# អុកស៊ីតូស៊ីន (OXYTOCIN)

អុកស៊ីតូស៊ីន គឺជាអ័រម៉ូន (Hormone) ចេញមកតាមធម្មជាតិរបស់សត្វមេ ។ តាមធម្មតាវាតែងតែមានកំរិតខ្ពស់នៅពេលដែលវាកើតកូននិងពេលសត្វដោយឈ្មោល ។ មុខនាទីរបស់វាគឺធ្វើអោយសាច់ដុំស្បូនកន្ត្រាក់ នៅពេល កើតកូនវាជួយជំរុញច្រានកូនចេញមកក្រៅ ។ នៅពេលពាក់គ្នាវាជួយជំរុញដំណើររបស់ស្ពែម៉ាតូសូអ៊ែ Spermatozoa ឱ្យឆ្លងកាត់ស្បូន សំដៅទៅអូវែ (Ovaries) ។

អុកស៊ីតូស៊ីន និងមានឥទ្ធិពលរបស់វាទៅលើកោសិកាសាច់ដុំនៅចំពោះមុខការកើតឡើងក្នុងកំរិតខ្ពស់របស់អ័រម៉ូន (អឺស្ត្រូសែន) Oestrogen ។ នេះបង្ហាញថាហេតុអ្វីបានជាវាមានសកម្មភាពនៅពេលកើតកូននិងនៅពេលសត្វពាក់គ្នា ពេលហោគេចាក់បញ្ចូលអុកស៊ីតូស៊ីន វានឹងមានឥទ្ធិពលនៅពេលដែលអឺស្ត្រូសែនមានកំរិតខ្ពស់ឡើង ។

## ✡ ការប្រើប្រាស់ក្នុងការព្យាបាល :

១-បច្ចេកទេសបង្កើតកូន : ក្នុងហេតុការណ៍នៃការបង្កើតកូនត្រូវពន្យាពេលយូរ និងមានការហេវហត់ដល់សាច់ដុំស្បូន គេអាចប្រើថ្នាំអុកស៊ីតូស៊ីននេះសំរាប់ជំនួយដល់ការកន្ត្រាក់សាច់ដុំស្បូនម្តងទៀត ។ ជាពិសេសថ្នាំនេះមានប្រយោជន៍សំរាប់សត្វ ដែលមានកូនច្រើនដូចជា : ឆ្កែ និងជ្រូក ។ ពីព្រោះចំនួនកូនច្រើនពេក ទម្ងន់របស់កូនរួមផ្សំមួយនឹងពេលវែងក្នុងការបញ្ចេញ កូនមកក្រៅ វាបណ្តាលឱ្យស្បូនមានការហេវហត់ដោយងាយ ហើយវាពន្យឺតឈប់កន្ត្រាក់តែម្តង ដូច្នេះអុកស៊ីតូស៊ីនប្រយោជន៍ជាពិសេសសំរាប់ហេតុការណ៍បែបនេះ ព្រោះវាមានការលំបាកក្នុងការទាញកូនចេញមកក្រៅ ។

## ✡ ការប្រុងប្រយ័ត្ន

: -ត្រូវដឹងឱ្យច្បាស់ថា តើមាត់ស្បូនបានបើកពេញលេញហើយរឺនៅ? បើសិនមានកូនសត្វមួយរឺច្រើន និងថង់ទឹកភ្លោះត្រូវបានច្រានចេញ នោះមាត់ស្បូនត្រូវរីក ។ ចំពោះជ្រូកគេអាចស្ទាបដោយដៃបាន បើសិនជាគេប្រើអុកស៊ីតូស៊ីនមុនមាត់ស្បូនបានបើក នោះសំពាធនៃការកន្ត្រាក់កើតឡើងខ្លាំងនឹងបណ្តាលអោយរហែកស្បូន ។

-ត្រូវដឹងឱ្យច្បាស់ថា គ្មានអ្វីនៅស្ទះមាត់ស្បូនដូចជាកូននៅស្ទិតជាប់គ្នា ជាការសំខាន់ ណាស់ត្រូវដឹងថាកូនសត្វស្ថិតនៅក្នុងស្ថានភាពធម្មតាដែលត្រូវចេញឬទេ? មុននឹងប្រើថ្នាំអុកស៊ីតូស៊ីន ។

២-បញ្ចេញទឹកដោះ : ចំពោះជ្រូកញី និងគោញីក្មេងដែលមានទឹកដោះតិច អុកស៊ីតូស៊ីនអាចប្រើប្រាស់បានតាមកំរិតកំហាប់ដូចខាងក្រោម ដើម្បីជំរុញឱ្យទឹកដោះហូរចេញតាមដោះ ។ ការធ្វើបែបនេះ វាមានប្រសិទ្ធភាពត្រឹមតែសប្តាហ៍ទី១និង ទី២នៃការបំបៅកូនតែប៉ុណ្ណោះ ។

- កំរិតប្រើប្រាស់ : ជ្រូកញី : ១០-២០ IU អុកស៊ីតូស៊ីន ចាក់សាច់ដុំ (I/M) ឬក្រោមស្បែក (S/C)
  គេអាចចាក់ម្តងទៀតក្នុងរយៈពេល ១៥-៣០នាទីក្រោយមក បើចាំបាច់ត្រូវប្រើ
  គោញី : ១០-៤០ IU អុកស៊ីតូស៊ីន ចាក់សាច់ដុំ (I/M) ។

# ហ្វែរកូបសង់ ១២ (FERCOBSANG12)

ហ្វែរកូបសង់ ១២ មានចំណុះ ១០០ម.ល ។

ថ្នាំនេះផ្សំឡើងពីពពួកវិតាមីនច្រើនជំពូក

**ការប្រើប្រាស់ :** ហ្វែរកូបសង់១២ ប្រើក្នុងករណីសត្វ

-ទើបតែជាសះស្បើយពីជំងឺឆ្លង

- ទើបតែជាសះស្បើយពីជំងឺបរាសិត

-ជួយបង្កើនគ្រាប់ឈាមក្រហម បំបាត់ការស្លេកស្លាំង

-ជួយឱ្យសត្វមានការធំធាត់លឿន

**វិធីប្រើ :** ចាក់សាច់ដុំ (I/M) ឬក្រោមស្បែក (S/C) ។

| | | | |
|---|---|---|---|
| ✡គោ ក្របី សេះ | (ធំ) | ២០ម.ល | សំរាប់សត្វមួយក្បាល |
| | (ក្មេង) | ១០ម.ល | សំរាប់សត្វមួយក្បាល |
| ✡ចៀម ពពែ | (ធំ) | ៥ម.ល | សំរាប់សត្វមួយក្បាល |
| | (ក្មេង) | ១-២ម.ល | សំរាប់សត្វមួយក្បាល |
| ✡ជ្រូក | (ធំ) | ១០ម.ល | សំរាប់សត្វមួយក្បាល |
| -ជ្រូកសាច់ | | ៥ម.ល | សំរាប់សត្វមួយក្បាល |
| -កូនជ្រូកអាយុ១៥-២០ថ្ងៃ : | | ២-៣ម.ល | (បាន ៤៨ម៉ោង ចាក់រំលឹកម្តងទៀត) |
| -កូនជ្រូកអាយុ ៤-៦ថ្ងៃ : | | ១-១.៥ម.ល (ចាក់តែម្តង) | |

✡ឆ្កែ ឆ្មា : បន្តក់តាមមាត់ : ១-២ដំណក់ សំរាប់ ១គក្រ នៃទំងន់សត្វរស់ ។

**ការថែរក្សា :** -ទុកនៅកន្លែងត្រជាក់និងត្រូវម្លប់

**កំណត់សំគាល់ :** -លើកលែងតែកូនជ្រូកអាយុពី ២០ថ្ងៃឡើងទៅ ហ្វែរកូបសង់ត្រូវចាក់រំលឹកម្តងទៀត បន្ទាប់ពីចាក់លើកទី១ ពី ៣-៤ថ្ងៃ ។

.រាប់ជ្រូកធំ និងជ្រូកមានការធំធាត់លឿនត្រូវចាក់ម្តង ហើយត្រូវលាយនិងទឹកឬចំណើឱ្យស៊ី ។ រីឯកិរិតប្រើប្រាស់ដូចចាក់ដែរ ។

# ទីឡូ — ប៉េសេ
# TYLO - PC

ជាថ្នាំសំរាប់ចាក់ ១ដបមានចំណុះ ៥០ម.ល ។ ( កូរ៉េ)

## ១_សមាសធាតុ :

-Tylosin
-Chloramphenicol
-Prednisolone

## ២_គុណភាពព្យាបាល :

-ជំងឺប្រព័ន្ធដកដង្ហើម ជំងឺក្រពះ ពោះវៀន របួសក្លាយ ជំងឺផ្លូវនោម និងជំងឺផ្សេងទៀត ដែលអាចព្យាបាលដោយ Tylosin និង chloramphenicol ។

**-គោ ក្របី :** ព្យាបាលជំងឺរលាកសួត សារទឹក រលាកស្បូន លាសដោះ រលាកតំរងនោម ស្អុយក្រចក។

**-ជ្រូក ឆ្កែ :** រលាកសួត រលាកស្បូន រលាកដោះ ខះទឹកដោះ រាគមួលជ្រូក ចុះរាគ រលាកពោះវៀន។

## ៣_ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :

-ចាក់សាច់ដុំ (IM)

**-សេះ គោ ក្របី :** ៣-៤មល / ១០០គក្រ ទំងន់សត្វរស់ចាក់រៀងរាល់ថ្ងៃ

**-ជ្រូក ចៀម ពពែ :** ១ មល / ១០០គក្រ ទំងន់សត្វរស់ចាក់រៀងរាល់ថ្ងៃ

**-សត្វស្លាប :** ២-៣មល / ១០០គក្រ ទំងន់សត្វរស់ចាក់រៀងរាល់ថ្ងៃ

## ៥_ការប្រុងប្រយ័ត្ន :

-ហាមប្រើលើសត្វជើម

-មិនត្រូវបរិភោគសាច់សត្វ ក្នុងចន្លោះពេល ៤ ថ្ងៃ ក្រោយការប្រើប្រាស់ថ្នាំចុងក្រោយ ។

-រក្សាថ្នាំទុក ក្នុងកន្លែងត្រជាក់ ស្ងួត កុំឱ្យប៉ះពន្លឺថ្ងៃ ។

# អំពីដិចសាឡូន
# AMPIDEXALONE

ជាថ្នាំសំរាប់ចាក់ ១ដបមានចំណុះ ១០០ម.ល ។

**១.សមាសធាតុ :**

-Ampicillin tritydrate
-Colistin
-Dexamethasone

**២.គុណវិបត្តិ :**

-គោ ក្របី ចៀម ពពែ និងជ្រូក ការពារ និងព្យាបាលការបង្កជំងឺ បណ្តាលមកពីពួកមីក្រូអ៊ែរកាទីស ដែលចាញ់និង Ampicillin និង Colistin ដូចជា :

ជំងឺផ្លូវដង្ហើម

-ជំងឺតំរងនោម ជំងឺប្រដាប់បន្តពូជ ជំងឺភ្នែក

-ការបង្ករោគសាំញ៉ាំ ដោយពួកបាក់តេរី ដែលបណ្តាលមកពីឥទ្ធិពលអាក្រក់នៃជំងឺបង្កដោយវីរុស

-ឡិបតូស្ពៀរ៉ូស៊ីស

-ជំងឺហើមកូនជ្រូក រលាកផ្ចិត រលាកស្រោមខួរ

-ជំងឺសាល់ម៉ូណែលឡូស៊ីស ជំងឺសារទឹក.......

**៣.ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :**

-ចាក់សាច់ដុំ (IM) ចាក់ក្រោមស្បែក (SC)

**-គោ ជ្រូក ពពែ ចៀម :** 1ml / 10kg នៃទំងន់សត្វរស់ ក្នុង ១ថ្ងៃ។

-រយះពេលព្យាបាល ៣ថ្ងៃ ។

**៤.បំរាម :**

-ហាមប្រើចំពោះសត្វផើម ក្នុងពាក់កណ្តាលដំណាក់កាលទី ២ នៃគភ៌ ។

-ហាមប្រើចំពោះសត្វទន្សាយ និងសត្វកកេរ ។

**៥.ការប្រុងប្រយ័ត្ន :**

-ក្រឡុកឱ្យរលាយ មុនប្រើ

-ហាមចាក់តាមសរសៃវ៉ែន (IV)

**៦.រយះពេលហាមប្រើប្រាស់ :**

-សាច់សត្វ : ២១ថ្ងៃបន្ទាប់ពីបញ្ចប់ការព្យាបាល និងទឹកដោះគោ យកចេញពីមេគោ ព្យាបាលរយះពេល៥ពេល ។

ប្រភេទថ្នាំ : វីតាមីន

ឈ្មោះថ្នាំ : AMINOVITAL-HIGH Inj (20 cc)

ការប្រើប្រាស់ : ប្រើប្រាស់ក្នុងការការពារនិងព្យាបាលនៅពេលដែលសត្វមានការបាត់បង់ជាតិទឹកនៅក្នុងខ្លួនរឺនោ
ដែលមានការបាត់បង់ប្រូតេអ៊ីនក្រោយពេលវះកាត់ដោយសារ មានការបាត់បង់ឈាមច្រើន ។

របៀបប្រើប្រាស់ : ចាក់ក្រោមស្បែក , សាច់ដុំ រឺ តាមសរសៃវ៉ែន

កំរិតនៃការប្រើប្រាស់ : ចំពោះសត្វគោ ក្របី សេះ ចៀម ពពែ ជ្រូក ឆ្កែ ត្រូវចាក់ ១ ម.ល សំរាប់ ១០
នៃទំងន់សត្វ ។ ( ១ដងរឺ៣ដងរៀងរាល់ថ្ងៃ )

ការប្រុងប្រយ័ត្ន :

- ក្នុងករណើចាក់តាមសរសៃវ៉ែនត្រូវបាញ់ថ្នាំបញ្ចូលយ៉ាងយឺត១ ។
- រក្សាថ្នាំនៅកន្លែងត្រជាក់ ( ៨-១៥ អង្សា) ។

ប្រភេទថ្នាំ : សារធាតុរ៉ែ

ឈ្មោះថ្នាំ : CALCIUM-FORT( 5 cc )

ការប្រើប្រាស់ : ប្រើប្រាស់ក្នុងការការពារនិងព្យាបាលជំងឺសត្វទន់ឆ្អឹង ស្វិតដៃជើង ជំងឺសរសៃរប្រសាទ ជំនួយកំ
ជាដើម ។

របៀបប្រើប្រាស់ : ចាក់សាច់ដុំ រឺ ចាក់សរសៃ

កំរិតនៃការប្រើប្រាស់ : ចំពោះសត្វធំ ត្រូវចាក់ ៥-១០ អំពូលសំរាប់សត្វ ១ក្បាល ក្នុង១ថ្ងៃ ។

ចំពោះសត្វតូច ត្រូវចាក់ ១-៤ អំពូល សំរាប់សត្វ ១ក្បាល ក្នុង១ថ្ងៃ / ១ អំពូល ៥ ml

ការប្រុងប្រយ័ត្ន :

ក្នុងករណើចាក់សាច់ដុំ ត្រូវញឹកប្រាប់កន្លែងចាក់អោយបានល្អ ។

# កាល់ស្យូម - $B_{12}$
## CALCIUM-$B_{12}$

ជាថ្នាំសំរាប់ចាក់ ១ដបមានចំណុះ ៥០ម.ល ។

**១.សមាសធាតុ :**

-Calcuim gluconate

-Vitamin $B_{12}$

**២.គុណភាពវិធី :**

ព្យាបាល និងការពារជំងឺ :

-កង្វះកាល់ស្យូម

-ជំងឺខ្វះឈាម

-ជំងឺខ្វិន របស់សត្វគោ ក្របី មាន់ ទា

-ជួយបង្កើនកំលាំងការពារ ទប់ទល់ជាមួយមេរោគ

-ធ្វើឱ្យមេជ្រូកសំបូរទឹកដោះ ។

**៣.ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :**

-ចាក់សាច់ដុំ (IM) ឬសរសៃឈាម (IV)

**-ជ្រូក គោ ក្របី :** ១០-២០មល / ក្បាល / ថ្ងៃ

**-មាន់ ទា :** ១០មល / ២០-៣០គក្រ/ថ្ងៃ

ព្យាបាលរយៈពេល ៣-៧ថ្ងៃជាប់គ្នា ។

**៤.ការប្រុងប្រយ័ត្ន :**

ទុកដាក់ថ្នាំក្នុងកន្លែងត្រជាក់ ស្ងួត និងកុំឱ្យប៉ះពន្លឺថ្ងៃ ។

**ប្រភេទថ្នាំ** : វីតាមីន

**ឈ្មោះថ្នាំ** : B-COMPLEX

**ការប្រើប្រាស់** ៖ ថ្នាំនេះប្រើប្រាស់ក្នុងការការពារនិងព្យាបាលជំងឺ ខ្វះវីតាមីន B ជំងឺក្រិន ស្វិតដៃជើង និងបង្កើន លូតលាស់ជាដើម ។

**របៀបប្រើប្រាស់** ៖ ចាក់សាច់ដុំ រឺ តាមសរសៃវ៉ែន

**កំរិតនៃការប្រើប្រាស់** ៖ ចំពោះសត្វជ្រូក ត្រូវចាក់ ១ ម.ល សំរាប់ ១០-១៥គ.ក្រ នៃទំងន់សត្វ ។ (រយៈពេល ព្យាបាល ពី៦-៧ថ្ងៃ)

ចំពោះបក្សីត្រូវចាក់ ១ម.ល សំរាប់ ៥-១០ គ.ក្រ នៃទំងន់សត្វ ។(រយៈពេលព្យាបាលពី ៣-៥ថ្ងៃ)

កិរិតនិងតារាងប៉ាន់ស្មានតំលៃ ( ជ្រូក)

ឈ្មោះថ្នាំ ........................................................................

តំលៃក្នុងមួយកញ្ចប់ ដប ........................................................................

ទំហំ មួយកញ្ចប់ ដប........................................................................

| ទំងន់ជ្រូក | ចំនួនថ្នាំ | តំលៃថ្នាំ | ប្រាក់កសិករបង់ |
|---|---|---|---|
| ១គក្រ | | | |
| ២គក្រ | | | |
| ៣គក្រ | | | |
| ៤គក្រ | | | |
| ៥គក្រ | | | |
| ៦គក្រ | | | |
| ៧គក្រ | | | |
| ៨គក្រ | | | |
| ៩គក្រ | | | |
| ១០គក្រ | | | |
| ២០គក្រ | | | |
| ៣០គក្រ | | | |
| ៤០គក្រ | | | |
| ៥០គក្រ | | | |
| ៦០គក្រ | | | |
| ៧០គក្រ | | | |
| ៨០គក្រ | | | |
| ៩០គក្រ | | | |
| ១០០គក្រ | | | |
| ១១០គក្រ | | | |
| ១២០គក្រ | | | |
| ១៣០គក្រ | | | |
| ១៤០គក្រ | | | |
| ១៥០គក្រ | | | |

# បេ កំប្លិច អា, ដេ, អ៊ី
# B. COMPLEX A D E

ជាថ្នាំ សំរាប់ចាក់ ១ដបមានចំណុះ ១០០មល ។

## ១_ សមាសធាតុ :

- Vitamine A
- Vitamine D
- Vitamine E
- Vitamine $B_1$
- Vitamine $B_2$
- Vitamine $B_6$
- Vitamine PP (Nicotinamide)

## ២_ គុណវិជ្ជ :

- ការពារ និងព្យាបាល ជំងឺកង្វះវីតាមីន ។
- ធ្វើឱ្យសត្វមានសុខភាពល្អ ឆ្ងាញ់ចំណី ជំរុញការរំលាយអាហារ ធំធាត់លឿន
- ជួយបង្កើនកំលាំងឱ្យសត្វ ក្នុងការព្យាបាលជំងឺ
- បង្កើនកំលាំងការពារ ទល់នឹងជំងឺ នៅពេលដែលបរិយាកាស មិនសមស្របសំរាប់សត្វ ។

## ៣_ ផ្លូវបញ្ចូលថ្នាំ និងកំរិតប្រើ :

ចាក់សាច់ដុំ (IM) ។

- សត្វធំ : ១ ml/១០ kg ទំងន់រស់
- សត្វតូច : ១ ml/០៥ kg ទំងន់រស់

## ៤_ ការថែរក្សា :

ទុកដាក់ថ្នាំក្នុងកន្លែងត្រជាក់ ស្ងួត និងកុំឱ្យប៉ះពន្លឺថ្ងៃ ។

# 5.4.3 សកម្មភាព

## ការចាក់វ៉ាក់សាំងគោ ក្របី ជ្រូក មាន់





# 5.4.4 សកម្មភាព

# ល្បែងអំពីការចិញ្ចឹមសត្វ



សិក្ខាកាមបានរៀនហើយអំពីវ៉ាក់សាំងគោ ក្របី ជ្រូក មាន់ ដូចនេះពេលលេងល្បែង គេត្រូវគិតអំពីតំណែ
សាំង ។

# មេរៀនទី ៦

## ជំងឺសំខាន់ៗមួយចំនួនរបស់សត្វនៅក្នុងប្រទេសកម្ពុជា



## 6 .1 សេចក្តីផ្តើម

នៅក្នុងមេរៀននេះអ្នកនឹងបានរៀនអំពីជំងឺសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា ។

## 6 .2 គោលបំណង

ក្រោយពីបានបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោម :

- ដាក់ឈ្មោះជំងឺទាំង៤ របស់សត្វគោក្របីដែលបង្កឡើងដោយមេរោគ
- ដាក់ឈ្មោះជំងឺទាំង៣ របស់សត្វគោក្របីដែលបង្កឡើងដោយព្រូន
- ដាក់ឈ្មោះជំងឺទាំង៤ របស់សត្វជ្រូកដែលបង្កឡើងដោយមេរោគ
- ដាក់ឈ្មោះជំងឺទាំង៣ របស់សត្វជ្រូកដែលបង្កឡើងដោយព្រូន ឬដោយអង្កែ
- ដាក់ឈ្មោះជំងឺទាំង៤ របស់សត្វមាន់ដែលបង្កឡើងដោយមេរោគ
- ចេះប្រើប្រាស់សៀវភៅដើម្បីរកឃើញអំពីលក្ខណៈនៃជំងឺនីមួយៗដូចខាងក្រោម :
  - ស្គាល់រោគសញ្ញានៃជំងឺនីមួយៗ
    - តើជំងឺនេះបណ្តាលមកពីមូលហេតុអ្វី?
    - តើជំងឺឆ្លងពីសត្វមួយទៅសត្វមួយទៀតតាមរបៀបណា?
    - តើព្យាបាលជំងឺយ៉ាងដូចម្តេច?
    - តើការពារជំងឺសត្វយ៉ាងដូចម្តេច?

## 6 .3 សំភារៈសំរាប់សិក្សា

## 6 .4 អត្ថបទ

# ជំងឺដែលបង្កឡើងដោយសារព្រូន

- ព្រូនមូលធំកូនក្របី
- ព្រូនមូលផ្សេងទៀតរបស់ គោ ក្របី
- ព្រូនសំប៉ែតរបស់សត្វ គោ ក្របី
- ព្រូនមូល របស់សត្វជ្រូក
- ជំងឺចុងអង្គររបស់សត្វជ្រូក និងមនុស្ស

# ជំងឺដែលបង្កឡើងដោយមេរោគ

- ជំងឺសារទឹកសត្វគោ ក្របី
- ជំងឺបូសខ្យល់សត្វគោ ក្របី
- ជំងឺឈាមខ្មៅសត្វគោ ក្របី ជ្រូក និងមនុស្ស
- ជំងឺអុតក្តាមសត្វគោ ក្របី
- ជំងឺរាគរូសកូនជ្រូក
- ជំងឺប៉េស្តជ្រូក
- ជំងឺហើមស្ងួតជ្រូក
- ជំងឺកញ្ជ្រិលជ្រូក និងមនុស្ស
- ជំងឺញូវកាសមាន់
- ជំងឺអុតមាន់
- ជំងឺអាសន្នរោគមាន់ និងទា
- ជំងឺតេតាណូស សត្វជ្រូក គោ ក្របី សេះ និងមនុស្ស
- ជំងឺឆ្កែឆ្កួត និងជំងឺដែលបណ្តាលមកពីឆ្កែឆ្កួតខាំ

**********

# ជំងឺមួយចំនួនរបស់សត្វដែលបង្កឡើងដោយមេរោគ



# ជំងឺសារទឹកសត្វគោ ក្របី



ជំងឺសារទឹកជាជំងឺឆ្លងកាចសាហាវមួយក្នុងចំណោមជំងឺឆ្លងទាំងអស់ ។ ជំងឺនេះកើតមានឡើងនៅលើសត្វពាហណៈគ្រប់ប្រភេទជាពិសេសចំពោះសត្វគោ ក្របី ។ ក៏ប៉ុន្តែចំពោះសត្វជទង់ៗឆាប់ទទួលនូវជំងឺនេះណាស់ ។ សត្វក្របីងាយកើត ជំងឺនេះ ជាងសត្វគោ ហើយអត្រាស្លាប់របស់សត្វក្របីដោយសារជំងឺនេះមានពីរដងលើសសត្វគោ ។

ជំងឺនេះបង្កឡើងដោយមេរោគបាក់តេរី ។ មេរោគបាក់តេរីនេះអាចរស់នៅក្នុងមជ្ឈដ្ឋានខាងក្រៅ ក្នុងរយៈពេលខ្លី (១ ឬ២ ថ្ងៃ) ។

ជំងឺសារទឹកសត្វគោ ក្របីច្រើនកើតឡើងជាញឹកញាប់នៅដើមរដូវវស្សា និងនៅចុងរដូវវស្សា ។ តាមបទពិសោធន៍ ជាក់ស្តែងបានបង្ហាញអោយឃើញថា នៅពេលដែលសត្វចុះខ្សោយ គឺជាមូលហេតុមួយសំខាន់ដែលនាំឱ្យសត្វកើតជំងឺ សារទឹកនេះឡើង ។

## ១-ការចំលងជំងឺ :

មេរោគបាក់តេរីនេះអាចឆ្លងពីសត្វឈឺទៅសត្វជាបានយ៉ាងងាយ ។ ជាទូទៅចំពោះសត្វឈឺជំងឺនេះ នៅពេលដំបូង និង មានហៀរទឹកមាត់ និងសំបោរមកក្រៅ ដែលមានលាយជាមួយនិងចំនួនយ៉ាងច្រើននៃមេរោគបាក់តេរី នេះនៅលើកន្លែងដែលវារស់នៅ ។ ដូចនេះតំបន់ដែលនៅជុំវិញ និងសំភារៈ ព្រមទាំងទឹកនិងចំណើដែលបានប្រឡាក់ទឹកមាត់សំបោរ និងលាមករបស់ សត្វឈឺនោះគឺជាមូលហេតុនៃការចំលងជំងឺពីសត្វឈឺទៅសត្វជាគឺនៅពេលដែលសត្វជាទៅប៉ះបូលិតវត្ថុ ឬបានស៊ីចំណើដែល មានប្រឡាក់មេរោគនោះ ។

## ២-រោគសញ្ញា :

សីតុណ្ហភាពខ្លួនសត្វឡើងខ្លាំង (៤១-៤២អង្សា) លេចឡើងនូវលក្ខណៈដុនដាប សត្វអាចស្លាប់ក្នុងរយៈពេល៦-២៤ ម៉ោង ។ ពេលខ្លះសត្វអាចស្លាប់ដោយគ្មានឃើញរោគសញ្ញាអ្វីទាំងអស់ ។ ជារឿយៗគេក៏សង្កេតឃើញសត្វមានហើមនៅ ក្រោម ថ្គាម ហើមក និងហើមពោះ អណ្តាតហើមតឹងល្បៀនចេញមកក្រៅ ។

## ៣-ការព្យាបាល :

ការព្យាបាលត្រូវប្រព្រឹត្តទៅអោយទាន់ពេលដោយប្រើថ្នាំសំលាប់មេរោគបាក់តេរីដូចជា :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១.......................................... | .......................................... |
| ២.......................................... | .......................................... |
| ៣.......................................... | .......................................... |

បើសិនជាការព្យាបាលប្រព្រឹត្តទៅក្រោយពេលចេញរោគសញ្ញាហើយនោះ ភាគច្រើនមិនអាចធ្វើអោយសត្វជាឡើយ ។

## ៤-វិធានការការពារជំងឺ :

-ចាក់ថ្នាំការពារជំងឺសារទឹកអោយបានត្រឹមត្រូវ (ត្រូវចាក់ថ្នាំការពារជំងឺជារៀងរាលឆ្នាំជាពិសេស ចំពោះសត្វគោ ក្របី ដែលមានអាយុក្រោមបីឆ្នាំ) ។

-មិនត្រូវប្រើសត្វអោយហួសកំលាំងឡើយ ពោលគឺកុំអោយសត្វចុះខ្សោយខ្លាំងពេក ។

-នៅក្នុងក្រោលសត្វ ត្រូវមានអនាម័យជានិច្ច ហើយចៀសវាងកុំអោយភ្លៀងសាចចូល និងត្រូវខ្យល់ខ្លាំងពេក ។

-ផ្តល់ចំណីអាហារគ្រប់គ្រាន់ និងមានជីវជាតិត្រឹមត្រូវ ។

**********

# ជំងឺបូសខ្យល់



បូសខ្យល់គឺជាជំងឺកាចសាហាវដែលកើតមានឡើងលើសត្វពាហនៈជាពិសេសសត្វ គោ ក្របី ដែលមានអាយុក្រោម ៣ឆ្នាំ ។ ជំងឺនេះវាបណ្តាលអោយសត្វស្លាប់យ៉ាងឆាប់រហ័ស ។ លក្ខណៈពិសេសរបស់ជំងឺនេះគឺគ្រុនក្តៅនិងមានហើមសាច់ ដុំ ប្រសិនបើយើងច្របាច់សាច់ដុំត្រង់កន្លែងហើមយើងនឹងឮសំលេងក្រិប១ដោយសារមានពពុះខ្យល់នៅក្រោមស្បែក ។

## ១.ការចំលងជំងឺ :

មេរោគបាក់តេរីនៃជំងឺនេះអាចឆ្លងចូលទៅក្នុងខ្លួនសត្វ ដោយសារតែមានមេរោគនេះដែលបានរស់នៅយ៉ាងយូរឆ្នាំ លើដីនៅលើកន្លែងដែលមានដុះស្មៅ ហើយនៅពេលដែលសត្វទៅស៊ីស្មៅនៅកន្លែងនោះ មេរោគទាំងនេះក៏ចូលទៅក្នុង ខ្លួនសត្វតាមរយៈចំណីនេះ ។ ម្យ៉ាងទៀតមេរោគបាក់តេរីនេះក៏អាចចូលទៅក្នុងខ្លួនសត្វតាមមុខរបួសដែលប្រឡាក់ដីមាន មេរោគនេះផង ដែរ ។

## ២.រោគសញ្ញា :

មានសត្វជាច្រើនដែលស្លាប់ដោយមិនបានបង្ហាញនូវរោគសញ្ញានៃជំងឺនេះឡើយ ។ បើសិនជាមានគឺគ្រុនក្តៅខ្លាំងល្វិតល្វៃមិនស៊ីចំណី ដំណើរពិការថែមទាំងមានហើមប៉ោងគួរអោយកត់សំគាល់នៅលើស្មា ឬនៅលើត្រគៀកផង ។ កន្លែងហើម ប៉ោងនេះឡើងក្តៅ បន្ទាប់មកប្រែជាត្រជាក់ហើយឈឺយ៉ាងខ្លាំង ។ បើយើងច្របាច់កន្លែងហើមប៉ោងនេះនឹងឮសូរក្រិប១ដែលបណ្តាលមកពីមានពពុះខ្យល់នៅក្រោមស្បែក ។ ជំងឺនេះវិវត្តន៍យ៉ាងឆាប់រហ័ស ដែលអាចធ្វើអោយសត្វស្លាប់ក្នុងរយៈពេលពី ២ ទៅ ៣ថ្ងៃ ។

## ៣.ការព្យាបាល :

ការព្យាបាលត្រូវប្រព្រឹត្តទៅអោយទាន់ពេលដោយប្រើថ្នាំប្រភេទសំលាប់មេរោគបាក់តេរីដូចជា :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១.......................................... | .......................................... |
| ២.......................................... | .......................................... |
| ៣.......................................... | .......................................... |

## ៤.វិធានការការពារ ៖

-ការចាក់ថ្នាំការពារជំងឺនេះត្រូវតែប្រព្រឹត្តទៅជារៀងរាល់ឆ្នាំចំពោះ គោ ក្របី ដែលមានអាយុតិច ៣ឆ្នាំ ។ នៅតំបន់ណាដែលមានជំងឺបូសខ្យល់កើតឡើងញឹកញាប់ ការចាក់ថ្នាំការពារគឺជាការចាំបាច់បំផុត ។

-សាកសពរបស់សត្វដែលស្លាប់ដោយសារជំងឺនេះត្រូវតែយកទៅដុត រឺកប់ក្នុងរណ្តៅយ៉ាងជ្រៅ ។

**********

# ជំងឺឈាមខ្មៅ



ជំងឺឈាមខ្មៅគឺជាជំងឺកាចសាហាវមួយដែលកើតឡើងចំពោះពពួកសត្វដែលមានឈាមក្តៅស្ទើរតែទាំងអស់ដូចជា : គោ ក្របី ចៀម ពពែ ជ្រូក សេះ ព្រមទាំងមនុស្សផងដែរ ។ ជំងឺនេះមានលក្ខណៈជាពីសរាលដាលពាសពេញខ្លួន ហើយ បណ្តាលអោយសត្វស្លាប់យ៉ាងឆាប់រហ័ស ដោយមានឈាមហូរចេញតាមរន្ធធម្មជាតិទាំងឡាយ ដូចជា :រន្ធញើស រន្ធច្រមុះ រន្ធគូថ មាត់ ។ល ។

ជំងឺនេះបណ្តាលមកពីមេរោគបាក់តេរីមួយប្រភេទមេរោគនេះ នៅពេលវាប៉ះខ្យល់ វានឹងបង្កើតបានជាស្រទាប់ការពារខ្លួនវាដែលអាចធ្វើអោយវារស់នៅបានយ៉ាងយូរឆ្នាំនៅក្នុងដី ។

## ១.ការចំលងជំងឺ :

មេរោគនេះអាចឆ្លងពីសត្វមួយទៅសត្វមួយបានតាមមាត់ ពេលដែលសត្វស៊ីអ្វីដែលមានលាយឡំដោយមេរោគបាក់តេរីនោះ ។ សាកសពសត្វដែលស្លាប់ដោយសារជំងឺឈាមខ្មៅនិង កន្លែងធ្វើការវះកាត់សាកសពសត្វនោះ គឺជាប្រភពនៃការចំលងជំងឺយ៉ាងសំខាន់ ព្រោះដោយសារតែសត្វឬមនុស្សយកសាច់សត្វស្លាប់នេះមកស៊ីឬបរិភោគ និងមេរោគអាចរស់នៅកន្លែងនេះបានរហូតដល់ ២០ឆ្នាំ ។ ការចាប់ផ្តើមនៃជំងឺនេះច្រើនតែកើតមានឡើងនៅពេលភ្លៀងធ្លាក់ដំបូង ។

## ២.រោគសញ្ញា :

ការពិនិត្យសាកសពសត្វដែលសង្ស័យថាកើតជំងឺឈាមខ្មៅគឺជាការនាំអោយមានការគ្រោះថ្នាក់បំផុត ។ អ្នកពិនិត្យត្រូវប្រុងប្រយ័ត្នកុំវះខ្មោចសត្វ ហើយជៀសវាងកុំប៉ះពាល់ផ្ទាល់នូវអ្វីដែលចេញពីខ្លួនសត្វ និងកុំយកសាច់ទៅបរិភោគ ព្រោះវានឹងធ្វើអោយអ្នកវះកាត់ ឬអ្នកបរិភោគសត្វនេះឈឺឬស្លាប់បាន ។ ត្រូវកប់ខ្មោចសត្វនោះចោលក្នុងរណ្តៅយ៉ាងជ្រៅ ឬក៏ដុតបំផ្លាញចោល ។



# ជំងឺអុតក្តាម



អុតក្តាមគឺជាជំងឺរាតត្បាតបំផុត ជាពិសេសលើសត្វគោ ក្របី និងពពួកសត្វដែលមានម្រាមជើងចង្វៃកដូចជាជ្រូ ជាដើម ។ លក្ខណៈពិសេសរបស់ជំងឺនេះ គឺដំបូងសត្វមានសភាពគ្រុនក្តៅ រួចមានដំបៅនៅមាត់ និងនៅចុងជើង តែទូទៅវាមិនបណ្តាលអោយស្លាប់ទេ ចំពោះសត្វធំតែអាចបណ្តាលអោយស្លាប់បានចំពោះកូនសត្វ ព្រោះមេរោគអាចជ្រៀ ចូលដល់បេះដូងរបស់កូនសត្វ ។ ជំងឺនេះបណ្តាលមកពី មេរោគវីរុស ។

## ១.ការចំលងជំងឺ :

មធ្យោបាយសំខាន់នៃការចំលងជំងឺគឺ សត្វស៊ីអ្វីៗដែលមានលាយឡំដោយមេរោគ ។ មេរោគនេះអាចប៉ើង តាមខ្យល់ តាមសត្វស្លាប តាមសាច់សត្វឈឺស្លាប់... ។ មនុស្សយើងក៏មានមធ្យោបាយ នៃការចំលងមេរោគមួយនេះដែរ គឺតាមរបស់របរប្រើប្រាស់ សំលៀកបំពាក់ ស្បែកជើង និងសំភារៈផ្សេងៗទៀតដែលប្រឡាក់ដោយមេរោគនេះ ។

## ២.រោគសញ្ញា :

ជាដំបូងសត្វក្តៅខ្លាំង ស្ងោមិនស៊ីចំណី មាត់រលាកធ្វើអោយសត្វទំពារអៀងនិងលេបចំណីអាហារដោយពិបាក ។ បន្ទាប់មកកំដៅក៏ធ្លាក់ចុះធម្មតាវិញ តែមានទឹកមាត់ហៀរយ៉ាងច្រើននិងបន្ទាប់មកឃើញមានដំបៅក្នុងមាត់ ដំបៅច្រវ៉ែកជើង និងគល់ក្រចក ។

ចំពោះសត្វមេគេសង្កេតឃើញមានដំបៅនៅចុងដោះផង ដែលជាហេតុបណ្តាលអោយកូនសត្វបៅពុំកើត ។

## ៣.ការព្យាបាល :

ក្នុងការព្យាបាលគឺមិនទាន់មានថ្នាំណាអាចសំលាប់មេរោគវីរុសនេះបាននៅឡើយទេ ។ ប៉ុន្តែយើងធ្វើការលាងសំអាតដំបៅដោយប្រើថ្នាំក្របាម ឬទឹកលាយជាមួយសារធាតុជូរ ដូចជាតាមទំលាប់របស់កសិករមួយចំនួនគាត់ប្រើសាច់ជូរខ្ទិះ ស្លឹក អំពិល ទឹកក្រូចឆ្មា ផ្លែស្ពឺ ........ជាដើម ។ យើងក៏ត្រូវប្រើប្រាស់ថ្នាំសំលាប់មេរោគបាក់តេរីក្នុងការព្យាបាលផងដែរ ។ ព្រោះនៅពេលដែលមានដំបៅនៅតាមមាត់និងគល់ក្រចករលួយស្អុយ បានន័យថាមានមេរោគបាក់តេរីផ្សេងទៀតចូលលុកលុយហើយ ។

ថ្នាំសំលាប់ ឬបង្អង់សកម្មភាពបាក់តេរីដែលត្រូវប្រើក្នុងការព្យាបាលមានដូចជា :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១........................................ | ........................................ |
| ២........................................ | ........................................ |
| ៣........................................ | ........................................ |

## ៤-ការការពារជំងឺ ៖

-ត្រូវចាក់ថ្នាំការពារជំងឺនេះ

-ក្នុងពេលដែលជំងឺបានផ្ទុះឡើង

ការសំខាន់បំផុតគឺត្រូវបន្ថយនូវចលនាដឹកនាំសត្វពាហនៈ ព្រមទាំងការធ្វើដំណើររបស់ប្រជាជនដែរ ។

**********

# ជំងឺមួយចំនួនរបស់សត្វដែលបង្កដោយព្រូន















# ព្រូនមូលធំ  កូនក្របី



ព្រូននេះគឺជាព្រូនធំវែងពណ៌ស ចូលចិត្តរស់នៅក្នុងពោះវៀនរបស់កូនក្របី ។ ព្រូនធំពេញវ័យមានរាងធំ រា ចង្អៀះ ។ វាគឺជាព្រូនមានគ្រោះថ្នាក់បំផុតចំពោះកូនក្របី វាអាចធ្វើអោយកូនក្របីឈឺ ឬស្គម ។ បើសិនជាកូនក្រប ព្រូននេះច្រើន វាអាចធ្វើអោយកូនក្របីនោះស្លាប់ ។

## ១-ការចំលង :

កូនព្រូនវាមានរាងតូចៗ ហើយនៅក្នុងទឹកដោះ ។ កូនព្រូននេះចូលទៅក្នុងខ្លួនកូនក្របីនៅពេលដែលកូនក្រប ដោះមេវា ហើយកូនព្រូនទាំងនេះរស់នៅធំធាត់ក្នុងពោះវៀនកូនក្របី ហើយបញ្ចេញពងនៅទីនោះ ។ បន្ទាប់មកពង ក៏ចេញមកតាមលាមករបស់កូនក្របី ។ នៅពេលដែលមេក្របី ស៊ីចំណីដោយពងព្រូននោះ វានឹងញាស់នៅក្នុង ពោះ ក្របី ហើយធ្វើដំណើរទៅតាមឈាមឆ្ពោះទៅកាន់ដោះ ដែលជាកន្លែងវារង់ចាំអោយកូនក្របីមកបៅទឹកដោះនេះ ។

## ២-រោគសញ្ញា :

នៅពេលដែលកូនក្របីមានព្រូននៅក្នុងពោះវៀន នោះវាធ្វើឱ្យពោះវៀនមានការលំបាកក្នុងការបំពេញការងាររបស់វា ។ កូនក្របីដែលមានអាយុក្រោមបីខែ ពេលវាមានព្រូននេះច្រើនវានឹងបង្កជារាគរូស ចុះស្គមហើយអាចស្លាប់ទៀតផង ។ ចំពោះកូនក្របីដែលមិនស្លាប់ទេនោះ វានឹងមិនអាចធំធាត់រីលូតលាស់បានល្អឡើយ ។

ចំពោះក្របីធំ វាមិនឈឺដោយសារព្រូននេះទេ ព្រោះវាមានប្រព័ន្ធការពារខ្លាំង ដែលអាចទប់ទល់នឹងព្រូននេះបាន ។

## ៣-ការព្យាបាល :

នៅពេលកូនក្របីចុះស្គម យើងអាចសង្ស័យថា ប្រហែលជាមានព្រូននៅក្នុងពោះវៀន ហើយវាធ្វើអោយពោះវៀនមានការពិបាកក្នុងការបំពេញការងាររបស់វា ។ ដូច្នេះយើងគួរតែព្យាបាលវា ដោយប្រើថ្នាំសំលាប់ព្រូនដូចជា :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១........................................ | ........................................ |
| ២........................................ | ........................................ |
| ៣........................................ | ........................................ |

※សូមកុំភ្លេចថា យើងត្រូវធ្វើការព្យាបាលទៀត បើសិនជាវាមានកើតព្រូននេះទៀត ។

※សូមចងចាំដែរថា កូនក្របីក៏អាចចុះស្គមដោយសារខ្វះទឹកដោះ ខ្វះចំណើរអាហារល្អៗ និងខ្វះទឹក ។

## ៤-ការការពារ :

មានតែមធ្យោបាយតែមួយគត់ក្នុងការការពារជំងឺនេះគឺ ត្រូវធ្វើការទំលាក់ព្រូនគ្រប់កូនក្របីទាំងអស់នៅពេលដែលមានអាយុបាន៣អាទិត្យ ហើយត្រូវទំលាក់ព្រូនម្តងទៀតនៅពេលដែលមានអាយុបាន ៦អាទិត្យ ។

ត្រូវប្រើថ្នាំអោយបានត្រឹមត្រូវតាមកំរិតនៃការប្រើប្រាស់របស់វា ។ បើសិនជាយើងប្រើថ្នាំតិចពេកវាមិនអាចសំលាប់ព្រូនបានឡើយ ។ តែបើយើងប្រើថ្នាំលើសកំរិត នោះវាអាចធ្វើអោយស្លាប់ទាំងព្រូន ស្លាប់ទាំងកូនក្របី ។

※កូនក្របីដែលមានអាយុបាន៣ខែ មានទំងន់ប្រហែលជា ២០ទៅ ៣០គក្រ ។

※កូនក្របីដែលមានអាយុបាន៦ខែ មានទំងន់ប្រហែលជា ៣០ទៅ ៥០គក្រ ។

**សូមប្រើថ្នាំដូចថ្នាំក្នុងការព្យាបាលខាងលើ ?**

# ព្រូនមូលផ្សេងទៀតរបស់ គោ ក្របី





ព្រូននេះគឺជាព្រូនតូចៗ ហើយចូលចិត្តរស់នៅក្នុងក្រពះនិងក្នុងពោះវៀនរបស់គោ ក្របី ជាពិសេសកូន
និងកូន ក្របី ។ ព្រូនធំពេញវ័យខ្លះមានរាងធំ ដូចដែកគោលមួយហ៊ុន ។ ព្រូននេះវាអាចធ្វើអោយគោ ក្របី
និងលូតលាស់យឺត ។

## ១. ការចំលង :

ពងព្រូន និងកូនព្រូនវារស់នៅលើដី រឺស្មៅដែលជាកន្លែងគោក្របីរស់នៅ ។ នៅពេលដែលគោ ក្របីស៊ីស្មៅ វាតែង តែដោយពងព្រូនខ្លះៗទៅជាមួយ ។ ពងនេះវានឹងញាស់ ហើយរស់នៅក្នុងក្រពះ និងពោះវៀនរបស់គោ ក្របីនោះ ។ បន្ទាប់មក ព្រូននេះនឹងបង្កើតពង ហើយបញ្ចេញពងនេះមកខាងក្រៅតាមលាមក ។ ដូច្នេះវាត្រូវតែមានពងព្រូននៅគ្រប់ ទីកន្លែងដែល គោ ក្របីរស់នៅ និងគ្រប់កន្លែងដែលវាជុះអាចម៍ដាក់ ។

## ២. រោគសញ្ញា :

នៅពេលដែលគោ ក្របីមានព្រូននេះរស់នៅក្នុងក្រពះ និងពោះវៀនរបស់វា នោះវាធ្វើអោយក្រពះ និងពោះវៀន មានការលំបាកក្នុងការបំពេញការងាររបស់វា ។ ដូច្នេះហើយ វាធ្វើអោយសត្វចុះស្គម និងមិនអាចលូតលាស់បានល្អ ។ ធ្វើអោយ គោ ក្របីខ្លះឃ្លានចំណីខ្លាំង ហើយខ្លះមិនចង់ស៊ីចំណី ខ្លះរាគអាចម៍ និងខ្លះទៀតអាចទល់លាមក ។ គោ ក្របីដែលមានព្រូន នេះ ស្បែកវាស្ងួតហើយរោមវាបះ និងមើលទៅឃើញវាមានសុខភាពមិនល្អ ។

## ៣. ការព្យាបាល :

នៅពេលដែលគោ ក្របីរបស់អ្នកនៅក្នុងភូមិចុះស្គម ហើយអ្នកសង្ស័យថាបណ្តាលមកពីព្រូន ។ សូមអ្នកប្រញាប់ ប្រញាល់ទៅហៅភ្នាក់ងារសុខភាពសត្វភូមិ អោយមកធ្វើការវិភាគដើម្បីពិនិត្យអោយបានដឹងថា តើមានព្រូនមូលឬព្រូន ប៉ែតដែលបណ្តាលអោយមានបញ្ហានេះ ។ នៅពេលដែលភ្នាក់ងារសុខភាពសត្វភូមិបានដឹងអំពីប្រភេទនៃព្រូននោះហើយ អ្នកអាចជ្រើសរើសយកថ្នាំមកទំលាក់ព្រូនបានយ៉ាងត្រឹមត្រូវ ។ ខាងក្រោមនេះគឺជាឈ្មោះថ្នាំដែលប្រើសំរាប់សំលាប់ព្រូន របស់ គោ ក្របី :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១.......................................... | .......................................... |
| ២.......................................... | .......................................... |
| ៣.......................................... | .......................................... |

*សូមកុំភ្លេចថា យើងត្រូវធ្វើការព្យាបាលទៀត បើសិនជាវាមានកើតព្រូននេះទៀត ។

*សូមចងចាំដែរថាគោ ក្របីក៏អាចចុះស្គមដោយសារ ខ្វះចំណីអាហារល្អៗ និងខ្វះទឹក ។

## ៤-ការការពារ ៖

មានតែមធ្យោបាយតែមួយគត់ក្នុងការការពារបញ្ហានេះគឺ ត្រូវធ្វើការទំលាក់ព្រូនអោយបាន២ដងក្នុងរដូវ ចំពោះ គោក្របីដែលមានអាយុក្រោម ៣ឆ្នាំ ។

បើសិនជាធ្វើដូចនេះ វានឹងមិនសូវមានពងព្រូននៅក្នុងលាមកសត្វ និងមិនសូវមានពង និងកូនព្រូននៅលើ ស្មៅ ឬ កន្លែងដែលសត្វរស់នៅ ។

បើសិនជាអ្នកមិនបានធ្វើការទំលាក់ព្រូនសត្វទាំងអស់នៅក្នុងភូមិរបស់អ្នកទេនោះ អ្នកអាចធ្វើការទំលាក់ព្រូន របស់អ្នកក៏បាន ។ ប៉ុន្តែសត្វនោះវានិងឆាប់មានព្រូនបែបនេះទៀត ។ ដូចនេះ អ្នកត្រូវតែទំលាក់ព្រូននេះម្តងទៀត

អ្នកគួរតែប្រាប់ម្ចាស់សត្វផ្សេងទៀតដែលរស់នៅក្នុងភូមិអ្នកអំពីព្រូននេះ ហើយជួយជំរុញអោយគេធ្វើការទំ ព្រូនសត្វរបស់គេ ជាពិសេសចំពោះកូនសត្វ ដែលមានអាយុក្រោម ៣ឆ្នាំ ។

### សូមប្រើថ្នាំដូចថ្នាំក្នុងការព្យាបាលខាងលើ ។

# ព្រូនសំប៉ែតរបស់ គោ ក្របី



ព្រូននេះគឺជាព្រូនសំប៉ែត ពណ៌ក្រហមត្នោត ហើយចូលចិត្តរស់នៅក្នុងថ្លើមគោក្របី ។ ព្រូនធំពេញវ័យមានរាង ស្លឹក ឈើតូចៗ និងមានប្រវែងប្រហែល ២ហ៊ុន ។ ព្រូននេះអាចធ្វើអោយគោ ក្របីស្គម និងឈឺ ។ បើសិនជា គោ បើមានព្រូននេះ ច្រើនវានឹងអាចស្លាប់ ។

## ១.ការចំលង :

កូនព្រូនវាមានរាងតូចៗ ហើយរស់នៅលើស្លឹកឈើ ស្លឹកស្មៅ ទឹក ឬលើស្មៅដែលមានកន្លែងទឹកលិច ។ ព្រូននេះ ចូលនៅក្នុងខ្លួនគោក្របី នៅពេលដែលគោក្របីស៊ីស្មៅ ដោយកូនព្រូននេះ ។

ពេលចូលទៅដល់ក្នុងខ្លួនគោក្របី កូនព្រូនទាំងនេះធ្វើដំណើរទៅកាន់ថ្លើម និងធ្វើការលូតលាស់នៅក្នុងបំពង់ទឹក ពាត់ បន្ទាប់មកព្រូននេះនឹងបង្កើតពង ហើយបញ្ចេញពងនេះមកខាងក្រៅតាមលាមក ។ ពងទាំងនេះនិងញាស់នៅក្នុង ពាំង ឬនៅកន្លែងដែលមានទឹកលិច ។ ហើយបន្ទាប់មកកូនព្រូនទាំងនេះនឹងទៅរស់នៅក្នុងខ្យងមួយរយៈ ។ ចេញពី ខ្យងនៅពេលដែលខ្យងហែលទៅទុំលើស្លឹកស្មៅ ហើយវានិងរងចាំសត្វគោក្របីមកស៊ីវា ។

## ២.រោគសញ្ញា :

នៅពេលដែលគោក្របីមានព្រូននេះនៅក្នុងថ្លើម នោះវាធ្វើអោយថ្លើមមានការលំបាកក្នុងការបំពេញការងារ វា ។ ដូច្នេះគោ ក្របីចុះស្គម និងធំធាត់មិនបានល្អ ។ គោក្របីនឹងឈឺពោះ ហើយស៊ីចំណីមិនបានច្រើន ។ ពេលខ្លះគោ គោ ក្របី រាគអាចម៍ ហើយពេលខ្លះទល់លាមក ។

## ៣.ការព្យាបាល :

នៅពេលដែលគោ ក្របីរបស់អ្នកនៅក្នុងភូមិចុះស្គម ហើយអ្នកសង្ស័យថាបណ្តាលមកពីព្រូន ។ សូមអ្នកប្រញាប់ ប្រញាល់ទៅហៅភ្នាក់ងារសុខភាពសត្វភូមិ អោយមកធ្វើការវិភាគដើម្បីពិនិត្យអោយបានដឹងថា តើមានព្រូន ឬព្រូនសំប៉ែតដែលបណ្តាលអោយមានបញ្ហានេះ ។ នៅពេលដែលភ្នាក់ងារសុខភាពសត្វភូមិបានដឹងអំពីប្រភេទនៃព្រូន ហើយ អ្នកអាចជ្រើសរើសយកថ្នាំមកទំលាក់ព្រូនបានយ៉ាងត្រឹមត្រូវ ។ ខាងក្រោមនេះគឺជាឈ្មោះថ្នាំដែលប្រើ សំលាប់ព្រូនសំប៉ែត គោ ក្របី ហើយថ្នាំនេះក៏អាចសំលាប់ព្រូនមូលដែរ :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១...................................... | ...................................... |
| ២...................................... | ...................................... |
| ៣...................................... | ...................................... |

*សូមកុំភ្លេចថា យើងត្រូវធ្វើការព្យាបាលទៀត បើសិនជាវាមានកើតព្រូននេះទៀត ។

*សូមចងចាំដែរថាគោ ក្របីក៏អាចចុះស្គមដោយសារ ខ្វះចំណីអាហារល្អៗ និងខ្វះទឹក ។

## ៤.ការការពារ :

មានតែមធ្យោបាយតែមួយគត់ក្នុងការការពារបញ្ហានេះគឺ ត្រូវធ្វើការទំលាក់ព្រូនគ្រប់គោ ក្របីទាំងអស់នៅ ភូមិរបស់អ្នកក្នុង១ឆ្នាំ ២ដង គឺ នៅខែតុលា និងមីនាម្តង និងក្នុងខែកញ្ញាម្តង ។

បើសិនជាបញ្ចុះព្រូនសត្វទាំងអស់នៅក្នុងភូមិរបស់អ្នកហើយ នោះវាមិនសូវមានពងព្រូននៅក្នុងលាមក និងមិន សូវមានពងនិងកូនព្រូននៅលើស្មៅ និងនៅក្នុងទឹកត្រពាំង ។

បើសិនជាអ្នកមិនបានធ្វើការទំលាក់ព្រូនទាំងនេះអស់នៅក្នុងភូមិរបស់អ្នកទេ អ្នកអាចធ្វើការទំលាក់ព្រូន របស់អ្នកក៏បាន ។ ប៉ុន្តែសត្វនោះនិងឆាប់មានព្រូននេះទៀត ។ ដូចនេះត្រូវទំលាក់ព្រូននេះម្តងទៀត ។

អ្នកគួរតែប្រាប់ម្ចាស់សត្វផ្សេងទៀតដែលរស់នៅក្នុងភូមិអ្នកអំពីព្រូននេះ ហើយជួយជំរុញអោយគេធ្វើការទំលាក់ ព្រូនសត្វរបស់គេ ជាពិសេសចំពោះកូនសត្វដែលមានអាយុក្រោម៣ឆ្នាំ ។

សូមប្រើថ្នាំដូចថ្នាំក្នុងការព្យាបាលខាងលើ ២

# ជំងឺប៉េស្តជ្រូក



ជំងឺប៉េស្តគឺជាជំងឺកាចសាហាវមួយដែលវាតែងតែកើតឡើងលើសត្វជ្រូកគ្រប់វ័យទាំងអស់ ។ ជំងឺនេះពេលចាប់ផ្តើម ឡើងដំបូងបង្អស់គឺសត្វចាប់ឈឺមានចំនួនយ៉ាងច្រើន ចំនួនងាប់ក៏ច្រើនដែរ ។

ជំងឺនេះបណ្តាលមកពីមេរោគ (វីរុស) ។ មេរោគនេះស្ថិតនៅក្នុងឈាមក្នុងទឹកនោម ក្នុងលាមក ក្នុងទឹកភ្នែក និងទឹកសំបោររបស់សត្វឈឺ ។

មេរោគនេះងាយនិងស្លាប់ដោយកំដៅព្រះអាទិត្យ ដោយកំដៅភ្លើង ហើយដោយថ្នាំរំងាប់មេរោគជាច្រើនទៀត ។ តាម ធម្មតាមេរោគនេះអាចរស់នៅក្នុងមជ្ឍដ្ឋានខាងក្រៅបានប្រហែល ២-៣ថ្ងៃ ។

### ១-ការចំលងជំងឺ :

មេរោគច្រើនតែឆ្លងពីជ្រូកមួយទៅជ្រូកមួយទៀតដោយសារការប៉ះពាល់គ្នា ដោយសារការស៊ីចំណីដែល ដោយជាមួយ មេរោគដែលបានបញ្ចេញពីសត្វឈឺតាមរយៈសំបោរ ទឹកនោម និងលាមក ។ល ។

មេរោគនេះច្រើនតែចូលទៅក្នុងខ្លួនសត្វតាមរយៈ ផ្លូវរំលាយអាហារ និងផ្លូវដង្ហើម ។

### ២-រោគសញ្ញា :

ក្នុងសភាពធ្ងន់ធ្ងរ គេសង្កេតឃើញជំងឺមានរបៀបជាពីសរាលដាលពេញខ្លួន ដោយដំបូងសត្វគ្រុនក្តៅខ្លាំង ៤ ៤១អង្សា មានសភាពទល់លាមក អស់កំលាំង មិនឃ្លានចំណី ហើយជ្រូកនៅផ្តុំគ្នាហាក់ដូចជារងាខ្លាំង ។ បន្ទាប់ ស្បែកជ្រូកឡើងពណ៌ ក្រហម ជ្រូកក្អួត និងមានពពឹកភ្នែកខាប់ ។ ជាញយ១ជ្រូកច្រើនតែដើរពាន់ជើងគ្នា និងប្រកាច់ ភាគច្រើនសត្វអាចស្លាប់ក្នុង រយៈពេល ៤-៧ថ្ងៃ ក្រោយពីចេញរោគសញ្ញា ។ សត្វខ្លះអាចស្លាប់ក្នុងរយៈពេ ១ទៅ៣ខែ ។

### ៣-ការព្យាបាល :

គ្មានថ្នាំស័ក្តិសិទ្ធសំរាប់ព្យាបាលជំងឺឡើយ ។

### ៤-ការការពារ :

-ការចាក់ថ្នាំការពារអាចការពារជំងឺនេះបាន

-ត្រូវយកសាកសពទៅកប់អោយបានល្អ

-ហាមវះសាកសពសត្វ រឺ យកសាច់មកបរិភោគ

**ប្រយ័ត្ន :**

ហាមប៉ះពាល់លើជ្រូកដែលកើតជំងឺនេះ

***********

# ជំងឺរាគរូសកូនជ្រូក



ជំងឺនេះគេសង្កេតឃើញកើតនៅលើកូនជ្រូក ដែលទើបតែនិងកើតមានអាយុ ជាងមួយអាទិត្យរហូតដល់ ៣ឬ៤ ខែ
នពិនិត្យឃើញសត្វចុះរាគខ្លាំង និងស្លេកស្លាំង ។

## ១.ការចំលងជំងឺ :

មេរោគទាំងនេះអាចឆ្លងទៅសត្វដ៏ទៃទៀត តាមលាមក ឆ្លងតាមចំណី ទឹក ឆ្លងតាមការដឹកនាំសត្វពីកន្លែងមួយទៅកាន់កន្លែងមួយផ្សេងទៀតអាចឆ្លងតាមសត្វស្លាប សត្វកណ្ដុរ ...... ដែលជាអ្នកពង្រាយមេរោគពីកន្លែងមួយទៅកន្លែងមួយទៀត ។

មេរោគនេះជាទូទៅច្រើនតែចូលទៅក្នុងខ្លួនសត្វតាមមាត់ហើយ បង្កើតកូនចៅនៅក្នុងពោះវៀនតូចដែលបណ្ដាលអោយរលាកពោះវៀននិងមានការរាគរូស ។

## ២.រោគសញ្ញា :

ជាញឹកញាប់ណាស់ចំពោះសត្វដែលឈឺខ្លាំង ច្រើនតែស្លាប់ដោយគ្មានឃើញរោគសញ្ញាអ្វីទាំងអស់និងច្រើនតែកើតលើសត្វដែលមានអាយុពី ១អាទិត្យទៅ៣ ឬ ៤ខែ ។

ជួនកាលគេសង្កេតឃើញខ្លួនសត្វឡើងក្ដៅខ្លាំងនិងមានការរាគរូស ហើយបើគ្មានទឹកផឹកទេ សត្វនិងចុះខ្សោយខ្លាំងទៅៗ ហើយស្លាប់ក្នុងរយៈពេលពី ៣ទៅ ៤ថ្ងៃ ។

## ៣.ការព្យាបាល :

ការព្យាបាលសំខាន់បំផុតគឺការបញ្ចូលសារធាតុរាវទៅក្នុងខ្លួនសត្វដូចជា : ទឹកអូរ៉ាលីត ទឹកអំបិលលាយស្ករ ទឹកដូង.. ។ យើងអាចប្រើថ្នាំវីតាមីនដើម្បីជួយកំលាំងដល់សត្វផងដែរ ។ និងត្រូវប្រើថ្នាំសំលាប់ ឬបង្អង់មេរោគបាក់តេរីដូចជា

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១......................................... | ......................................... |
| ២......................................... | ......................................... |
| ៣......................................... | ......................................... |

## ៤. ការការពារជំងឺ ៖

-ការចាក់ថ្នាំការពារ អាចការពារមេរោគបានខ្លះៗ

-ការសំអាតទ្រុងអោយបានទៀងទាត់ជាការសំខាន់ណាស់

-បង្ខាំងសត្វឈឺ អោយនៅដោយឡែកពីសត្វជា

-កូនជ្រូកដែលទើបនឹងកើតគួរតែចិញ្ចឹមវាដោយដាក់អោយដាច់ឆ្ងាយពីសត្វដែលចាស់ជាងវា ។

**********

# ជំងឺហើមសួត



ជំងឺហើមសួតកើតឡើងលើសត្វជ្រូកគ្រប់វ័យទាំងអស់ តែជាពិសេសចំពោះកូនជ្រូក ។ បើសិនជាជ្រូកមិនបាន
បាលអោយបានជាសះស្បើយឆាប់រហ័សទេនោះ សួតរបស់វានឹងត្រូវខូច ហើយជ្រូកនេះមិនអាចធំធាត់ល្អបានឡើយ
មានមេរោគ ជាច្រើនប្រភេទដែលចូលចិត្តរស់នៅក្នុងសួតសត្វជ្រូក ហើយវាអាចធ្វើអោយសួតជ្រូកហើម ។ កាល
កូនជ្រូកមានព្រូននៅ ក្នុងសួត ឬក៏រស់នៅក្នុងកន្លែងមិនស្អាតនោះជាឱកាសល្អសំរាប់មេរោគទាំងនេះចូលទៅរុករាន
សួត ។

## ១-ការចំលងជំងឺ :

មេរោគដែលធ្វើអោយសួតជ្រូកហើមនេះអាចឃើញនៅក្នុងទឹកមាត់ ឬសំបោរដែលហៀរចេញពីមាត់ និងច្រ
របស់ជ្រូកឈឺ ។ បន្ទាប់មកមេរោគទាំងនេះចូលទៅក្នុងខ្លួនជ្រូកមានសុខភាពល្អនៅពេលដែលវាទៅស៊ីចំណីផឹកទឹក ឬ
ដង្ហើមនៅជិតជ្រូកឈឺ ។ ទោះបីជ្រូកឈឺនេះមានសុខភាពល្អគ្រាន់បើឡើងវិញក៏ដោយ ក៏មានមេរោគខ្លះនៅក្នុងទឹកមា
និងសំបោររបស់ វាដែលអាចឆ្លងទៅជ្រូកផ្សេងទៀតបាន ។

## ២-រោគសញ្ញា :

ជ្រូកដែលកើតជំងឺហើមសួតនេះគេសង្កេតឃើញវាក្អក ដកដង្ហើមញាប់ និងពេលខ្លះវាគ្រុនក្តៅ និងមានហៀ
សំបោរចេញពីច្រមុះ ។ បើសិនជាសួតវាហើមខ្លាំង ជ្រូកនិងអង្គុយមួយកន្លែងហើយដកដង្ហើមដោយមានឮសំលេងខ្លាំង ។

## ៣. ការព្យាបាល :

ត្រូវអោយសត្វជាសះស្បើយឡើងវិញយ៉ាងឆាប់រហ័សគឺជាការសំខាន់បំផុត

បើសិនជាមិនប្រញាប់ធ្វើការព្យាបាល ទេ សួតវានឹងត្រូវខូចហើយជ្រូកនេះនឹងមិនអាចធំធាត់បានល្អឡើយ ។

ត្រូវព្យាបាលយ៉ាងតិច ៥ថ្ងៃ ដោយប្រើថ្នាំសំលាប់មេរោគបាក់តេរីដូចជា :

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១.......................................... | .......................................... |
| ២.......................................... | .......................................... |
| ៣.......................................... | .......................................... |

## ៤. ការការពារ :

-ការទំលាក់ព្រូនកូនជ្រូកអាចជួយការពារជំងឺហើមសួតនេះបាន

-ចិញ្ចឹមជ្រូកនៅកន្លែងស្អាត និងមានបរិយាកាសល្អ អាចជួយការពារជំងឺហើមសួតនេះបាន

-បង្ខាំងជ្រូកដែលឈឺ ( ក្អក) អោយនៅដោយឡែកដើម្បីការពារកុំអោយមេរោគឆ្លងទៅជ្រូកផ្សេងទៀត

-ការចាក់ថ្នាំការពារជំងឺសារទឹកជ្រូកអាចការពារនិងមេរោគដែលធ្វើអោយជ្រូកហើមសួតមួយប្រភេទបាន

**********

# ជំងឺតេតាណូស

ជាជំងឺដែលអាចកើតឡើងចំពោះគ្រប់សត្វ ជាពិសេសជ្រូក គោ ក្របី និង មនុស្សផងដែរ ។

## ១_ភ្នាក់ងារបង្កជំងឺ

ជំងឺនេះបង្កដោយមេរោគក្រាមវិជ្ជមានឈ្មោះ ក្លូស្ទ្រីដ្យូម តេតានី (Clostridium Tetani) ។ មេរោគ បានរាយប៉ាយស្ទើរគ្រប់ទីកន្លែងនៅក្នុងដី ជាពិសេសនៅទីលានដីស្ងួត ។ នៅខាងក្រៅខ្លួន មេរោគនេះអាចរស់នៅក្នុងដី យ៉ាងយូរ ។

## ២_ការចំលងរោគ

បាក់តេរីអាចចូលទៅក្នុងខ្លួនសត្វតាមរយៈមុខរបួស ទងផ្ចិតពិសេសក្រោយពេលកើត និង តាមរយៈមុខ រៀវ ។ ដូច្នេះនៅពេលក្រៀវជ្រូកត្រូវប្រើឧបករណ៍ដែលបានរំងាប់មេរោគ ឬស្ងោររំងាប់មេរោគរួច ។ សត្វអាចមាន តេតាណូសនៅពេលមានដំបៅជើងមុតដែកគោល ។ របួសដែលមានគ្រោះថ្នាក់ជាងគេបំផុតគឺរបួសដែលធ្វើអោយដាច់ រហែកសាច់ ។

## ៣_រោគសញ្ញា

បន្ទាប់ពីចូលទៅក្នុងខ្លួនសត្វ បាក់តេរីលូតលាស់ និងបញ្ចេញជាតិពុល ។ ជាតិពុលបាក់តេរីចូលទៅក្នុង កណ្តុររួចចូលទៅក្នុងសរសៃឈាម និងមជ្ឈមណ្ឌលប្រព័នប្រសាទ ( ខួរក្បាល និងខួរឆ្អឹងខ្នង) ។

រោគសញ្ញាលេចឡើងក្នុងរយៈពេលពី ២-៣ថ្ងៃ ទៅច្រើនអាទិត្យ ក្រោយពីមេរោគបានចូលទៅក្នុងខ្លួន ជ្រូកឈឺមានដំណើរមិនធម្មតា រឹងសាច់ដុំ រឹងខ្នង ត្រចៀកបះត្រង់ កន្ទុយត្រង់និងទីបំផុតជ្រូកដេកសណ្តូកជើងទៅក្រោយ ជំងឺនេះច្រើនតែបណ្តាលអោយសត្វងាប់ ។

## ៤_ការព្យាបាល

ជ្រូកដែលឈឺធ្ងន់ដោយជំងឺនេះពិបាកព្យាបាលអោយជាសះស្បើយណាស់ ។ យើងអាចព្យាបាលដោយប្រើ ប៉េនីស៊ីលីនហ្សេ (Pénicilline G) ក្នុងកំរិត ១លាន អ៊ុយអ៊ី សំរាប់ទំងន់ជ្រូក ៥០ គីឡូក្រាម ចាក់ ២ដង ក្នុង ១ថ្ងៃ ។

## ៤.ការការពារ

-រំងាប់មេរោគទងផ្ចិតកូនជ្រូក ដែលទើបនឹងកើតដោយប្រើថ្នាំរំងាប់មេរោគ ( តាំងតួអ៊ីយ៉ូត បេតាឌីន) ។

-ធ្វើអនាម័យ និងរំងាប់មេរោគនៅពេលគ្រៀវ

-ត្រូវលាងសំអាតមុខរបួសដោយប្រើថ្នាំរំងាប់មេរោគ និងត្រូវបើកចំហរមុខរបួស ។

# ជំងឺលាសដោះមេជ្រូក

ជំងឺនេះកើតឡើងលើដោះមេជ្រូក វាតែងតែកើតមានឡើងជាញឹកញាប់ក្រោយពេលមេជ្រូកកើតកូនរួចបានពី ១២ ទៅ៧២ម៉ោង

## ១.មូលហេតុ



កូនជ្រូកមានធ្មេញស្រួច  ពេលបៅវាខាំដោះមេវា បណ្តាលឱ្យមានរបួស ។

-មេជ្រូកខ្លះកខ្វក់ពេក ធាត់ពេក ពេលដើរចុះឡើង ដោះទាំងពីរជួរកកិតនិងដី ។

-ពេលមេជ្រូកស៊ីចំណីសំបូរជាតិសាច់ ទឹកដោះវាចេញច្រើនពេក កូនបៅមិនអស់ ទឹកដោះដែលនៅសេសសល់ក្នុងដោះបង្កលក្ខណៈងាយស្រួលឱ្យមេរោគដុះដាល ។

-មេជ្រូកមានកូនតិចជាងចំនួនដោះ កូនជ្រូកបៅមិនអស់ នាំឱ្យសល់ទឹកដោះនៅក្នុងដោះ ជាហេតុនាំឱ្យមេជ្រូកកើតជំងឺលាសដោះ ។

## ២_រោគសញ្ញា

-ដោះហើមធំ ក្រហមឡើង រឹងក្តៅ ពេលកូនបៅ ឬដើរប៉ះដី មេជ្រូកស្រែកជូនកាលធាក់កូន។

-ជ្រូកក្តៅខ្លួន (៤០-៤២អង្សា) អន់ចំណី ឬឈប់ស៊ីចំណី បើលាសដោះខ្លាំង នោះមេជ្រូកឈប់ស៊ីចំណីតែម្តង ហើយវាដេកបែរទៅជញ្ជាំងដើម្បីលាក់ដោះកុំឱ្យកូនបៅ។

-ពេលទើបលាសដោះដំបូង ទឹកដោះនៅចេញ ប៉ុន្តែវានឹងខះបន្តិចម្តងៗ គុណភាពទឹកដោះក៏ប្រែប្រួល ទឹកដោះមានលាយខ្ទុះខាប់ពណ៌លឿង ឬខៀវ ។ ក្នុងសភាពធ្ងន់ធ្ងរ នៅក្បាលដោះមានហូរចេញទឹកពណ៌លឿងលាយខ្ទុះ និងឈា

-ដោះអាចជា និងអាចបញ្ចេញទឹកដោះធម្មតាកាលណាយើងព្យាបាលទាន់ពេលវេលា។ បើទុកយូរមិនបានព្យា បាល នោះដោះនឹងឡើងរឹងនិងគ្មានទឹកដោះតែម្តង។

## ៣_ការព្យាបាល

-បើទើបលាសដោះដំបូង យកទឹកកកសង្កត់លុញចុះលុញឡើងលើដោះដើម្បីកុំឱ្យហើមធំ។ ប្រសិនបើយើងដឹ តាំងពីដំបូងហើយយើងយកទឹកកកលុញសង្កត់លើដោះឱ្យបានច្រើនដង នោះដោះនឹងលែងហើមហើយ។

-ប៉ុន្តែបើដោះហើមធំ ក្តៅ និងឈឺទៅហើយ គេត្រូវប្រើទឹកក្តៅបាញ់ដាក់ដោះ ឬយកកន្សែងជ្រលក់ទឹកក្តៅ ដោះមួយថ្ងៃ២-៣ដង ម្តងពី២០-៣០នាទី។ យើងអាចយកប្រេងកូឡាលាបដោះក៏បានដែរ។

-មិនត្រូវឱ្យកូនជ្រូកបៅដោះដែលលាសនោះទេ ផ្ទុយទៅវិញត្រូវច្របាច់ទឹកដោះដាក់ក្នុងចានរួចចាក់ចោល មួយថ្ងៃច្របាច់ ៣-៤ដង។ ពេលច្របាច់ម្តងៗ ត្រូវច្របាច់ឱ្យអស់។

-ចាក់តេរ៉ាវើត អុកស៊ីតែត អុកស៊ីគ្លីន (មើលក្រដាសប្រើប្រាស់ថ្នាំ) ។

## ៤_វិធីបង្ការ

-មួយអាទិត្យមុនពេលកើតកូន ត្រូវបន្ថយចំណីដែលសំបូរជាតិសាច់ និង ២ថ្ងៃមុនពេលកើតត្រូវបន្ថយចំណីវា ឱ្យទឹកវាផឹកអោយបានច្រើន និងផ្តល់បន្លែមនូវបន្លែស្រស់ដើម្បីជួយក្នុងការរំលាយអាហារ ដើម្បីកុំឱ្យបាក់តេរីដុះដាលច្រើ ពេកក្នុងពោះវៀន។

-ក្រោយពេលកើតកូនអស់ ត្រូវលាងសំអាតដោះទាំងពីរជួរ និងខ្លួនជ្រូកភាគខាងក្រោយជាមួយទឹកក្តៅឧណ្ហ និងសាប៊ូ។

-ចំពោះមេជ្រូកដែលមានកូនតិចជាងចំនួនដោះ ត្រូវឱ្យកូនជ្រូកបៅអោយបានគ្រប់ដោះ បើទឹកដោះច្រើន ត្រូវច្របាច់ចោល។

-កូនជ្រូកដែលកើតមក ត្រូវកាត់ធ្មេញភ្លាម ។

-ត្រូវសំអាតទ្រុងជាប្រចាំទាំងព្រឹក និងល្ងាច

-ចាក់អុកស៊ីតេត្រាស៊ីគ្លីន ១ម្ជុលមុនពេលកើត៣ថ្ងៃ និងចាក់ម្តងទៀតនៅប៉ុន្មានម៉ោងក្រោយពេលកើតរួច ដើម្បីប្រឆាំងនឹងការបង្កជំងឺ ។

## រូបបំព្រួញពីការរាតត្បាតនៃមេរោគលាសដោះ



តាមរយៈរូបបំព្រួញខាងលើនេះ យើងអាចនិយាយបានថា :

១-មេរោគធ្វើដំណើរចេញពីពោះវៀន ទៅកាន់កន្សោមដោះ

២- មេរោគធ្វើដំណើរចេញពីតំរងនោម ទៅកាន់កន្សោមដោះ

៣- មេរោគអាចធ្វើការឆ្លងចូលទៅកាន់ដោះ តាមរយៈលាមកដែលមានបាក់តេរីកូលី

៤- មេរោគនៅជុំវិញខ្លួនសត្វ អាចចូលទៅក្នុងកន្សោមដោះមេជ្រូក ពេលមានរបួស

# ជំងឺចុងអង្ករជ្រូក និងមនុស្ស



ចុងអង្ករក្នុងសាច់ជ្រូក គឺជាកូនព្រូនសំប៉ែតតូចៗ ដែលវាកំពុងរង់ចាំអោយមនុស្សបរិភោគវា ។ នៅពេលមនុ បរិភោគសាច់ជ្រូកដែលមានចុងអង្ករនេះទៅ កូនព្រូននេះនឹងធ្វើការលូតលាស់ក្លាយជាព្រូនសំប៉ែត យ៉ាងវែងរស់នៅ ពោះវៀនរបស់មនុស្ស ។ ព្រូននេះមានគ្រោះថ្នាក់ណាស់ចំពោះមនុស្ស ព្រោះវាអាចធ្វើអោយមនុស្សស្លាប់បាន ។

## ១. ការចំលង :

នៅពេលដែលមនុស្សស៊ីសាច់ជ្រូកដែលមានកូនព្រូនខ្លះៗ (មើលទៅឃើញសៗតូចដូចចុងអង្ករ) កូនព្រូននេះ លូតលាស់ក្លាយជាព្រូនសំប៉ែតវែង ហើយធ្វើចលនាក្នុងពោះវៀនតូចរបស់មនុស្ស ។ព្រូនសំប៉ែតនេះនឹងបង្កើ ហើយពងនេះ ចេញមកក្រៅតាមលាមក ។ នៅពេលដែលជ្រូកស៊ីលាមកនោះ ពងព្រូននេះនឹងញាស់នៅក្នុងពោះ តូចរបស់ជ្រូក ។ កូនព្រូនដែលញាស់មកនេះធ្វើដំណើរទៅកាន់កន្លែងផ្សេងៗនៃខ្លួនជ្រូក ។ កូនព្រូននេះមើលទៅហាក់ ជាចុងអង្ករ ហេតុនេះហើយបានជាភាសាខ្មែរយើងហៅថា ចុងអង្ករ ។ កូនព្រូនទាំងនេះរស់នៅបានយ៉ាងយូរនៅ ខ្លួនជ្រូក គឺជាពេលដែលវារង់ចាំអោយ មនុស្សមកបរិភោគ ។

## ២.រោគសញ្ញាចំពោះជ្រូក :

នៅពេលដែលកូនព្រូនធ្វើចលនាទៅកាន់ផ្នែកផ្សេងៗនៃខ្លួនជ្រូក វាធ្វើអោយជ្រូកមានការឈឺចាប់បន្តិចបន្តួច ។ ហេតុនេះហើយធ្វើអោយជ្រូកមិនសប្បាយចិត្ត ។

## ៣.រោគសញ្ញាចំពោះមនុស្ស :

នៅពេលដែលព្រូននេះធំពេញវ័យ ហើយបានរស់នៅក្នុងពោះវៀនតូចរបស់មនុស្ស វាធ្វើអោយអ្នកនោះចុះស្គម ហើយ ឈឺពោះ ។ ពេលខ្លះពងរបស់វានោះអាចញាស់នៅក្នុងពោះវៀនមនុស្ស ហើយកូនព្រូននេះនឹងធ្វើដំណើរទៅកាន់ផ្នែកផ្សេងៗ នៃខ្លួនមនុស្ស ។ ក្នុងករណីនេះវាធ្វើអោយមានគ្រោះថ្នាក់ណាស់ ព្រោះពេលខ្លះកូនព្រូននេះ វាធ្វើដំណើរទៅនៅក្នុងខួរក្បាល ដែលអាចធ្វើអោយមនុស្សប្រកាច់ ឬស្លាប់ ។

## ៤.ការព្យាបាលចំពោះជ្រូក :

គ្មានថ្នាំសំរាប់សំលាប់កូនព្រូន (ចុងអង្ករ) ដែលរស់នៅក្នុងខ្លួនជ្រូកបានឡើយ ។ ដូចនេះកត្តាសំខាន់បំផុតនោះគឺការការពារកុំអោយពងវាចូលទៅនៅក្នុងខ្លួនជ្រូក ។

## ៥.ការព្យាបាលចំពោះមនុស្ស :

បើសិនជាអ្នកគិតថា អ្នកប្រហែលជាមានព្រូននៅក្នុងពោះវៀនរបស់អ្នក ។ អ្នកគួរតែទៅឱសថស្ថានដើម្បីទិញថ្នាំមកធ្វើការទំលាក់ព្រូននេះចេញ ។ តែសូមលេបអោយត្រូវតាមក៏រិតនៃការប្រើប្រាស់របស់ថ្នាំនោះ ។

## ៦.ការការពារ :

-ដើម្បីការពារកុំអោយមានកូនព្រូន (ចុងអង្ករ ) មាននៅក្នុងខ្លួនជ្រូក គឺត្រូវធ្វើយ៉ាងណាកុំអោយជ្រូកទៅស៊ីលាមករបស់មនុស្សអោយសោះ ។

-ដើម្បីការពារកុំអោយមានព្រូននេះចូលទៅនៅក្នុងពោះវៀនមនុស្ស គឺត្រូវចំអិនសាច់ជ្រូកអោយបានឆ្អិនល្អមុនពេលបរិភោគ ព្រោះកំដៅនេះវាអាចសំលាប់កូនព្រូនទាំងអស់ដែលមាននៅក្នុងសាច់ជ្រូក ។

# ព្រូនមូលរបស់ជ្រូក



មានព្រូនមូលជាច្រើនប្រភេទដែលចូលចិត្តរស់នៅក្នុងខ្លួនជ្រូក ។ ព្រូនខ្លះវាមានប្រវែងវែងពណ៌សប្រហ ប្រហែល និងព្រូនមូលធំរបស់កូនក្របី តែវាមិនដូចគ្នានោះទេ ។ ព្រូនខ្លះវាមានរាងតូចៗ ប្រហាក់ប្រហែលព្រូនរបស់ ក្របី តែវាមិនដូចគ្នាទេ ។ ព្រូនទាំងនេះវាធ្វើអោយជ្រូកឈឺ និងស្គមហើយធំធាត់យឺត ជាពិសេសចំពោះកូនជ្រូក ។

## ១_ការចំលង :

ស៊ុតព្រូន និងកូនព្រូនវារស់នៅលើដីដែលជាកន្លែងជ្រូករស់នៅ ។ នៅពេលជ្រូកឈ្លូសដីរកស៊ីជន្លេន ឬសត្វ ផ្សេងៗ វាតែងតែដោយស៊ុតព្រូនខ្លះទៅជាមួយ ស៊ុតនេះវានឹងញាស់នៅក្នុងពោះវៀនតូច ហើយកូនព្រូនវាធ្វើដំណើរ ឈាមទៅកាន់សរីរាង្គផ្សេងៗនៃខ្លួនជ្រូកតាមកន្លែងដែលវាចង់រស់នៅ ។ ប្រភេទព្រូនខ្លះវាចូលចិត្តទៅរស់នៅក្នុង ខ្លះទៀតចូលចិត្តរស់នៅក្នុងពោះវៀនតូច ខ្លះចូលចិត្តរស់នៅក្នុងពោះវៀនធំ ។ ព្រូនទាំងនេះវានឹងបង្កើតស៊ុតរប ហើយស៊ុតទាំងនេះនឹងចេញមកក្រៅតាមលាមកជ្រូក ។ ដូចនេះមានស៊ុតព្រូនពាសពេញកន្លែងដែលជ្រូករស់នៅ និងក ដែលជ្រូកជុះអាចម៍ដាក់ ។

## ២.រោគសញ្ញា :

នៅពេលដែលព្រូនចូលទៅក្នុងសួតជ្រូក វាបានធ្វើអោយជ្រូកក្អក ហើយធ្វើអោយសួតមានការលំបាកក្នុងការបំពេញការងាររបស់វា ។ ម្យ៉ាងទៀតវាធ្វើអោយមានការងាយស្រួលដល់មេរោគផ្សេងទៀតចូលទៅរុករាន ក្នុងសួតជ្រូកនោះ ។ នៅពេលដែលព្រូនវាចូលទៅក្នុងពោះវៀនតូច វាធ្វើអោយពោះវៀនតូចមានការលំបាកក្នុងការបំពេញការងាររបស់វា ។ ដូច្នេះវាធ្វើអោយសត្វចុះស្គម និងមានការរីកធំធាត់ឃើត ។ ព្រូនអាចធ្វើអោយជ្រូកខ្លះឃ្លានចំណីខ្លាំង ហើយខ្លះមិនចង់ ស៊ីចំណី និងខ្លះ រាគអាចម៍ និងខ្លះទៀតអាចក្តៀនអាចម៍ ។ កូនជ្រូកនៅពេលដែលមានព្រូនធំៗច្រើនក្នុងពោះវៀនតូចវា ធ្វើអោយមានហើម ពោះជ្រូកដែលមានព្រូននៅក្នុងខ្លួន មើលទៅហាក់ដូចជាមានសុខភាពមិនល្អឡើយ ។

## ៣.ការព្យាបាល :

នៅពេលកូនជ្រូកចុះស្គម និងមានការលូតលាស់ ឬធំធាត់យឺតដែលសង្ស័យថាបណ្តាលមកពីមានព្រូននៅក្នុងពោះវៀនវា ។ អ្នកគួរតែប្រើថ្នាំសំលាប់ព្រូនដើម្បីទំលាក់វាចេញ ។ នៅពេលដែលកូនជ្រូកក្អក ហើយសង្ស័យថាវាបណ្តាលមកពីមានកូនព្រូន និងមានមេរោគនៅក្នុងសួត ។ ដូច្នេះអ្នកគួរតែប្រើថ្នាំសំលាប់ព្រូន និងថ្នាំសំលាប់មេរោគ ។

ខាងក្រោមនេះគឺជាថ្នាំសំលាប់ព្រូនមូលជ្រូក

| ឈ្មោះថ្នាំ | កំរិតនៃការប្រើប្រាស់ |
|---|---|
| ១.......................................... | .......................................... |
| ២.......................................... | .......................................... |
| ៣.......................................... | .......................................... |

※ សូមកុំភ្លេចថា បើចិញ្ចឹមជ្រូកដោយអោយវាដើរស៊ីពាសវាលពាសកាលតាមតែចិត្តវា នោះវានឹងឆាប់មានព្រូននៅក្នុងខ្លួនរបស់វា ។ បើសិនជាអ្នកចិញ្ចឹមជ្រូកនៅលើដីដោយដាក់ទ្រុង ឬចងវាមិនអោយដើររកស៊ីពាសវាលពាសកាល ហើយអ្នក អាចផ្លាស់កន្លែងវាអោយទៅនៅកន្លែងស្អាត បន្ទាប់មកធ្វើការទំលាក់ព្រូនអោយវានោះ ជ្រូកអ្នកនឹងមិនអាចមានព្រូនឡើយ ។

※ សូមចងចាំដែរថាជ្រូកក៏អាចចុះស្គមដោយសារ ខ្វះចំណីល្អៗ និងខ្វះទឹក ។

### ៤_ការការពារ :

មានមធ្យោបាយតែមួយគត់ក្នុងការការពារបញ្ហាដែលបង្កឡើងដោយសារព្រូននេះ គឺត្រូវធ្វើការទំលាក់ព្រូ ដោយប្រើថ្នាំដូចបានប្រាប់ខាងលើ ។

❋ បើសិនជាអ្នកចិញ្ចឹមជ្រូកនៅលើដី អ្នកគួរតែមានកម្មវិធីទំលាក់ព្រូនដូចខាងក្រោមនេះ

-ពេលផ្តាច់ដោះម្តង

-បន្ទាប់មក ១ខែម្តងរហូតដល់ជ្រូកមានអាយុ ៦ខែ

-និងបន្ទាប់មក ២ខែម្តង

❋ បើសិនជាអ្នកចិញ្ចឹមជ្រូក នៅលើក្តារ ឬស៊ីម៉ង់ត៍ អ្នកគួរតែមានកម្មវិធីទំលាក់ព្រូនដូចខាងក្រោមនេះ

- ពេលផ្តាច់ដោះម្តង

-និងម្តងទៀតក្រោយពេលផ្តាច់ដោះ១ខែ

❋ ចំពោះជ្រូកមេ ត្រូវទំលាក់ព្រូន២អាទិត្យមុនពេលកើតកូន ។

✍ ត្រូវចងចាំថា រាល់ពេលដែលអ្នកទំលាក់ព្រូនជ្រូក អ្នកគួរតែផ្លាស់វាទៅចិញ្ចឹមនៅកន្លែងស្អាតល្អ ។អ្នកគួរ ប្រាប់ម្ចាស់សត្វផ្សេងទៀតនៅក្នុងភូមិអំពីព្រូននេះ ហើយជួយជំរុញអោយគេធ្វើការទំលាក់ព្រូនសត្វរបស់គេផង ជាពិសេស ចំពោះកូនសត្វ ។

☞ សូមប្រើថ្នាំដូចថ្នាំក្នុងការព្យាបាលខាងលើ ។

# ជំងឺញូវកាស

### ១_ភ្នាក់ងារ :

ជំងឺញូវកាស ជាជំងឺមួយដែលបង្កឡើងដោយវីរុស ។ មានលក្ខណៈកាចសាហាវចំពោះមាន់ ។ វីរុសចូលចិត្ត នៅក្នុងខ្លួនសត្វ និងក្នុងខ្យល់ ។

ជំងឺកើតមានតែនៅលើសត្វមាន់ ហើយភាគច្រើនកើតក្នុងកំឡុងខែកុម្ភៈ ដល់ខែ ឧសភា ។

### ២_ការឆ្លងរាលដាល :

ឆ្លងតាមខ្យល់ លាមក ទឹក ចំណី និងនាំចំលងដោយសត្វផ្សេងៗដូចជា សត្វព្រៃ ទា ជ្រូក ឬមនុ និងឆ្លងពីសត្វមួយទៅសត្វមួយ តាមការក្អក កណ្តាស់របស់សត្វឈឺ ។

## ៣. រោគសញ្ញា :

ជំងឺនេះអាចបង្កើតរោគសញ្ញាពយ៉ាង :

- នៅប្រព័ន្ធដកដង្ហើម :

-ស្លេះនៅជុំវិញរន្ធច្រមុះ

-ចំពុះហា ពិបាកដកដង្ហើម

-ភ្នែកហើម និងហូរទឹកភ្នែក

-សិរពណ៌ខៀវ

- នៅប្រព័ន្ធរំលាយអាហារ :

-ភាគពណ៌បៃតង

-មានឈាមនៅក្លូអាក់

- នៅប្រព័ន្ធសរសៃប្រសាទ :

-ប្រទាញក្បាល "រមួលក" ដំណើរធីងធោងខុសធម្មតា

-សត្វខ្វិន

ឈឺលើសត្វគ្រប់វ័យ ។ អត្រាឈឺមានដល់១០០ភាគរយ អត្រាស្លាប់មានពី ៥០-១០០ភាគរយ ។ ថយចំនួនពង

ង មានលក្ខណៈមិនធម្មតា ។

## ៤. ការវះកាត់សាកសពសត្វពិនិត្យ :

ពេលវះសាកសពសត្វគេ សង្កេតឃើញមានស្នាមដូចខាងក្រោម

-មានការហូរឈាម និងរលាកនៅតាមប្រព័ន្ធដកដង្ហើមនិងមានសំបោរ "ស្លេស្ម" នៅក្នុងបំពង់ខ្យល់

-មានការហូរឈាមនៅក្រពេញកូនកណ្តុរនៃពោះវៀន ។

-មានស្នាមក្រហមអុច១នៅផ្លូវរំលាយអាហារ ពិសេសនៅ **ខេចកោះ** និង **ក្លូអាក់** ។

-ផាលតែងតែរីកធំ




**៥.ការព្យាបាល :**

-គ្មានថ្នាំព្យាបាល

**៦ការការពារ :**

-អនាម័យក្នុងការចិញ្ចឹមមាន់

-ការចាក់ថ្នាំការពារ

- ចាក់តែសត្វមានសុខភាពល្អ
- លើកទី១ បន្តក់នៅលើភ្នែក ឬ ច្រមុះ
- លើកទី២ រំលឹកនៅ ៣អាទិត្យក្រោយ
- លើកទី៣ ពេលវាអាយុបាន ៣ខែ

**៧.ការណែនាំ :**

អនុវត្តកម្មវិធីចាក់ថ្នាំការពារ គឺបន្តក់លើកទី១ នៅខែតុលា និងលើកទី២ នៅខែវិច្ឆិកា និងលើកទី៣ ជូសស្លាប ពេលវាអាយុបាន៣ខែ ។



# ជំងឺអាសន្នរោគបក្សី
# FOWL CHOLERA



គឺជាជំងឺដែលកើតឡើងចំពោះសត្វមាន់ មាន់ដាំងដុង មាន់បារាំង ក្ងាន និងទា ។ វាកើតចំពោះតែសត្វពេញវ័យទេ ។ វាកើតឡើងនៅដើមរដូវប្រាំង រួចបាត់ទៅវិញនៅរដូវក្តៅ ។

## ១-ភ្នាក់ងារ :

ជាជំងឺបង្កឡើងដោយបាត់តេរី ។ បាក់តេរីចូលចិត្តរស់នៅក្នុងខ្លួនសត្វ និងទឹក ។

## ២-ការឆ្លងរាលដាល :

ឆ្លងពីបក្សីមួយទៅមួយទៀត តាមទឹក ឬចំណី ឬ ឧបករណ៍ដែលមានជាប់ទៅដោយបាក់តេរី ។ សត្វជាពីឈឺ ជ្រូក ឆ្កែ និងពពួកសត្វកកេរ ក៏ជាភ្នាក់ងារចំលងមួយដែរ ។ បាក់តេរីជ្រៀតចូលទៅក្នុងខ្លួនសត្វតាមច្រមុះ មាត់ ភ្នែក និងរបួស ។ ឈឺ លើគ្រប់ពពួកបក្សី ពិសេសមាន់ និងទា ។

## ៣-រោគសញ្ញា :

អត្រាឈឺមានរហូតដល់ ៦០ភាគរយ ។ អត្រាស្លាប់មានរហូតដល់ ៥០ភាគរយ ។ ភាគច្រើនឈឺលើមាន់អាយុច្រើនជាង៤ខែ ។ រោគសញ្ញាអាចមានទម្រង់ជារលាកសួត ។

រយៈពេលសំងំរបស់ជំងឺមានរយៈពេលខ្លី ( ពី ៣ ទៅ ៩ថ្ងៃ )

ការវិវត្តន៍មានសភាពស្រួចស្រាវបំផុត ឬក្នុងទំរង់ស្រួចស្រាវ ឬក្នុងទំរង់រ៉ាំរ៉ៃ

- **ទំរង់ស្រួចស្រាវបំផុត :** មានរយៈពេល ២ ឬ ៣ម៉ោង ។ សត្វកើតជំងឺនេះ ឈប់ស៊ីភ្លាមមួយរំពេច នៅស្ងៀម ដួលហើយស្លាប់ក្រោយពីប្រកាច់ ។ សត្វនៅគៀនក្រលៀតដាច់ពីគេ ហើយវាសិកក្បាលទៅក្រោមស្លាប ក្បាលធ្លាក់សំយ៉ុងចុះ និងបះរោមស្លាប ។ សិរ ណង់ និងស្បែក តែងមានពណ៌ស្វាយ និងមានហូរទឹករំអិលខាប់អន្តាយចេញពីមាត់ ។ គេឃើញសត្វងាប់នៅពេលព្រឹក ដែលពីថ្ងៃមុនមានសុខភាពល្អសោះ ។
- **ទំរង់ស្រួចស្រាវ :** មានរយៈពេលពី ២ ទៅ ៨ថ្ងៃ ។ សត្វគ្រុន អស់កំលាំង សំកុកនៅគៀនជញ្ជាំងជួនកាលវាហាក់ ដូចជាភ្ញាក់ពីដេក ដំណើរទ្រេតទ្រោត សត្វស្រេកទឹក ។ ការដកដង្ហើមញាប់ និងមានបញ្ចេញសម្លេង សិរក្រហមជាំ ពណ៌ប្រផេះលឿង រួចបែតងខ្ចី ចុងក្រោយមានពណ៌ក្រហមព្រឿងៗ

លាយឈាមធ្វើឱ្យសត្វអស់កំលាំងយ៉ាងខ្លាំង ។ ចំពុះ សត្វហាក់ដូចជាសណ្តក ជូនកាលក្បាល ក និង ស្លា
រមួលតែវ៉ៃ សត្វដួលហើយស្លាប់ ជំងឺនេះកំរជាណាស់ ។

- **ទំរង់រ៉ាំរ៉ៃ :** កើតមានបន្តពីទំរង់ស្រួចស្រាល សត្វនៅតែរាគ ស្គម សិរស្លេកហើយទ្រុត ជូនកាលបង្ហាញនូវពោះ
រលាកសន្លាក់ អាប់សែល (បូស) ចុងបញ្ចប់សត្វសន្លប់ ។

## ៤. ការវះសាកសពពិនិត្យ :

-មានការចេញឈាម : នៅក្នុងសាច់ដុំ និងក្នុងប្រហោងពោះ

-ថ្លើម : មានតំបន់ឆ្នូត១ភ្លឺថ្លា មានស្នាមតូច១

## ៥. ការព្យាបាល :

នៅពេលដែលជំងឺលេចឡើងនៅក្នុងកន្លែងចិញ្ចឹមសត្វ ត្រូវចាប់ផ្តើមធ្វើការសំអាត់កន្លែងរស់នៅរបស់សត្វ ប្រសិន បើមានសត្វស្លាប់ច្រើន (៥០០ ទៅ ១០០០ក្បាល) ជាការចាំបាច់ត្រូវធ្វើការសំលាប់មេរោគ ត្រូវធ្វើការព្យាបាលសត្វ ទាំងអស់ដែលចិញ្ចឹម ទាំងឈឺ ទាំងជា :

- **ចំពោះសត្វជា :**

  ប្រើតេត្រាស៊ីគ្លីន (Tetracyclin 250mg) ១គ្រាប់សំរាប់មាន់៥ក្បាល ឬ

  បេតាមីស៊ីន (Betamycine powder) លាយទឹកឱ្យផឹកចំនួន ៥ថ្ងៃ

- **ចំពោះសត្វឈឺ :**

  ប្រើអុកស៊ីតែត (Qxytet) ០.២ ម.ល សំរាប់ទំងន់ ១គក្រ ឬ

  បេតាមីស៊ីន (Betamycine powder) លាយទឹកឱ្យផឹកចំនួន ៥ថ្ងៃ

## ៦.ការការពារ :

-អនាម័យ

-ការចាក់ថ្នាំការពារ : មាន់ និងទា អាយុ ១០អាទិត្យ និងចាក់រលឹករាល់ ៦ខែម្តង

ដុតសាកសពមាន់ដែលងាប់ដោយជំងឺនេះចោល ។



# ជំងឺសាល់ម៉ូណែឡូសបក្សី
## SALMONELLOSIS

### ១-ភ្នាក់ងារ :

ជាជំងឺបង្កឡើងដោយបាត់តេរី ។ បាក់តេរីចូលចិត្តរស់នៅក្នុងខ្លួនសត្វ ទឹក និងស៊ុត ។

### ២-ការឆ្លងរាលដាល :

ឈឺលើគ្រប់ប្រភេទបក្សី ។ ឆ្លងតាមរយៈចំណី ទឹកមិនស្អាត ឬការប៉ះពាល់ឧករណ៍ប្រើប្រាស់ដែលប្រឡាក់ ទៅដោយមេរោគ ឬលាមក សាច់សាកសពសត្វឈឺ ។ សត្វជាពីឈឺ ឬកូនមាន់ដែលទើបតែញាស់ពីពងដែលមានមេរោគ អាចជាអ្នកផ្ទុកមេរោគ ។ បាក់តេរីចូលទៅក្នុងខ្លួនសត្វតាមមាត់ ។

### ៣-រោគសញ្ញា :

អត្រាមាន់ឈឺមានរហូតដល់ទៅ៥០ភាគរយ ។ អត្រាស្លាប់មានរហូតដល់ទៅ ៤០ភាគរយ ច្រើនឈឺលើកូន មាន់អាយុតិចជាង ៣អាទិត្យ មានរោគសញ្ញាដូចជាមាន់សំកុក ឈប់ស៊ីចំណី រាគពណ៌លឿងបែក រោមបះ សិរ និងណង់ មានពណ៌ក្រម៉ៅ ។

- **ទំរង់ស្រួចស្រាវ :**

ឃើញងាប់បន្ទាប់ពីញាស់ និងបន្តងាប់រហូតដល់ ៣-៤អាទិត្យ ។ អត្រាងាប់មានពី ២០-៣០ភាគរយ មាន់សំកុករោម បះ ខ្សោយ រាគស ពិបាកដកដង្ហើម ។





- **ទំរង់រ៉ាំរ៉ៃ :**

ច្រើនឃើញលើបក្សីដែលមានអាយុ ៣-៨អាទិត្យ ។ ដើរខ្ញើច១ ហើមនៅសន្លាក់ជើង រោមដុះមិនល្អ មិនស៊ីចំណី ស្លេកស្លូតលាស់យឺត សិរស្លេកស្លាំង ។

## ៤.ការវះសាកសពសត្វពិនិត្យ :

- ចំពោះមាន់ធំ : ឃើញថ្លើមរីកធំ និងមានហូរឈាម ។ សួត ថ្នក់ពោះវៀន បេះដូង ក៏មានការរលាក និងហូរឈាមដែរ ។ អូវែមានសភាពមិនធម្មតា ។
- ចំពោះកូនមាន់ :ឃើញមានការរលាកនៅស្រោមពោះ នៅមានពងលឿង "ក្នុងពោះកូនមាន់"

## ៥.ការព្យាបាល :

-អង់ទីប៊ីយោទិច

-សិបតូទ្រីល (Septotryl) ឬអាល់ហ្វាទ្រីម (Alfatrim)

-ស៊ុលហ្វាមីត (Sulfamide) លាយជាមួយទឹក រយៈពេល ៥ថ្ងៃ

## ៦.ការការពារ :

-អនាម័យ

# ជំងឺអុតបក្សី
## FOWL POX

### ១. ភ្នាក់ងារ :

ជំងឺនេះ បណ្តាលមកពី វីរុស ។ វាចូលចិត្តរស់នៅលើខ្លួនសត្វ នៅដី និងសត្វមូស ។ ជំងឺឈឺលើមាន់ គ្រប់ ជាពិសេសកូនមាន់ ព្រាប និងជូនកាល ទា ក៏ឈឺជំងឺនេះដែរ ។ ពូជមាន់ក្នុងស្រុកអាចមានសភាពធន់នឹងជំងឺនេះ ជាង នាំចូលពីបរទេស ។

### ២. ការឆ្លងរាលដាល :

ឆ្លងតាមការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ឬឧករណ៍ដែលប្រឡាក់ប្រឡូកទៅដោយវីរុសអស់នោះ ។ នេះមូស ដង្កៅ ចៃ ក៏អាចជាភ្នាក់ងារចំលងមួយដែរ ។ វីរុសជ្រៀតចូលទៅក្នុងខ្លួនសត្វតាមមាត់ ភ្នែក ឬស្បែក របួស ។

### ៣. រោគសញ្ញា :

បើជំងឺស្ថិតនៅក្នុងសភាពស្រួចស្រាវ មាន់ងាប់ក្នុងថ្ងៃដំបូង ។ បើក្នុងសភាពរ៉ាំរ៉ៃ មាន់អាចស្លាប់នៅក្នុង អា ទី២ ឬ អាទិត្យទី៤ ។

អត្រាមាន់ឈឺមានដល់ ២៥ភាគរយ ។អត្រាស្លាប់អាចឡើងរហូតដល់ ៥០ភាគរយ "ជាពិសេសកូនមាន់"

- ក្នុងសភាពស្រួចស្រាវ :

-មានអុតកំពឹកកំពកទៅលើសិរ ត្របកភ្នែក និងគែមចំពុះ ។



-ករណើឈឺខ្លាំងអាចកើតលើជើង និងលើស្បែកដងខ្លួនដែរ ។ អុតនេះមានពណ៌សតូចៗ ឬពងទឹកថ្លា រួច រីកធំពណ៌ត្នោត ឬប្រផេះ ឬក៏មានដុំបន្ទះសតូចនៅគែមចំពុះ លើអណ្តាត ឬក្នុង មាត់ ។

-ពេលខ្លះរន្ធច្រមុះត្រូវបិទជិត ដោយសារអុត ធ្វើឱ្យសត្វពិបាកដកដង្ហើម

-កូនមាន់តូចៗចុះខ្សោយ មិនចង់ធ្វើចលនា

- ក្នុងសភាពរ៉ាំរ៉ៃ :

-មានអុតខ្លះនៅលើភ្នាសស្តើង

-មាន់មានរាគ

## ៤.ការវះកាត់សាកសពសត្វពិនិត្យ

- ក្នុងសភាពស្រួចស្រាវ :

-សាច់ដុំភ្នាសស្តើងកើតអុត មានពណ៌ក្រម៉ៅ

-មានចំណុចសនៅក្នុងមាត់ ក្រោមអណ្តាត បំពង់ខ្យល់ បំពង់ក ដែលបន្ទាប់មកប្រែទៅជាពណ៌ លឿង រឹង ។

- ក្នុងសភាពរ៉ាំរ៉ៃ :

-ថ្លើម បេះដូង តំរងនោមមានសភាពស្លេកស្លាំង

## ៥.ការព្យាបាល :

☞ គ្មានថ្នាំព្យាបាល

ប៉ុន្តែយើងត្រូវបេះអ៊ុត និងលាងកន្លែងនោះដោយប្រើ

-បេតាឌីន (Betadine) ឬអាល់កុល

-បេតាមីស៊ីន (Betamycine)

## ៦.ការការពារ :

-ចាក់វ៉ាក់សាំង លើមាន់ចាប់ពីអាយុ ១ថ្ងៃឡើងទៅ

-ចាក់ក្នុងពេលជាមួយគ្នា ដោយបន្តក់វ៉ាក់សាំងញូវកាស

-ចាក់តែមាន់មានសុខភាពល្អ

-ពេលមានជំងឺចាប់ផ្តើមផ្ទុះ យើងចាក់តែមាន់ណាដែលមិនបង្ហាញរោគសញ្ញា

-សត្វដែលជាពីឈឺមានភាពស៊ាំមួយរយៈ

-បំបែកមាន់ឈឺពីមាន់ជា ដុតសាកសពមាន់ចោល ។

# ជំងឺកុកស៊ីឌីយ៉ូស៊ីសបក្សី
# COCCIDIOSIS

## ១. ភ្នាក់ងារ :

ជំងឺនេះធ្វើឱ្យឈឺមាន់ ទា ។ ជំងឺនេះគឺបណ្តាលមកពីពពួក ប្រូតូសូអ៊ែរ ។ វារស់នៅក្នុងដី និងនៅក្នុងពោះវៀន របស់សត្វ ។

បក្សីគ្រប់វ័យអាចទទួលជំងឺនេះ ជាពិសេសកូនបក្សីងាយទទួលជំងឺនេះជាងសត្វបក្សីចាស់ ព្រោះភាពស៊ាំទល់នឹងជំងឺរបស់សត្វចាស់ មានលក្ខណៈខ្លាំងជាងកូនសត្វ ។

ជំងឺនេះច្រើនកើតឡើងនៅរដូវភ្លៀង ។ អត្រាឈឺ និងអត្រាស្លាប់មានកំរិតខ្ពស់ ។ ដំណើរវិវត្តន៍នៃជំងឺអាចមានសភាពពី ២-២១ថ្ងៃ ។

## ២. ការឆ្លងរាលដាល :

មេរោគចូលទៅក្នុងខ្លួនសត្វតាមមាត់ តាមរយៈការស៊ីចំណី និងផឹកទឹក ឬឆ្លងតាមរយៈសត្វល្អិត ឬដោយសារ ឧបករណ៍ប្រើប្រាស់ ដែលមានមេរោគនេះ ។ រយៈពេលបង្កជំងឺមានពី ៤-៥ថ្ងៃ ។

សត្វជាអាចឆ្លងជំងឺនេះ ដោយសារលាមករបស់សត្វឈឺ ឬក៏ដីដែលបានប្រឡាក់ទៅដោយលាមកសត្វឈឺ ។

## ៣. រោគសញ្ញា :

រោគសញ្ញាសំខាន់ៗ គឺស្គម ល្ងើយកន្តើយ ស្លាបមិនរាបស្មើ នៅផ្តុំគ្នា មានការលូតលាស់យឺត លាមកមានឈាម ឬ សំបោរ ឬលាមកមានសភាពជាទឹក ។

## ៤. ការវះសាកសពសត្វពិនិត្យ :

ដំណាក់កាលឈឺដំបូង មានចំណុចក្រហមនៅថ្នក់ពោះវៀន ថ្នក់ពោះវៀនរីកធំមានឈាមកក ។ មានចំណុចពណ៌សនៅលើភ្នាសខាងក្រៅនៃពោះវៀន និងចំណុចពណ៌ក្រហមនៅលើភ្នាសខាងក្នុងនៃពោះវៀន។ នៅខាងក្នុងពោះវៀន មាន ឈាម និងខ្យល់ ។ ជួនកាលជញ្ជាំងនៃថ្នក់ពោះវៀនឡើងក្រាស់មានពណ៌ស "លក្ខណៈរាំរ៉ៃ" ។



ថ្លក់ពោះវៀនរីកធំមានឈាមកក



ពោះវៀនមានជាំឈាម

## ៥.ការព្យាបាល :

-ស៊ុលហ្វាមីត (Sulfamide)

-សិបតូទ្រីល ឬ អាល់ហ្វាទ្រិម ១ម.ល "លាយក្នុងទឹកកន្លះលីត្រ" សំរាប់មាន់១០ក្បាលក្នុង១ថ្ងៃ

-ព្យាបាលក្នុងរយៈពេល៥ថ្ងៃ "ក្នុងរយៈពេលនោះមិនត្រូវអោយទឹកសាបវាផឹកទេ"

-ធ្វើការព្យាបាលមាន់ទាំងអស់ក្នុងហ្វូង

-ប្រើអង់ទីប៊ីយោទិក ក្នុងការព្យាបាលអោយបានត្រឹមត្រូវ

## ៦_ការការពារ :

-អនាម័យ

-ត្រូវធ្វើយ៉ាងណាអោយទ្រុងមាន់ស្ងួត

-បំបែកកូនមាន់អោយនៅដោយឡែកពីគ្នា

-ធ្វើការរំងាប់មេរោគទ្រុងអោយបានត្រឹមត្រូវ មុននឹងទិញមាន់ថ្មីមកដាក់ ។



# ជំងឺប៉េស្តទា

ជាជំងឺដែលកើតចំពោះសត្វទា ក្ងាន និងតាលបាទបក្សីដែលរកស៊ីនៅក្នុងទឹក ។ ជំងឺនេះឆ្លងរាលដាលយ៉ាងរហ័ស ពីសត្វទៅ សត្វ១ទៀត សាយភាយយ៉ាងឆាប់រហ័សក្នុងកន្លែងចិញ្ចឹមសត្វ នឹងធ្វើឱ្យសត្វងាប់យ៉ាងច្រើន ។

## ១_ភ្នាក់ងារបង្កជំងឺ :

ជំងឺនេះបង្កដោយវីរុស

## ២_ការចំលង

ពីក្នុងខ្លួនសត្វឈឺ មេរោគចេញមកក្រៅតាមលាមក ទឹកភ្នែក ទឹកសំបោរ ដែលអាចប្រឡាក់ប្រឡូកជាមួយ ទឹក ហើយឆ្លងទៅសត្វផ្សេងទៀត ។ ប្រសិនបើទាមានសុខភាពល្អចុះរកស៊ីទីវាលស្រែ ថ្លុកត្រពាំង វាលបឹងដែលជាក់ ដែលទាឈឺរកចំណី ជំងឺនេះនឹងឆ្លងទៅកាន់ទាដែលមានសុខភាពល្អទាំងនោះ ។

## ៧.រោគសញ្ញា

ជាញឹកញាប់សត្វឈឺងាប់ភ្លាមៗ ដោយគ្មានបង្ហាញរោគសញ្ញាច្បាស់លាស់ណាមួយទេ។ ប្រសិនបើជំងឺនេះអូសបន្លាយពេលយូរ គេអាចសង្កេតឃើញ :

-សត្វឈប់ស៊ីចំណី

-សត្វមានសំឡេងស្អកស្អារ

-ពិបាកដកដង្ហើម

-ហូរទឹកសំបោរ ដំបូងខាប់ ក្រោយមកថ្លា

-ហើមត្របកភ្នែក ភ្នែកក្រហម ដំបូងហូរទឹកភ្នែកថ្លា ធ្វើឱ្យទទឹករោមខាងក្រោមភ្នែក ក្រោយមកទឹកភ្នែកទៅជាខាប់ពណ៌លឿងដូចជាខ្ទុះនៅក្នុងភ្នែក ជួនកាលវាធ្វើអោយភ្នែកបិទជិត។

-ទាជាច្រើនហើមក្បាល ប្រសិនបើយកដៃស្ទាប យើងទទួលអារម្មណ៍ថាដូចជាស្ទាបចេកទុំ។

-ទាស្រេកទឹកខ្លាំង

-រាគ លាមករាវខ្លាំង ក្លិនឆ្អាប ពណ៌បៃតង

-រោមផ្នែកខាងក្រោមគូទសើមដោយលាមក

ក្រោយពីរោគសញ្ញាលេចឡើងបាន ៥-៦ថ្ងៃ សត្វឈឺស្គមខ្លាំង ខ្វិនដើរលែងរួច វាដេកនៅនឹងកន្លែង ធ្លាក់ស្លាប

ជំងឺប៉េស្តទាឆ្លងខ្លាំង អត្រាងាប់ខ្ពស់។ នៅកន្លែងដែលជំងឺមិនធ្លាប់កើត ប្រសិនបើជំងឺផ្ទុះឡើង ហើយបើគ្មានអន្តរាគមន៍ទាន់ពេលវេលានោះទេ អត្រាងាប់ខ្ពស់ពី ៨០-១០០ភាគរយ។ ផ្ទុយទៅវិញ នៅកន្លែងដែលជំងឺផ្ទុះជាប្រចាំជំងឺដែលលេចឡើងក្នុងសណ្ឋានស្រាលជាងអត្រាងាប់មិនសូវខ្ពស់ ប៉ុន្តែជំងឺប៉េស្តនេះអូសបន្លាយរយៈពេលយូរ។

ចំពោះមេទា ជំងឺនេះធ្វើឱ្យវាថយពង ឬឈប់ពង។

## ៨.ការវះកាត់ពិនិត្យ :

-ផ្ទៃខាងក្នុងនៃតែ គ្របដណ្តប់ទៅដោយរំអិលពណ៌ប្រផេះ ស និងមានចេញឈាមលើភ្នាសនៃតែ។

- កោះចេញឈាម ប្រសិនបើយើងបកស្រទាប់ខាងក្នុងនៃកោះចេញ យើងនឹងឃើញស្នាមឆ្នូតឈាមពណ៌ក្រហមក្រម៉ៅ។

- ភ្នាសពោះវៀនធ្លាក់ឈាម ឬចេញឈាមឆ្នូតពណ៌ក្រហម ដែលផ្នែកខាងលើគ្របដណ្តប់ដោយស្រទាប់រំអិលស្តើង។ បើជំងឺធ្ងន់ធ្ងរ មានស្នាមរលាករាងមូល ឬពងក្រពើនៅលើពោះវៀនតូច។

- ភ្នាសក្រសាលគូទ និងភ្នាសពោះវៀនធំ មានចេញឈាមឆ្នូតក្រហម ឆ្លាស់គ្នានឹងស្នាមរលាកពណ៌លឿង។

- ថ្លើមហើមធំជាងធម្មតា ថង់ទឹកប្រម៉ាត់រីកធំ។

- ចំពោះមេទាពង សរសៃកន្សោមពងរីកធំតឹង ពេលខ្លះមានចេញឈាម ពងតូចៗ ព្រៀចប៉ិច។ មានផ្នែកក្រហមនៃស៊ុតបែកនៅប្រហោងពោះ។

### ៥.ការព្យាបាល : គ្មាន

### ៦.ការការពារ :

នៅក្នុងការចិញ្ចឹម គេអាចចាក់ថ្នាំការពារសត្វបាននៅពេលជំងឺផ្ទុះឡើងហើយ ។ វ៉ាក់សាំងផលិតនៅប្រទេ
ថៃ អាចចាក់ការពារលើទាអាយុពី ១ខែទៅ ។

# ជំងឺបណ្ដាលពីព្រូន
## ENDOPARASILE

### ១. ភ្នាក់ងារ :

ជំងឺនេះបណ្ដាលមកពីពពួកព្រូន។ សត្វដែលឈឺនិងជំងឺនេះ គឺមាន់ និងទា ។ ព្រូនទាំងនេះមាននៅក្នុងពោះវៀន

និង បំពង់ខ្យល់នៃសត្វមានជីវិត ។ ពងរបស់វានៅលើដី ។

ជំងឺនេះកើតឡើងនៅគ្រប់រដូវ ។ អត្រាឈឺមានកំរិតខ្ពស់ តែអត្រាស្លាប់មានកំរិតទាប ។

សត្វគ្រប់វ័យអាចឈឺនិងជំងឺនេះ តែកូនសត្វអាចទទួលជាង ។ ការវិវត្តន៍នៃជំងឺនេះមានសភាពយឺត និងបណ្ដាល

អោយមាន បញ្ហាដោយជំងឺផ្សេងទៀត ។

### ២. ការឆ្លងរាលដាល :

ព្រូនទាំងនេះចូលទៅក្នុងសត្វតាមមាត់ ដោយសារការស៊ីចំណី ឬផឹកទឹកដែលមានពងព្រូន ។

សត្វទទួលជំងឺតាមរយៈលាមករបស់សត្វ និងដីដែលមានពងព្រូន ។ ពងព្រូនទាំងនេះមានភាពទន់ណាស់ ។

### ៣. រោគសញ្ញា :

រោគសញ្ញានៃជំងឺគឺអាស្រ័យទៅនឹងទីកន្លែងដែលព្រូនរស់នៅ ។

- *ចំពោះព្រូនដែលរស់នៅក្នុងពោះវៀន*

បណ្ដាលអោយសត្វរាគ ជួនកាលមានលាយឈាម មិនចង់ស៊ីចំណី ស្គម ។

- *ចំពោះព្រូនដែលរស់នៅក្នុងបំពង់ខ្យល់*

បណ្ដាលអោយមានពិបាកក្នុងការដកដង្ហើម ឮសូរសំលេងពេលដកដង្ហើម ។

- *ចំពោះព្រូនមូល*

ចំពោះកូនមាន់បើមានពួកអាស្ការីច្រើនពេក អាចធ្វើឱ្យណែនស្ទះពោះវៀន ។

- *ចំពោះព្រូនអំបោះ*

ធ្វើអោយខូចពោះវៀន

ច្រើនជាមូលហេតុដែលបណ្ដាលអោយមានការរលាកពោះវៀនខ្វះឈាមនិងថយពង

- *ចំពោះព្រូនសំប៉ែតវែង*

ឃើញមានតិចតួច មិនធ្វើអោយមានបញ្ហាធ្ងន់ធ្ងរទេ លើកលែងតែវាដណ្ដើមស៊ីចំណីរបស់មាន់នោះ ។

## ៤.ការវះសាកសពសត្វពិនិត្យ :

សង្កេតឃើញនៅក្នុងពោះវៀនមានព្រូនសំប៉ែត និងព្រូនមូល





## ៥.ការព្យាបាល :

មេបង់ដាហ្សុល (Mebandazol)១គ្រាប់ សំរាប់មាន់ទំងន់ ១០គក្រ

ព្យាបាលរយៈពេល៣ថ្ងៃ ១ថ្ងៃម្តង ។ ព្យាបាលគ្រប់មាន់ទាំងអស់នៅក្នុងហ្វូង ។ ធ្វើការព្យាបាលរំលឹកឡើងវិញក្នុង ១ខែម្តង រៀងរាល់ខែ ។

**៦.ការការពារ :**

-អនាម័យ

-ដាក់កូនមាន់ដោយឡែកពីមាន់ធំ ។

# ការក្រៀវគោ ក្របី
# CASTRATION

នៅប្រទេសកម្ពុជាយើង ប្រជាកសិករច្រើនតែក្រៀវគោ ក្របី ដោយដំសរសៃទឹកកាមឱ្យបែក ឬក៏វះយកពងស្វាស ចេញតែម្តង ។ ការក្រៀវដោយប្រើវិធីទាំងអស់នេះ បានជួបនឹងផលវិបាកយ៉ាងច្រើន ។ ក្នុងការដំនេះគឺគេត្រូវប្រើរយៈពេលយូរ ដើម្បីអោយបែកសរសៃទឹកកាម ។ បន្ទាប់ពីដំមក គោត្រូវអត់ស៊ីស្មៅដោយសារការស្រើបធ្មេញនិងឈឺកន្លែងដែលដំផង ។ ជួនកាលអាចបណ្តាលឱ្យសត្វស្លាប់ផងក៏មាន ដោយសារការធ្វេសប្រហែសរបស់អ្នកដំ ។ ចំណែកឯការវះយកពងស្វាសចេញវិញ ក៏មានផលវិបាកដែរ ដោយការវះហើយទុកអោយឈាម មិនបានដេរមុខរបួសទេដែលជាហេតុធ្វើអោយសត្វខ្សោយ ដោយ សារការហូរឈាមច្រើន ដំបៅយូរ ហើយជាពិសេសជួនកាលអាចធ្វើឱ្យមេរោគតេតាណូសជ្រៀតចូលទៅតាមមុខរបួស ដែលជាហេតុធ្វើអោយមានគ្រោះថ្នាក់ដល់សត្វ ។

ប៉ុន្តែបច្ចុប្បន្ននេះ យើងមានបច្ចេកទេសក្រៀវថ្មី ដែលធានាបាននូវគុណភាពល្អ មានរយៈពេលឆាប់មិនគ្រោះថ្នាក់ ហើយសត្វអាចស៊ីស្មៅបានធម្មតាបន្ទាប់ពីក្រៀវហើយ ។

**ឃ្នាបគាបពងគោ ក្របី**



## បច្ចេកទេសក្រៀវដោយប្រើឃ្នាប :

### ១-របៀបចាប់គោអោយនៅស្ងៀម ឬមិនឱ្យកំរើកៈ

យើងមានវិធីសាស្ត្រច្រើនរបៀបក្នុងការចាប់ចងសត្វ ប៉ុន្តែវិធីសាស្ត្រក្នុងការចាប់ចងសត្វអោយនៅមួយក បានល្អជាងគេនោះគឺ ចងសត្វនៅចន្លោះបង្គោលឈើធំ (រឹងមាំ) ដោយអបសង្ខាងនៅក្បែរដងខ្លួនសត្វ (ដូចការធ្វើសា ជាដើម) ។

-ក្បាលសត្វចងកៀបទៅនិងដើមឈើមួយដើមធំ

-ជើងក្រោយរិតជាប់និងខ្សែ

វិធីសាស្ត្រខាងលើនេះ ធ្វើអោយយើងមិនសូវចំណាយប្រាក់កាកច្រើន ហើយម្យ៉ាងទៀតងាយអនុវត្តន៍បំផុត ។ យើង ឃើញថា គឺជាវិធីសាស្ត្រដែលងាយបំផុតសំរាប់កសិករ និងអ្នកគាប (ក្រៀវពងស្វាស) (មើលរូប)



**ត់សំគាល់ :**

កាបចាប់ចងសត្វ ត្រូវសហការជាមួយម្ចាស់សត្វជាមុនសិន ហើយអ្នកគាបពងសត្វត្រូវផ្តល់យោបល់បច្ចេកទេស ការគាបពងនេះដល់ម្ចាស់សត្វ ។

## ២. របៀបគាបពង (ក្រៀវពង) គោ ក្របី :

កាលណាសត្វនៅនឹងមួយកន្លែងហើយ ត្រូវយកដៃឆ្វេងលូកចាប់ពងសត្វ ទាញពីលើចុះក្រោមទៅខាង ពងនៅ ខាងស្តាំ) ហើយទៅខាងឆ្វេង (បើសិនពងស្ថិតនៅខាងឆ្វេង) ចំណែកដៃស្តាំកាន់ឃ្នាប ។ ងាប់មេរោគនៅកន្លែងត្រង់ កន្លែងដែលត្រូវក្រៀវ(គាប) ដោយអាល់កុល (Alcohol No . 70 °c)បញ្ចូល ប់មកគាបជាមួយនឹងឃ្នាបដែល បើកចំហមាត់នៅដៃស្តាំ ចំបំពង់នាំស្មែម (សរសៃនាំទឹកកាម) គឺផ្នែកខាងពងស្វាស យសង្កត់ឃ្នាបយ៉ាងខ្លាំង រហូតដល់គន្លឹះឃ្នាប ដែលសន្មត់ថាបានការហើយ ។ ក្នុងរយៈពេលតែ៣វិនាទី (យ៉ាងតិច) គាបពងម្ខាងនេះជាការ ស្រេច (ពេលនោះ យើងស្ទាបពងស្វាសដែលគាបនោះឡើងត្រជាក់ស្រឹប) ។

រីឯពងទី២ក៏យើងត្រូវធ្វើដូច្នេះដែរ ក៏ប៉ុន្តែត្រូវដាក់ឃ្នាបអោយខ្ពស់ជាងចំណុចដែលបានគាបលើកទី១ (មើលរូប ខាងក្រោម)



## កំណត់សំគាល់ :

ក្រោយពីការគាបពងសត្វនីមួយៗ បំពង់នាំស្តែម(សរសៃនាំទឹកកាម) ឈប់ដំណើរការ រីឯពងស្វាសចាប់ផ្តើម ស្វិតជាបណ្តើរៗ ។ បន្ទាប់ពីការក្រៀវដោយឃ្នាប បើមានរលាកឬដាច់នៅកន្លែងគាប អាចលាបថ្នាំពណ៌ខៀវ (Blue Methylene ) ឬតាំងទៀវអ៊ីយ៉ូត ឬខ្លាញ់ត្រីក៏បាន ដើម្បីកុំអោយរុយរោម ។

ក្នុងការចិញ្ចឹមសត្វទាំងឡាយ ទោះបីជាលក្ខណៈគ្រួសារក្តី ឬឧស្សាហកម្មក្តី យើងត្រូវតែជ្រើសរើសយកមុខ ធានាឱ្យបាននូវចំណី ដើម្បីឆ្លើយតបនឹងតំរូវការរបស់សត្វ និងការថែទាំអោយបានល្អ នោះទើបការចិញ្ចឹមទទួលបាន លទ្ធផលល្អ ។

## បច្ចេកផ្តួលគោ ក្របី :

គោលបំណង : ក្នុងការផ្តួលគោ ក្របី ដើម្បីអោយងាយស្រួលក្នុងការធ្វើរោគវិនិច្ឆ័យសត្វ (ដូចជាការពិនិត្យលើ កាយឱ្យសព្វទីកន្លែង និងយកកំដៅដោយប្រើសីតុណ្ហមាត្រ) ។ សំភារៈសំរាប់ផ្តួលត្រូវមានខ្សែ២ចង្វាយ ដែលមានប្រវែង ៣ម៉ែត្រ និងមួយខ្សែទៀតប្រវែង ១០ម៉ែត្រ ហើយត្រូវមានដើមឈើមួយដើម រឺបង្គោលមាំដែលធន់នឹងកម្លាំងរបស់ ក្របី បាន ។

### របៀបចងផ្តួល :

-ប្រើខ្សែខ្លីចងពាក់កន្តែ ហើយសិកកន្ទុយខ្សែចូលក្នុងប្រឡោះកន្តែដែលទាក់មុន គឺធ្វើទាកចុងប្រមុះ ហើយដាក់ ទៅលើក្បាលតាមក្រោយស្លឹកត្រចៀក ហើយឆ្លងទៅម្ខាងទៀត (មើលរូបភាព) ។



របៀបចងខ្សែទី១ សំរាប់ឃ្លុំមាត់ របៀបចងខ្សែទី១ សំរាប់ទាញគោផ្តួល

-ប្រើខ្សែទីពីរវែង ត្រូវចងទាក់កន្លែ សំរាប់ទាក់និងកសត្វគោ ( មើលរូបភាពខាងលើ ) ។

-ខ្សែទី១ ដែលទាក់ពីចុងច្រមុះទៅក្បាល ត្រូវយកទៅចងភ្ជាប់នឹងគល់ឈើឬបង្គោលដោយចងទៅផ្នែកខាងក្រោមជិតគល់ឈើ មិនត្រូវចង់ទទ្ទឹមនិងច្រមុះឬលើច្រមុះគោឡើយ មុនពេលយើងផ្តួល ត្រូវចៀសវាងកុំឱ្យនៅពេលយើងផ្តួលគោហើយ ច្រមុះ និងក្បាលរបស់វាហើបផុតពីដី ( មើលរូបភាព ) ។




របៀបចងគោទៅនិងដើមឈើ ដើម្បីទាញផ្តួល

ចំពោះខ្សែទីពីរ ដែលជាខ្សែវែង យើងទាក់កគោត្រូវយកកន្លែងប្រសព្វខ្សែចំពីលើខ្នងគោ ចៀសវាងដាក់ពីចំហៀងខ្លួនសត្វ គឺដើម្បីឱ្យសត្វគោលោតឡើងលើ ( មើលរូបភាពខាងក្រោម ) ។ មុនផ្តួលយើងត្រូវពិនិត្យមើលខ្សែយ៉ាងណា ឱ្យខ្សែជាប់ល្អមនឹងដងខ្លួនសត្វ មិនត្រូវឱ្យខ្សែសល់លើសពីដងខ្លួនសត្វឡើយ ។








វិធីក្រៀវនេះគឺយើងត្រូវការមនុស្សពីរនាក់  ម្នាក់ជាអ្នកចាប់  និងម្នាក់ទៀតជាអ្នកក្រៀវ ។
កាំបិតវះក្រៀវ តំបៀតឃាត់ឈាម  ត្រូវស្មោររំងាប់មេរោគឱ្យបានត្រឹមត្រូវ ។
មុននឹងក្រៀវត្រូវលាងសំអាតដៃ  លាងកន្លែងដែលត្រូវវះក្រៀវ  (ពងស្វាសទាំងពីរ) ដោយប្រើអាល់កុល  រឺអាល់ ឬលេអ៊ុយ៉ូត ឱ្យបានស្អាតដើម្បីរំងាប់មេរោគនៅកន្លែងវះកាត់ ។

វិធីទី១: ដៃប្របាច់ពងស្វាសឱ្យប៉ោងចេញ និងដៃម្ខាងទៀតវះ ( មើលរូបភាព) តែគប្បីវះខាងក្រោមនៃពងស្វាស បន្តិច ដើម្បីទឹករងៃអាចហូរចេញយ៉ាងស្រួល ។ គួរវះឱ្យបានល្មមប្រវែងពងស្វាសអាចចេញបាន ( តាមពងតូច រឺ ធំ) ។

-បន្ទាប់មកត្រូវប្របាច់ពងស្វាសចេញ ហើយប្រើតំបៀតឃាត់ឈាម គៀបលើបំពង់នាំទឹកកាម សរសៃឈាមរួមគ្នា មូលទងពងស្វាស ( បំពង់ទឹកកាម និងសរសៃឈាម) រហូតដល់វាដាច់ មិនត្រូវកាត់ផ្តាច់ឡើយ ។

-ត្រូវអនុវត្តន៍លើពងស្វាសម្ខាងទៀតដូចគ្នា ។

វិធីទី២: រៀបចំពងស្វាសអោយធ្លាក់ទៅក្នុងថង់ពង ទុកឱ្យនៅស្ងៀម លាងដៃ និងឧបករណ៍វះ ដូចវិធីទី១ដែរ រួចវះចន្លោះពងទាំងពីរ ឱ្យបានប្រវែងល្មមតាមពងជ្រូកធំ ឬតូច រួចវះស្រោមពង ប្របាច់ឱ្យពងស្វាសចេញមកក្រៅ ទាញយកពងម្តងមួយៗ យកតំបៀតឃាត់ឈាមមកគៀបសរសៃនាំទឹកកាម និងសរសៃឈាមរហូតដល់ដាច់ ហើយដោះតំបៀតឃាត់ឈាម រួចហើយបញ្ចូលសរសៃឈាមទៅវិញ ។ វះស្រោមពងប្របាច់ពងស្វាសម្ខាងទៀត យកចេញតាមកន្លែងវះដដែល រួចអនុវត្តន៍ដូចមុន ។

ចំពោះជ្រូកបាធំៗ មិនត្រូវអនុវត្តន៍តាមវិធីទី២នេះទេ ត្រូវអនុវត្តន៍តាមវិធីទី១ ប៉ុន្តែត្រូវចាប់ជើងទាំងបួនផ្តោបជាប់គ្នា រួចផ្តេកឱ្យនៅចំហៀង សង្កត់លើជ្រូកអោយបានមាំទាំ( ត្រូវការមនុស្សច្រើនបន្តិច) ទើបអ្នកអាចអនុវត្តន៍ដូចវិធីទី១ខាងលើ តែចាំបាច់ត្រូវប្រើអំបោះដេរ ដើម្បីចងសរសៃឈាម ព្រោះបាមានសរសៃឈាមធំ ចាំបាច់ត្រូវប្រើអំបោះចងសរសៃឈាមយ៉ាងប្រុងប្រយ័ត្នបំផុត ។

## ការប្រុងប្រយ័ត្ន :

-ក្នុងការក្រៀវ កូនជ្រូកដែលមានអាយុតិច គឺប្រសើរជាងជ្រូកដែលមានអាយុច្រើន ។ យកល្អត្រូវក្រៀវមុនផ្តាច់ដោះរយៈពេល១សប្តាហ៍ ទៅ ២សប្តាហ៍ ។ ព្រោះកំរៀវកូនជ្រូកអាចជាសះ នៅពេលផ្តាច់ដោះ ។

-មិនត្រូវក្រៀវនៅពេលផ្តាច់ដោះភ្លាម ឬទើបតែដឹកនាំចូលភ្លាមនោះទេ ព្រោះពេលនោះកូនជ្រូកនៅខ្សោយ ។

-មិនត្រូវទុកឱ្យលើសពី ៣សប្តាហ៍ ក្រោយពេលផ្តាច់ដោះទេ បើសិនជាយើងត្រូវការចិញ្ចឹមយកសាច់ ព្រោះច្រើនសរសៃឈាមក៏ធំ ហើយការសះកំរៀវក៏យឺតយូរ នាំឱ្យខាតបង់ដល់សេដ្ឋកិច្ច ។

-បន្ទាប់ពីក្រៀវហើយ ត្រូវប្រើថ្នាំពពួកអង់ទីប៊ីយោទិក ដូចជា : ប៉េនីស៊ីលីន (Penicilline) សូតាប៉ែន (Shotapen) ...ជាដើម ។

※ **ការបង្កើតកូន :** ពេលកើតកូនគឺជាពេលមួយដែលយើងត្រូវមានការប្រុងប្រយ័ត្នជាទីបំផុត ជាពិសេសទំពេលកំពុងកើត និងកើត ហើយភ្លាម ។ បើពេលកើតកូនមានលក្ខណៈធម្មតា យើងមិនពិបាកជួយវាទេ គឺអាចទុកឱ្យវាកើតតាមសំរួលក្នុងទីស្ងាត់ តែ ចាំបាច់ត្រូវការចំបើងអោយវា ដើម្បីកុំឱ្យកូនប្រឡាក់ដីប៉ុណ្ណោះ ។ តាមការសង្កេតជាដំបូងយើងឃើញមានលេចចេញ ថង់ទឹកភ្លោះ រួចបែកហូរហៀរមកក្រៅតាមទ្វារបន្តពូជ បន្ទាប់មកទៀតកូនគោត្រូវចាប់ផ្ដើមកើតក្នុងរយៈពេល ២ម៉ោង ប្រសិនបើកូនស្ថិតនៅក្នុងពោះមានទំរង់សមស្របតាមលំនាំធម្មជាតិរបស់វា ។

**លំនាំធម្មជាតិរបស់កូនគោពេលកើតគឺ :** ក្បាលនិងជើងមុខ២ ចេញស្របគ្នាមកមុន ជើងក្រោយទាំង២លាត្រង់ ស្របគ្នាចេញមកមុន ( មើលរូបភាព) ។



លំនាំធម្មតារបស់កូនគោពេលកើត

តាមធម្មតាមេគោវាទំរេតពេលកំពុងកើត រួចវាក្រោកឈរមុនពេលដែលកូនចេញមកជិតផុត ។ មេគោប្រហែល ភាគរយ ពុំមានបញ្ហាលំបាកក្នុងការកើតកូនទេ ប៉ុន្តែប្រសិនបើកើតកូនដោយលំបាកលើសពីរយៈពេល២ម៉ោង ប្រហែលបណ្ដាលមកពីលក្ខណៈកូនកើតខុសប្រក្រតី ដែលយើងធ្លាប់ជួបប្រទះជាញឹកញាប់ដូចជា :

១-ចេញជើងមុខស្របគ្នាទាំងពីរ តែក្បាលបត់ចុះទៅក្រោយ បែរចំហៀងខាងឆ្វេង ឬ ខាងស្ដាំ ( រូបភាព១)

២-ចេញជើងមុខម្ខាង ស្របគ្នាជាមួយក្បាលមកមុន តែជើងមុខម្ខាងទៀតបត់ទៅក្រោយ ( រូបភាព២)

៣-គូទ ឬក្បាល មកមុន តែជើងទាំង៤ក្ដោបនៅក្រោមពោះទាំងអស់ ( រូបភាព៣)

៤-ចេញជើងទាំង៤មករួមស្របគ្នានឹងក្បាល ( រូបភាព៤)

បើជួបប្រទះនូវលក្ខណៈដូចខាងលើនេះ ត្រូវតាមអ្នកបច្ចេកទេសសត្វ ឬភ្នាក់ងារសុខភាពសត្វភូមិអោយមកជួយសង្គ្រោះជាបន្ទាន់ ។ បើទុកយូរអាចបណ្ដាលអោយមានគ្រោះថ្នាក់ដល់កូន ឬមេ ឬទាំងមេទាំងកូនក៏មាន ។




## ❋ របៀបសង្គ្រោះមេគោកើតកូនមិនរួច :

មេគោឈឺពោះកើតកូនដែលមានទំរង់សមស្របដំណេកត្រឹមត្រូវតាមលក្ខណៈធម្មជាតិរបស់វានោះ តែក្នុងរយ ពេល២ម៉ោងប៉ុណ្ណោះ ។ ដូចនេះកាលបើយើងសង្កេតឃើញមេគោឈឺពោះ អស់រយៈពេល២ម៉ោងហើយមិនឃើញកើតកូ ចេញមកក្រៅរួច ហើយកំលាំងរបស់មេគោក៏ខ្សោយចុះបន្តិចម្តងៗ ពេលនោះបើយើងជាភ្នាក់ងារសុខភាពសត្វភូមិត្រូ ទៅសង្គ្រោះវាជាបន្ទាន់ ដោយត្រូវអនុវត្តន៏តាមក្បួនអនាម័យបសុពេទ្យដូចខាងក្រោមនេះ :

-កាត់ក្រចកដៃទាំងអស់អោយខ្លី ហើយលាងដៃឱ្យបានស្អាតជាមួយនឹកទឹកក្តៅឧណ្ហៗ ឬទឹកសាប៊ូ ហើយត្រូវដោះ គ្រឿងអលង្ការពីដៃអោយអស់ ។

-សំអាតសំភារៈផ្សេងៗសំរាប់ប្រើប្រាស់ និងខ្សែសំរាប់ចងទាញអោយបានស្អាត ។

-ដុសលាងទ្វារបន្តពូជ ត្រគាក ភ្លៅ និង កន្ទុយ ដោយទឹកក្តៅឧណ្ហៗលាយនឹងសាប៊ូអោយបានស្អាត

-ត្រូវចងគ្រៀកសត្វក្នុងសាឡុង ដើម្បីចៀសវាងគ្រោះថ្នាក់

បន្ទាប់មកយើងត្រូវអនុវត្តន៏តាមវិធីជួយសង្គ្រោះទៅតាមលក្ខណៈស្រាល ឬធ្ងន់ធ្ងរដូចខាងក្រោម :

## .លក្ខណៈស្រាល :

បន្ទាប់ពីពាក់ស្រោមដៃរួច អោយមេគោក្រោកឈរបញ្ចូលក្នុងសាឡុង រួចចាប់អនុវត្តន៏លូកដៃតាមទ្វារបន្តពូជ ទៅកាន់ក្បាលកូនក្នុងពោះ ដោយយកដៃលូកស្ទាបបង្វែរតំរង់ក្បាលកូនឱ្យចំមាត់ទ្វារមេ រួចទុកឱ្យប្រឹងតាមសំរួល ក្នុងការ ង្វិលសំរួលនេះ ត្រូវធ្វើទៅតាមចង្វាក់នៃការប្រឹងរបស់មេ បើមេកំពុងប្រឹងខ្លាំង កុំទាន់បង្វិលសំរួលវា ទុកឱ្យវាបង្កន់ទើប ម្រេតម្រង់តាមសំរួល ។

## .លក្ខណៈធ្ងន់ធ្ងរ :

មេដេកពុំសូវមានកំលាំងប្រឹងខ្លាំងពេកទេ ត្រូវប្រើខ្សែនីឡុងដែលសំអាតរួច លូកទៅចងលើក្បាលមកក្រអូមមាត់ ញក្បាលកូនចូលក្នុង ហើយបង្វិលទាញក្បាលកូនតម្រង់ឱ្យចំទ្វារមេ ។ មុននឹងទាញកូនចេញត្រូវស្ទាបពិនិត្យមើលទំរង់ឱ្យ នស្រួល បើជើងបត់ត្រូវលូកដៃទៅកាន់ក្តាប់ក្រចកជើងឱ្យជាប់កុំរបូតឱ្យសោះ តែរបូតនឹងបណ្តាលឱ្យរហែកធ្លុះដាច់ស្បូន គ្រោះថ្នាក់ធំមួយដល់មេ ។ បន្ទាប់មកត្រូវរុញទៅលើ ហើយទាញឱ្យសណ្តកត្រង់ស្របតាមក្បាលឱ្យចំមាត់ទ្វារមេ ទើប ចទាញចេញបាន ។ ពេលទាញត្រូវជួយទាញនៅពេលដែលមេកំពុងប្រឹងខ្លាំង ទាញសន្សឹម១ចៀសវាងនាំអោយរហែក របន្តពូជមេ ( មើលរូបភាព) ។



របៀបទាញកូនគោចេញ នៅពេលកើតមិនរួច

## គ.លក្ខណៈឆ្លងទ្វារបំផុត :

មេគោកាន់តែខ្សោយខ្លាំង ដោយរយៈពេលឈឺពោះយូរពេក លក្ខណៈនេះច្រើនបណ្តាលមកពីមាត់ស្បូនចង្អៀត ហើយទឹកភ្លោះបែកយូរ ស្ងួតជាតិរំអិល ។ ពេលនោះយើងត្រូវដកពិសោធន៍ ចាប់មេអោយបង្វិលដេកផ្ងារម្តង រួចបញ្ចូលទឹកឆ្អិនស្អាតជាច្រើនលីត្រ ដែលមានកំដៅស្មើនិងខ្លួនមេ បញ្ចូលទៅក្នុងស្បូន ដើម្បីជួយឱ្យមានជាតិរំអិលឡើងវិញ ប្រយោជន៍ងាយស្រួលឱ្យកូនកើត ។

## ការស្ទះសុក :

វាមានរយៈពេលកំណត់ត្រឹមត្រូវរបស់វា ប្រសិនបើសុកមិនធ្លាក់រយៈពេលពី ៦ទៅ១០ម៉ោង ក្រោយពេលកូនកើតរួច យើងត្រូវរកវិធានការជួយសង្គ្រោះជាបន្ទាន់ ។ ការស្ទះសុកបណ្តាលមកពី :

-លទ្ធភាពនៃការបន្រ្តាក់ស្បូនមិនបានគ្រប់គ្រាន់ (Hypotonie)

-គ្មានកំលាំងកន្រ្តាក់ស្បូនទាល់តែសោះ (Atonie)

-ការប៉ះពាល់ដល់ភាពជាប់ស្អិតរបស់ផ្ទៃកស្បូន និងសុកកូន ច្រើនកើតឡើងដោយសារភាពចុះខ្សោយ បាត់បង់នូវ ការកន្រ្តាក់សាច់ដុំ ដែលមានជំងឺមួយចំនួនដូចជា : ជំងឺព្រុយសែលឡូស៊ីស (Brucellosis) រលូតកូន (Abortion) រលាកស្បូន (Metritis). Hypotonie ឬ Atonie . មេខ្សោយគ្មានកំលាំង ចំណីអាហារមិនគ្រប់គ្រាន់ កង្វះវីតាមីន ការគ្រុនក្តៅច្រើន ការរៀបចំមុនមិនបានល្អនូវល័ក្ខខ័ណ្ឌថែទាំ និងកន្លែងសំរាប់សត្វមានគ៌ភ ។

## ❋ រោគសញ្ញា :

ចំពោះគោដែលតែងតែជួបប្រទះជាញឹកញាប់ នូវការស្ទះសុក ឬបំណែកសុក ជួនកាលមានឃើញបំណែកសុកធ្លាក់ចេញអន្លាយពីប្រដាប់បន្តពូជ ( យោនី ) ដែលសំយ៉ុងចុះដល់សន្លាក់ជើងក្រោយ ។ សត្វឈរដោយចំកោងឆ្អឹងខ្នង ខំប្រឹងហាក់ដូចជា ចង់បន្ទោរបង់ ។ ក្នុងសភាពការនេះ កាកសំណល់ចាប់ផ្តើមមានក្លិនស្អុយភាយៗចេញមក ។ ប្រសិនបើកាកសំណល់ផ្ទៃក្នុងនៃសុកធ្លាក់មិនអស់ មានផ្ទុកក្នុងស្បូនវានឹងស្អុយរលួយបង្កឱ្យមានការរលាកក្នុងស្បូន បណ្តាលឱ្យសត្វមានអាការៈដូចជា :

- មានសភាពល្វើយអស់កំលាំង
- ស៊ីតុណ្ហភាពក្នុងខ្លួនកើនឡើង
- សត្វមិនសូវស៊ីចំណី
- បរិមាណផលិតទឹកដោះត្រូវថយចុះ
- ជួនកាលបណ្តាលឱ្យមានការរាគរូស
- សត្វឈរដោយប្រឹងចំកោងខ្នង និង ផតពោះចុះឡើង ។

ជួនកាលគេសង្កេតឃើញផងដែរនូវការស្ទះសុកទាំងមូលនៅក្នុងស្បូន ។ ការស្ទះនេះ មួយថ្ងៃមុនដំបូងសត្វមានសភាពធម្មតា តែ២ ឬ ៣ថ្ងៃ ក្រោយមក យើងឃើញចាប់ផ្តើមមានទឹករំអិលដូចខ្ទុះរាងសំបោរលាយគ្រាប់តូចៗ ហៀរចេញពីស្បូនមក ពេលនោះហើយដែលធ្វើឱ្យមានការប្រែប្រួលនូវស្ថានភាពទូទៅរបស់សត្វ ដូចជា :

- សីតុណ្ហភាពកើនឡើង
- សត្វឈរទ្រឹង ជួនដេក
- ពុំស៊ីចំណី

ផលវិបាកនៃការស្ទះនេះ វាអាចឱ្យមានកើតជំងឺមួយចំនួនដូចជា :

- រលាកស្បូន
- រលាកយោនី
- រលាកដោះ

## ❋ របៀបថែរក្សាកូនគោទើបកើតភ្លាម :

កូនគោដែលកើតមកហើយ ជាដំបូងត្រូវពិនិត្យរន្ធច្រមុះក្រែងមានស្លេស្មបិទជិត ត្រូវត្បារ និងជូតឱ្យបានស្ងួត និងក្រណាត់ស្បៃដែលស្ងួតល្អ ហើយត្រូវកាត់ផ្ចិតចំងាយពីពោះ ៤ ទៅ ៦ ស.ម (មើលរូបភាព) ។




របៀបកាត់ផ្ចិតកូនគោ

ប៉ុន្តែមុននិងកាត់ ត្រូវជូតឈាមក្នុងទងផ្ចិតឱ្យអស់ កាត់ហើយត្រូវលាបថ្នាំតាំងទីអ៊ីយ៉ូដ ឬថ្នាំសម្លាប់មេរោគផ្សេងទៀត ។ បន្ទាប់មកទៀតយើងត្រូវថ្លឹងកូនគោដើម្បីអោយដឹងថានៅពេលវាកើតមានទំងន់ប៉ុន្មាន ចុះក្នុងបញ្ជីថ្លឹងប្រចាំខែ ។

នៅពេលកូនគោកើតហើយ មេវាលិតយ៉ាងច្រើន ធ្វើយ៉ាងនេះគឺវាទទួលស្គាល់កូនរបស់វា ។ ក្នុងពេលជាមួយគ្នា យើងចាំបាច់ត្រូវឱ្យកូនគោបៅទឹកដោះដំបូង (ទឹកដោះដំបូងដែលមានគ្រឿងការពារខ្លួនច្រើន) ទឹកដោះដំបូងនេះការពារកូន ប្រឆាំងនឹងជំងឺដែលកើតមានក្នុងរយៈពេលមួយខែ ។ ដូច្នេះហើយយើងត្រូវបង្ខំកូនគោ ឱ្យបៅភ្លាមក្រោយ

វាកើត ។ បើកូនគោខ្សោយពេករកដោះខ្លួនឯងមិនឃើញ ត្រូវជួយវា និងមើលវាឱ្យបៅទឹកដោះដំបូងឱ្យបានគ្រប់គ្រា
ព្រោះ សុខភាពកូនគោទាក់ទងនឹងទឹកដោះនេះ ។ ក្នុងរយៈពេលបំបៅកូន ចាំបាច់ត្រូវផ្តល់ចំណីឱ្យមេគោបានគ្រប់គ្រា
ព្រោះពេលនេះសេចក្តីត្រូវការចំណីរបស់វាត្រូវកើន ។

*សេចក្តីបញ្ជាក់* : តាមដានពិនិត្យមើលមេគោតើធ្លាក់សុកហើយឬនៅ? ជាធម្មតាសត្វកើតកូនរួចត្រូវតែធ្លាក់សុក
ប្រសិនបើសុកនោះ មិនព្រមធ្លាក់ក្រោយពេលកើតរួច ៨ម៉ោងទេនោះ មេគោនឹងទៅជាគ្រុនឡើងកំដៅយ៉ាងខ្លាំង ។

សត្វដែលជួបប្រទះនៅបញ្ហានេះ ច្រើនតែបណ្តាលមកពីមូលហេតុខាងក្រោមនេះ :

- ខ្វះខាតចំណីអាហារក្នុងការថែទាំ ជាពិសេសខ្វះជីវជាតិអា (Vitamine A)
- សត្វកើតមិនគ្រប់ខែ ឬមេមានកូនភ្លោះ ឬកូនក្នុងពោះធំពេក ឬស្រោមថង់ផ្ទុកកូនមានទឹកច្រើនពេកធ្វើ
សាច់ដុំស្បូន កន្ត្រាក់ខ្លាំង ។
- ជួនកាលតួស្បូនត្រូវរលាក ដែលបណ្តាលមកពីជំងឺមួយនៅជិតគ្រប់ខែ ។ ក្នុងករណីបើសុកមិនព្រមធ្លា
ក្នុងរយៈពេល ២៤ម៉ោង ឬរហូតដល់ ៤៨ម៉ោង គេសង្កេតឃើញសីតុណ្ហភាពមេគោ ត្រូវក្តៅរហូតដល់ ៤០-៤១ (°) ហើយ
កោសិការរបស់សុកត្រូវងាប់ នឹងមានទឹករំអិលល្អក់ៗ ហៀរចេញមកខាងក្រៅនៃទ្វារបន្តពូជ ដោយមានក្លិនស្អុយ ។ ពេល
នោះមេគោមានសភាពឈរទ្រឹង ទឹកដោះចេញខ្សោយ មិនឱ្យកូនបៅ ប្រសិនបើយើងមិនសង្គ្រោះភ្លាមទេ វានាំឱ្យរលាក
ស្បូន រលាកដោះ នឹងកើតជំងឺឆ្លងបាន សត្វនឹងស្លាប់ក្នុងរយៈពេលខាងមុខ ។

## ❋ វិធានការណ៍ការពារ :

ក្រៅពីកត្តាទាំងអស់ខាងលើ បញ្ហាសំខាន់ដែលកសិករជួបប្រទះក្នុងការចិញ្ចឹមគោ ក្របី គឺជំងឺដែលកើតមាន
ជាញឹកញាប់ចំពោះសត្វ ជំងឺចែកចេញជាពីរផ្នែក គឺជំងឺឆ្លង និងជំងឺបណ្តាលមកពីបរាសិត។ ដោយហេតុថាយើងមិនអាច
សិក្សាបានគ្រប់ជំងឺនោះទេ តែជំងឺសំខាន់ៗដែលសង្កេតឃើញកើតមាននៅប្រទេសកម្ពុជាគឺ : ជំងឺអុតក្តាម សារទឹក
ឈាមខ្មៅ និង បូសខ្យល់ ។ ដូចនេះហើយយើងត្រូវយកចិត្តទុកដាក់ក្នុងការចាក់ថ្នាំការពារលើជំងឺ ទាំងបួនប្រភេទនេះឱ្យ
បានទៀងទាត់ ពីព្រោះកាលណាមានជំងឺនេះកើតឡើងហើយ ការព្យាបាលច្រើនតែគ្មានប្រសិទ្ធភាព ។ ម្យ៉ាងវិញទៀត
កាលណាអ្នកសង្កេត ឃើញសត្វឈឺ ត្រូវចាប់អារម្មណ៍ និងមានវិធានការណ៍ដូចជា :

- បំបែកសត្វឈឺចេញពីសត្វជា និងធ្វើអនាម័យទីកន្លែងដែលសត្វឈឺរស់នៅ
- បង្ខាំងសត្វឈឺទុក ដើម្បីងាយស្រួលក្នុងការព្យាបាល និងការពារនូវការឆ្លងរាលដាល
- សាកសពរបស់សត្វស្លាប់ ត្រូវកប់ឱ្យជ្រៅ ឬដុតចោល ( ហាមបរិភោគ)



សាកសពសត្វមានជម្ងឺឆ្លងត្រូវកប់ឱ្យជ្រៅ មិនត្រូវបរិភោគឡើយ

# ជំងឺមួយចំនួននៃសត្វញីបន្តពូជ

**ការមិនបង្កកំណើត :**

វាអាចមានប្រភពជាច្រើន ។ ភាពអារបស់សត្វមេអាចបណ្តាលមកពី ជំងឺកង្វះសារធាតុចិញ្ចឹម និងជំងឺផ្សេងៗ ទៀត ។

*វដ្តនៃការរកឈ្មោល :* ជាទូទៅការដែលមិនអាចបង្កកំណើតបាន គឺបណ្តាលមកពីវត្តមានមិនទៀងទាត់នៃការរកឈ្មោល ឬការរកឈ្មោលលេចឡើងមិនបង្ហាញលក្ខណៈឱ្យឃើញ ។ នៅប្រទេសកម្ពុជាយើង អ្នកចិញ្ចឹមមិនសូវយកចិត្តទុកដាក់តាមដានការរកឈ្មោលរបស់មេគោទេ ដែលជាការខុសស្រឡះពីមេជ្រូក ។ ប្រជាជនចូលចិត្តអោយមេគោដោយឈ្មោលនៅតាមវាលស្មៅ ដែលពេលខ្លះវដ្តនៃការរកឈ្មោល "កាត់ផ្តាច់" ។

ការផ្តល់អាហារមានតុល្យភាព នាំឱ្យការបន្តពូជមានការល្អប្រសើរ ។ វាកាត់បន្ថយមហន្តរាយនៃការបង្កកំណើត និងជំងឺផ្សេងៗ ។ គេអាចអនុវត្តន៍នូវវិធានការណ៍ការពារដោយផ្តល់ចំណីអាហារដែលមានជាតិអាសូតច្រើនដល់សត្វ ។ ដូចនេះគេត្រូវឱ្យសត្វស៊ីផ្អកចំបើង ។ យើងត្រូវចាក់វីតាមីន អា ដេ៣ អឺ ($AD_3E$)នៅរដូវប្រាំងនិងមុនពេលបន្តពូជ ។

## ២-ជំងឺរលាកស្បូន :

ជាជំងឺប្រដាប់បន្តពូជ ក៏អាចជាបុព្វហេតុនៃការមិនបង្កកំណើតដែរ ។ ការរលាកស្បូនចែកចេញជា២ប្រភេទ :

<u>ក-ការរលាកស្បូនស្រួចស្រាវ :</u>

*មូលហេតុ :* ការរលាកស្បូនស្រួចស្រាវអាចបណ្តាលមកពី :

-ការទំលាក់កូនដោយលំបាក

-ការទំលាក់កូនដោយមិនធ្លាក់សុក ( ការស្ទះសុក)

-ការកើតកូនប្រព្រឹត្តទៅក្នុងល័ក្ខខ័ណ្ឌមិនធម្មតា

-ការកន្ត្រាក់ស្បូនខ្លាំងហួសហេតុ

-ការរលូតកូន

-ការធ្លាក់ស្បូនចេញមកក្រៅ

-ជំងឺឆ្លងមួយចំនួន

*រោគសញ្ញា:* មានហូរចេញនូវសំបោរលាយខ្ទុះ ពីផ្លូវបន្តពូជ សត្វគ្រុនក្តៅ សត្វអស់កំលាំង មិនស៊ីចំណី ។

*ការព្យាបាល :*

-លាងសំអាតស្បូនដោយប្រើ  ប៉ូតាស្យូមពែរម៉ង់កាណាត ១/១០០០ ( ១ក្រាមជាមួយទឹក១លីត្រ)

-ប្រើទឹកអំបិល ៣-៥ភាគរយ ( ៣០០-៥០០ក្រាមជាមួយទឹក១០លីត្រ) ឬសេរ៉ូប្រៃ ០.៩ភាគរយ

-តាំងទូរអ៊ីយ៉ូត ២០ ដំណក់លាយទឹក១លីត្រ

-បេតាឌីន ១-២ស្លាបព្រា លាយទឹកក្តៅឧណ្ហ១១លីត្រ

ថ្នាំអង់ទីប៊ីយោទិក

-ប៉េនីស៊ីលីន

-អាល់ប៊ីប៉ែន ( អំពីស៊ីលីន)

-ទែរ៉ាវ៉ៃត អុកស៊ីតេត្រាស៊ីគ្លីន អុកស៊ីតែត អុកស៊ីគ្លីន

- ចាក់អុកស៊ីតូស៊ីន ៤០-១០០UI ចាក់សាច់ដុំ ឬ សើរស្បែក
- ចំពោះសត្វដែលមានសភាពដុនដាបខ្លាំងត្រូវប្រើគ្លុយកូស ៤០ភាគរយ ចំនួន ២០០-៣០០ម.ល តាមសរសៃឈាម ។

## ៤.ការរលាកស្បូនរ៉ាំរ៉ៃ :

*មូលហេតុ :* ការរលាកស្បូនរ៉ាំរ៉ៃ ច្រើនបណ្ដាលមកពីម្ចាស់សត្វមានការធ្វេសប្រហែសមិនយកចិត្តទុកដាក់ពេលស្បូនទើបរលាកដំបូង ( មិនចាប់អារម្មណ៍ និងមិនមានការព្យាបាល) ។

*រោគសញ្ញា :* សង្កេតឃើញមានដុំរំអិលតូចៗកកហៀរចេញពីស្បូន ជួនកាលមានខ្ទុះពណ៌លឿងព្រឿងៗ ការកន្ត្រាក់ស្បូនមានសភាពខ្សោយបំផុត ។

*ការព្យាបាល :*

-លាងសំអាតស្បូនដោយប្រើទឹកអំបិល ៣-១០%

-ប្រើថ្នាំជំនួយដល់ការកន្ត្រាក់ស្បូន :អុកស៊ីតូស៊ីន វីតាមីន $AD_3E$

-ចាក់ថ្នាំប៉េនីស៊ីលីន ក្លរ៉មហ្វេនីកុល អាល់ប៊ីប៉ែន ទែរ៉ាវ៉ៃត អុកស៊ីគ្លីន អុកស៊ីតែត.......

## ៥.វិធានការការពារ :

-យកចិត្តទុកដាក់ចំពោះមេជើម

-ផ្ដល់ចំណីគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព

-ប្រុងប្រយ័ត្នក្នុងការជួយបង្កើតកូន សំភារៈប្រើប្រាស់ត្រូវរំងាប់មេរោគឱ្យបានល្អ

-កន្លែងកើតកូនត្រូវមានអនាម័យ

-ត្រួតពិនិត្យការធ្លាក់សុកក្រោយពេលកើត បើមិនទាន់ធ្លាក់តាមពេលកំណត់ទេ ត្រូវព្យាបាល ។

## ៣.ការរលូតកូន :

ការរលូតកូនគឺជាការបញ្ចេញឬធ្លាក់កូនមកក្រៅមុនពេលកំណត់នៃការកើត ។

ក-មូលហេតុ :មូលហេតុនៃការរលូតកូនចែកចេញជា ៣សំខាន់ៗ :

-ការរលូតដោយជំងឺមិនឆ្លង

-ការរលូតដោយជំងឺឆ្លង

-ការរលូតដោយជំងឺបរាសិត

## ការរលូតដោយជំងឺមិនឆ្លង :

-ការរលូតដោយចំណីអាហារ :

ចំណីខ្វះវីតាមីន

ចំណីខ្វះសារធាតុរ៉ែ :កង្វះជាតិកាល់ស្យូម និងផូស្វ័រសំរាប់ការលូតលាស់ឆ្អឹង

ចំណីខ្វះប្រូតេអ៊ីន : ប្រូតេអ៊ីនជួយអោយកូនលូតលាស់ ធំធាត់

ចំណីអាហារមានជាតិពុលច្រើន

-ការរលូតដោយការប៉ះទង្គិច :

ការបុកទង្គិចត្រូវពោះយ៉ាងខ្លាំង

ការដើរធ្លាក់រណ្តៅ ការលោតផ្លោះរបង ឬរនាំងផ្សេងៗ

ការដួលបោកខ្លួន

ធ្វើការហួសកំលាំង ធ្វើដំណើរផ្លូវឆ្ងាយបាក់កំលាំង

ផ្អើល ឬភ័យខ្លាច

-ការរលូតដោយការចាក់វ៉ាក់សាំង :

*ការរលូតដោយជំងឺឆ្លង* :មានជំងឺឆ្លងមួយចំនួនដែលបណ្តាលឱ្យសត្វមេរលូតកូន ជាពិសេសជំងឺដែលបណ្តាលឱ្យសត្វក្តៅខ្លាំង ដូចជាជំងឺអ៊ុតក្តាម ឈាមខ្មៅជាដើម ។

*ការរលូតដោយជំងឺបរាសិត* : មានជំងឺបរាសិតខ្លះអាចបណ្តាលឱ្យរលូតបាន ដូចជាទ្រីខូម៉ូណាសជាដើម ។

ខ-រោគសញ្ញា :

-សត្វមិនសូវស៊ីចំណី

-ក្តៅខ្លួន

-ហើមដោះ

-សត្វនៅមិនស្ងៀម ឆ្លេឆ្លា

-មានការកន្ត្រាក់សាច់ដុំពោះ

-មាត់ស្បូនបើក

-មានឈាមហូរចេញតាមយោនី

-ធ្លាក់កូនចេញមកក្រៅ

ក-ការព្យាបាល :

-កាលណាយើងឃើញផ្នែកខ្លះនៃកូន ឬកូនលេចចេញនៅក្នុងមាត់ស្បូន យើងត្រូវតំរង់ស្ថានភាពកូនរួចទាញចេញ

-ក្រោយមកប្រើអង់ទីប៊ីយោទិក

ខ-វិធានការការពារ :

-ថៃទាំឱ្យបានដិតដល់

-ផ្តល់ចំណីអាហារឱ្យបានគ្រប់គ្រាន់

-កន្លែងរស់នៅស្អាត

-ធ្វើចលនាបានច្រើន តាមសំរួល

-ហាមប្រើថ្នាំដែលមានអំពើកន្ត្រាក់ស្បូនខ្លាំងពេក និងថ្នាំសន្លប់

## ៤.ជំងឺលាសដោះ :

ជំងឺលាសដោះមានច្រើនកំរិត ។ វាលេចឡើងនៅពេលទឹកដោះចុះថយ ឬស្លាក់ឈាមដោះ ដោយមានសញ្ញាមិនឱ្យកូនបៅ។ បើជំងឺក្នុងសណ្ឋានភាពស្រួចស្រាវ គេសង្កេតឃើញ :

-កំដៅឡើងខ្ពស់

-ដោះហើមធំ ហើយរឹង

-ដោះមានការឈឺចាប់ មិនឱ្យកូនបៅ

-អាចកើតជាអាប់សែ ឬខ្ទុះដោយកំរ៉ំ

ការព្យាបាល :

-ច្របាច់ទឹកដោះចេញទាំងព្រឹក និងល្ងាច

-ព្យាបាលដោយប្រើអង់ទីប៊ីយោទិក : អុកស៊ីតេត្រា ទែរ៉ាវ៉ែត អុកស៊ីគ្លីន អាល់ប៊ីប៉ែន...។

វិធានការការពារ

-អនាម័យកន្លែងរស់នៅរបស់សត្វ

-អនាម័យដោះ

## ៥.ការស្ទះសុក :

ការស្ទះសុកគឺជាការមិនធ្លាក់សុកតាមពេលកំណត់ ក្រោយពេលដែលកូនកើតហើយ ។

ក-មូលហេតុ : មូលហេតុនៃការមិនធ្លាក់សុកអាចបណ្តាលមកពី :

- ស្បូនខ្សោយ កំលាំងកន្ត្រាក់ស្បូនមិនគ្រប់គ្រាន់សំរាប់រុញសុកចេញមកក្រៅ

- គ្មានការកន្ត្រាក់ស្បូនទាល់តែសោះ

- ការស្អិតជាប់គ្នារវាងសុក និងចំណែកនៃស្បូន ដែលច្រើនកើតឡើងដោយសារភាពចុះខ្សោយ ឬការបាត់បង់ការកន្ត្រាក់សាច់ដុំស្បូនដែលបណ្តាលមកពីជំងឺព្រូសសៃលឡូស ការរលូតកូន ការរលាកស្បូន មេខ្សោយខ្លាំងពេក ការផ្តល់ចំណីមិនគ្រប់គ្រាន់ កង្វះវីតាមីន ការគ្រុនក្តៅច្រើន ការថែទាំអនាម័យពេលផើមមិនបានល្អ ។

ខ-រោគសញ្ញា

ចំពោះគោច្រើនជួបប្រទះការស្ទះសុកផ្នែកខ្លះ ។ គេសង្កេតឃើញសុកធ្លាក់សំយុងអន្លាយមកខាងក្រៅតាមយោនី

សត្វឈរចំកោងខ្នង ខំប្រឹងហាក់ដូចជាបន្ទោរបង់ ។ ជួនកាលគេក៏ជួបប្រទះផងដែរនូវការស្ទះសុកទាំងស្រុងនៅក្នុងស្បូនដែរ ។ ប្រសិនបើសុកនៅក្នុងស្បូនយូរ នាំឱ្យសត្វពុល គេសង្កេតឃើញ :

- សត្វអស់កំលាំង
- កំដៅឡើង
- សត្វមិនសូវស៊ីចំណី
- សត្វឈរចំកោងខ្នង និងផតពោះចុះឡើង

ក្រោយពីការស្ទះសុកបាន ៤-៥ ថ្ងៃគេសង្កេតឃើញមានទឹករំអិល ខ្ទុះ ហៀរចេញពីស្បូន ។ ការស្ទះសុកអាចជាមូលហេតុនាំអោយកើតជំងឺរលាកស្បូន រលាកយោនី រលាកដោះ ។

គ- ការព្យាបាល

- ធ្វើឱ្យសុកធ្លាក់ចេញពីស្បូន ដើម្បីកុំឱ្យសុករលួយ និងមេរោគបង្កកូនចៅក្នុងស្បូន :

➠ ជំរុញឱ្យស្បូនកន្ត្រាក់ : ក្រោយពីកើតកូន ៦-៨ ម៉ោង សុកមិនធ្លាក់ទេ គេត្រូវបញ្ជ្រកទឹកស្ករពាក់កណ្តាលមាត់ចំនួន ៥០០-៧០០ក្រាម លាយជាមួយទឹក ២លីត្រ ឬចាក់អុកស៊ីតូស៊ីន ១0UI សំរាប់សត្វ ១00kg ។

➠ លូកបាដោយដៃ : ប្រសិនបើអនុវត្តវិធីខាងលើមិនបានសំរេចក្រោយពីកើតបាន ២៤ម៉ោង យើងត្រូវលូកបាសុកដោយដៃ ។ ដំបូងយើងត្រូវចងគ្រៀកសត្វនៅក្នុងសាឡុងមួយរឹងមាំ រួចយើងបញ្ចូលទឹកអំបិល ៥-១0 ភាគរយប្រហែល ៥ លីត្រ ។ ៣០ នាទីក្រោយយើងចាប់ផ្តើមលូក ។ យើងលូកដៃម្ខាងដែលមានពាក់ស្រោម តាមយោនីចូលទៅក្នុងស្បូនរាវរកសុក ។ យើងយកដៃសង្កត់ជើងការុនគូល រួចផ្តាច់កូទីឡេដុងចេញពីការុនគូល ។ ចំណែកដៃនៅខាងក្រៅ ត្រូវចាប់ទាញសុកដែលលៀនចេញ បន្តិចម្តងៗ រហូតដល់អស់ ។

- បង្កកុំឱ្យមេរោគរីកចំរើនក្នុងស្បូនដោយប្រើថ្នាំ ប៉េនីស៊ីលីន អុកស៊ីតែត ...

ឃ- វិធានការពារ :

- យកចិត្តទុកដាក់ឱ្យបានល្អពេលសត្វធើម កើតកូន និង ក្រោយកូនរួច
- ផ្តល់ចំណីអាហារគ្រប់គ្រាន់ទាំងបរិមាណ និង គុណភាព
- អនាម័យទូទៅ : ចំណីអាហារ ទឹក កន្លែងរស់នៅ ខ្លួនសត្វ

**រូបបង្ហាញអំពីកូទីឡេដុង និងការូនគូល**



រូបរាងស្បូនមេគោពេលមិនទាន់មានភគិ



រូបរាងស្បូនមេគោពេលមមានភគិ




## ៦.ជំងឺធ្លាក់ស្បូន :

ធ្លាក់ស្បូនជាគ្រោះថ្នាក់ដែលកើតឡើងក្រោយពីទំលាក់កូន ។ ការធ្លាក់ស្បូនអាចបណ្តាលមកពីការមិនធ្លាក់សុក និងការខំប្រឹងបញ្ចេញកូនយ៉ាងខ្លាំងរបស់មេគោ ពេលទំលាក់កូន ។

ការធ្លាក់ស្បូនមាន ២ប្រភេទ ៖

- ការធ្លាក់ស្បូនមិនពេញលេញ ( ករណីកំរ )
- ការធ្លាក់ស្បូនពេញលេញ

ជាទូទៅការធ្លាក់ស្បូនមានលក្ខណៈពេញលេញ ។ ស្បូនដែលធ្លាក់មកក្រៅអាចមានទំហំធម្មតា ធំល្មម ធំខ្លាំង អាស្រ័យទៅតាមរយៈពេលដែលស្បូនបានធ្លាក់ចេញមកក្រៅ ។ នៅជាប់នឹងស្បូនយើងឃើញវត្តមានកូទីឡេដុង ជូនកាលឃើញមានចំណែកនៃស្រោមកូន ។ មេគោមួយចំនួនតូចមានការឈឺចាប់ ចំណែក មួយចំនួនធំមិនមានការឈឺចាប់អ្វីទាំងអស់ វានៅទំពារអៀងយ៉ាងស្ងៀមស្ងាត់ ។

ការធ្លាក់ស្បូនច្រើនតែធ្វើឱ្យម្ចាស់សត្វ មានការភ័យស្លន់ស្លោយ៉ាងខ្លាំង ប៉ុន្តែវាគ្មានបញ្ហាអ្វីទេប្រសិនបើគេជួយអន្តរាគមន៍ទាន់ពេលវេលា ។ ការធ្វើអន្តរាគមន៍យឺតយ៉ាវ ស្បូនហើមធំ រាតត្បាតដោយមេរោគ យើងជួបការលំបាកក្នុងការបញ្ចូលស្បូនទៅក្នុងវិញ ពេលនេះគេត្រូវតែកាត់ស្បូនចេញ ។ សត្វអាចងាប់ពេលណាមានការហូរឈាមខាងក្នុងស្បូន ។



១-ស្បូនក្នុងទីតាំងធម្មតា



២-ស្បូនចាប់ផ្តើមធ្លាក់ដំបូង



៣-ស្បូនធ្លាក់ពាក់កណ្តាល



៤-ស្បូនធ្លាក់ពេញលេញ

## របៀបបញ្ចូលស្បូន

មុនពេលបញ្ចូលស្បូន យើងត្រូវធ្វើការលាងសំអាត រំងាប់មេរោគ ដោយប្រើសូលុយស្យុងពែរម៉ង់កាណាត ឬទឹក ៥-១០% ឬទឹកក្ដៅអ៊ុនៗ ។ ស្បូនត្រូវតែធានាថាស្អាត និងគ្មានមេរោគ ។

ក្នុងការបញ្ចូលគេត្រូវការមនុស្ស ៥នាក់ ក្នុងនោះមានយ៉ាងតិចមនុស្សប្រុស ៣នាក់ ។ មនុស្ស ២ នាក់ឈរអមសងខាងគោ មនុស្សទី១ យកដៃម្ខាងតោងកន្ទុយ ដៃម្ខាងទៀតកាន់កូនដំបងមួយមាំ ដោយហុចចុងមួយទៀត ឆ្លងកាត់លើខ្នងមេគោទៅកាន់មនុស្សទី២ ។ ចំណែកមនុស្សទី២ ដៃម្ខាងកាន់ដំបង និងដៃមួយទៀតកាន់រំពាត់ ។ មនុស្សផ្សេងមានាក់ទៀត កាន់បន្ទះក្តារមួយទ្រស្បូនដែលធ្លាក់នោះ ។ ក្រោយពីលាងសំអាត និងរំងាប់មេរោគស្បូនរួចមក អ្នកឈរកាន់ដំបងនៅ សងខាង ក៏សង្កត់ដំបងលើខ្នងគោ ត្រង់ខាងក្រោយស្មា ។ ដំបូងយើងចាប់បញ្ចូលជញ្ជាំងយោនីដោយប្រើកំលាំងតែមិន រុញទាំងគោទេ ។ យើងនៅតែបន្តកាន់ទ្រស្បូនដដែល ។ យើងរុញបញ្ចូលបន្តិចម្តងៗ ពេលជិតផុតហើយយើងលាបាតដៃ ដាក់ផ្ទប់ទៅនឹងចុងស្បូនដែលមិនទាន់ចូលផុត រួចច្រានបញ្ចូលយ៉ាងខ្លាំង ។ ពេលចូលផុតហើយយើងដកបន្ទះក្តារ និងដំបងចេញ ។ វាមិនមែនជាការអាក្រក់ទេ ដែលមេគោកំរើកទៅមុខទៅក្រោយនោះ ព្រោះវាអាចឱ្យស្បូនរលូលទៅកាន់ទីតាំងដើមរបស់វា ។ យើងត្រូវតែប្រាកដថា ស្បូន និងដៃស្បូនស្ថិតក្នុងទីតាំងដើមរបស់វា ។ ករណីសង្ស័យថាស្បូនបត់ ឬមិននៅចំទីតាំងត្រូវទេនោះ យើងត្រូវបញ្ចូលទឹកចំនួន ២០ លីត្រ (ទៅតាមទំងន់សត្វ) ដែលអនុញ្ញាតិឱ្យវារលាលូ និងស្ថិតក្នុងទីតាំងដើមវាវិញ ។

ជាធម្មតាក្រោយពីដាក់បញ្ចូលរួចរាល់ហើយ យើងត្រូវដាក់ខ្សែទប់កុំឱ្យស្បូនក្អែរចេញមកវិញ ។ យើងអាចស្រាយខ្សែចំណងចេញវិញក្រោយពីចងបាន ២-៣ម៉ោង ។ ការចងបិទជិតទាំងស្រុង ឬចងតឹងពេក អាចឱ្យមានគ្រោះថ្នាក់ដល់សត្វ ។

ក្នុងការបញ្ចូលគេអាចធ្វើ :

◎ *ស្ថានភាពឈរ* : ជាវិធីងាយស្រួល និងល្អបំផុត ។ គេត្រូវដាក់វានៅក្នុងសាឡុងមាំ (មើលរូប) ។

◎ *ស្ថានភាពដេក* : គេធ្វើតែក្នុងករណីមេគោខ្សោយពេក មិនអាចក្រោកឈរបាន ។ គេត្រូវចាប់លើកផ្នែកខាងក្រោយនៃមេគោឱ្យខ្ពស់បន្តិច រួចដាក់កល់ចំបើង ។

◎ *ស្ថានភាពព្យួរជើងក្រោយឡើងលើ* : ជាវិធីលំបាក និងប្រើពេលយូរ ។ យើងធ្វើយ៉ាងណាឱ្យផ្នែកខាងក្រោយហើបផុតពីដី ។ វិធីនេះអាចបណ្តាលឱ្យសត្វគ្រេច ឬថ្លោះ ឬបាក់ជើងទៀតផងពេលវាត្រដរខ្លាំង (មើលរូប) ។



របៀបបចងទប់ស្បូនក្រោយពេលបញ្ចូលរួច



របៀបបញ្ចូលស្បូនក្នុងស្ថានភាពឈរ



របៀបបញ្ចូលស្បូនក្នុងស្ថានភាពព្យួរជើងក្រោយឡើងលើ

# ជំងឺឆ្កែឆ្កួត និងជំងឺដែលបណ្តាលមកពីឆ្កែឆ្កួតខាំ



ជំងឺនេះគឺជាជំងឺឆ្លងដែលប្រកបដោយគ្រោះថ្នាក់ជាទីបំផុត និងមេរោគអាចឆ្លងពីសត្វមួយទៅសត្វមួយទៀត ផងទៅមនុស្សតាមរយៈមេរោគដែលបញ្ចេញមកតាមទឹកមាត់សត្វឈឺជំងឺនេះ ។ នេះជាជំងឺនៃសរសៃប្រសាទ ដែលទី សត្វ រឺមនុស្សត្រូវតែស្លាប់ ។

## ១.ការចំលងជំងឺ :

មេរោគនៃជំងឺនេះឆ្លងតាមរយៈ :

-ឆ្កែឆ្កួតខាំ

-ទឹកមាត់របស់ឆ្កែឆ្កួតចូលតាមមុខរបួស

-ការវះកាត់ខ្មោចសត្វដែលបណ្តាលមកពីជំងឺនេះ

-ការបរិភោគសាច់សត្វដែលកើតជំងឺនេះ

## ២.រោគសញ្ញា :

លក្ខណៈរួមនៃរោគសញ្ញានេះគឺការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នូវចរិកលក្ខណៈនិងការផ្លាស់ប្តូរសំលេងរបស់ សត្វស្លូតក្លាយជាកាច ហើយសត្វកាចក្លាយជាស្លូត ។ គេសង្កេតឃើញឆ្កែរត់ក្តោបកន្ទុយហៀរទឹកមាត់ ចេញពីផ្ទះ គ្មានទិសដៅ ហើយខាំសត្វឬមនុស្សដែលវាជួបប្រទះ ។

ចំពោះសត្វគោក្របីគេសង្កេតឃើញវាយកជើងកាយដី ស្រែករោទ៍ដោយមានសំលេងខុសធម្មតា ហូរទឹក ហាក់ដូចជាមានអ្វីនៅក្នុងបំពង់កវា ហើយរត់ចុះរត់ឡើងដោយយកក្បាលបុកនិងដើមឈើ ឬវត្ថុផ្សេងៗ ហាក់ដូច ត់តែពីការប្រយុទ្ធនិងអ្វីមួយ ។ សត្វដែលកើតជំងឺនេះនឹងត្រូវស្លាប់ក្នុងរយៈពេល ១០ថ្ងៃ ។

# មេរៀនទី ៧

# ពេលត្រឡប់ទៅភូមិវិញ

## 7.1 សេចក្តីផ្តើម

នៅក្នុងមេរៀននេះអ្នកនឹងបានរៀនអំពីការបំពេញតារាងបញ្ហាសត្វ ។ អំពីកិច្ចសន្យាជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាល និងការទំនាក់ទំនងជាមួយគ្រូរបស់អ្នកនៅពេលអ្នកត្រឡប់ទៅភូមិរបស់អ្នកវិញ ។

## 7.2 គោលបំណង

ក្រោយពីការបញ្ចប់មេរៀន សិក្ខាកាមទាំងអស់នឹងអាចមានសមត្ថភាពដូចខាងក្រោមនេះ

- ចេះបំពេញតារាងបញ្ហាសត្វ ដើម្បីអោយដឹងនូវចំនួនគោ ក្របី ជ្រូក មាន់នៅក្នុងគ្រួសារនីមួយៗ ដែលងាប់កាលពីរដូវ ច្រូតកាត់ឆ្នាំមុន និងចំនួនសត្វដែលនៅរស់ ។
- ចេះរៀបរាប់អំពីកិច្ចសន្យាជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាល
- ចេះរៀបរាប់អំពីការទំនាក់ទំនងជាមួយគ្រូ នៅពេលគ្រូទៅជួបអ្នកនៅតាមភូមិរបស់អ្នក

## 7.3 សំភារៈសំរាប់សិក្សា

- តារាងស្ថិតិចំនួនសត្វដែលស្លាប់កាលពីរដូវ ច្រូតកាត់ឆ្នាំមុន និងចំនួនសត្វដែលនៅរស់
- កិច្ចសន្យា
- សៀវភៅពតិមានជំងឺសត្វ

## 7.4 អត្ថបទ :

## ការងារបន្ថែមដែលអ្នកគួរធ្វើនៅពេលដែលអ្នកទៅព្យាបាលសត្វឈឺ

ពេលនេះអ្នកត្រូវការបំពេញបន្ថែមនូវ ៤ចំនុចសំខាន់ៗទៀត បន្ទាប់ពីការចាប់ផ្តើមព្យាបាលសត្វឈឺ ។

### ១_ប្រាប់ទៅកសិករម្ចាស់សត្វម្តងទៀត :

-ប្រាប់ទៅម្ចាស់សត្វអោយបានច្បាស់ថា តើគាត់ត្រូវធ្វើអ្វីខ្លះបន្ថែមទៀតដើម្បីថែរក្សាសត្វឈឺរបស់គាត

-សូមប្រាប់ម្ចាស់សត្វ បើសិនជាអ្នកមកពិនិត្យសត្វឈឺនេះទៀត ។

-ប្រាប់ទៅម្ចាស់សត្វថាតើ អ្នកគិតថាសត្វនេះអាចជាសះស្បើយ ឬអត់ ។

-ចូរប្រាប់ម្ចាស់សត្វថាតើគាត់គួរត្រូវធ្វើអ្វីខ្លះជាមួយសត្វផ្សេងទៀត ។

បើសិនជាខ្លួនសត្វឡើងកំដៅ ហើយអ្នកបានគិតថាមានមេរោគចូលទៅក្នុងខ្លួនសត្វ ។ ដូចនេះសត្វនេះត្រូវបង្ខាំងអោយនៅឆ្ងាយពីសត្វផ្សេងទៀតក្នុងខណះពេលដែលវាឈឺ និងរយះពេល ២អាទិត្យក្រោយពីពេលវាជាសះស្បើយឡើងវិញ។ ចូរកុំអោយសត្វឈឺ និងសត្វជាស៊ីចំណើ ឬផឹកទឹកស្នូកជាមួយគ្នា ។ នេះជាការងារមួយដែលពិបាកនឹងធ្វើ តែបើសិនជាមិនចង់អោយសត្វផ្សេងទៀតឈឺនោះ គាត់ត្រូវតែធ្វើការងារនេះ ។

អ្នកគួរតែប្រាប់ទៅម្ចាស់សត្វថា តើអ្នកគិតថាសត្វនេះនឹងត្រូវជាសះស្បើយ ឬអ្នកគិតថាសត្វនេះប្រហែលជាស្លាប់ព្រោះវាឈឺធ្ងន់ហើយមិនអាចព្យាបាលបានឡើយ ។

បើសិនជាកសិករម្ចាស់សត្វមិនទាន់ចាក់វ៉ាក់សាំងអោយសត្វគាត់ទេ អ្នកគួរតែប្រាប់ម្ចាស់សត្វអំពីរឿងនេះព្រោះការ ចាក់ថ្នាំការពារ វាមានសារៈសំខាន់ខ្លាំងណាស់ ។

ត្រូវរង់ចាំសត្វគាត់ដែលឈឺនោះ ជាសះស្បើយឡើងវិញសិនទើបធ្វើការចាក់វ៉ាក់សាំងការពារអោយសត្វរបស់គាត់ ។

បើសិនជាគាត់មានកូនសត្វដែលមិនដែលបានព្យាបាលដោយធ្វើការបញ្ចុះព្រូនទេនោះ អ្នកគួរតែប្រាប់គាត់ថាការ ទំលាក់ព្រូនវាមានសារៈសំខាន់ណាស់ ។ គ្រប់កូនសត្វទាំងអស់វាតែងតែមានព្រូនទោះបីមើលទៅហាក់ដូចជាមិនឈឺក៏ ដោយ ។ ហើយការទំលាក់ព្រូននឹងធ្វើអោយកូនសត្វកាន់តែមានសុខភាពល្អ ។

### ២_តើអ្នកគួរតែប្រាប់អ្វីដល់ប្រធានភូមិ និងកសិករនៅក្នុងភូមិ ?

បើសត្វមួយក្បាលនេះឈឺ តើសត្វដទៃទៀតដែលនៅក្នុងភូមិនេះអាចឈឺដែរឬទេ?

បើសិនជាសត្វនេះឈឺ តើមនុស្សនៅក្នុងភូមិនេះអាចឈឺដែរឺទេ?

ជាធម្មតាអ្នកប្រាប់ទៅប្រធានភូមិថា បើសិនជាមានមេរោគនៅក្នុងខ្លួនសត្វណាមួយហើយវាអាចឆ្លងទៅសត្វផ្សេងទៀត និងធ្វើអោយសត្វទាំងនោះឈឺបាន ដូចជា : មេរោគនៃជំងឺឈាមខ្មៅ ជំងឺសារទឹក ជំងឺអុតក្តាម ជំងឺបួសខ្យល់ គោក្របី ...... មេរោគប៉េស្តជ្រូក ញូវកាសមាន់ .... ។ល ។

អ្នកទាំងអស់ត្រូវតែដឹងថានៅពេលដែលមានជំងឺនៅក្នុងភូមិ ពួកគេគួរតែថែទាំសត្វអោយបានជិតដល់ហើយត្រូវទៅ [...]ភ្នាក់ងារសុខភាពសត្វភូមិបើសិនមានបញ្ហាអ្វីកើតឡើងព្រោះភ្នាក់ងារសុខភាពសត្វភូមិអាចជួយព្យាបាលសត្វបាន ។

បើសិនជាមានជំងឺឈាមខ្មៅកើតឡើងនៅក្នុងភូមិ នោះវានាំអោយមានបញ្ហាធំហើយ ព្រោះមេរោគនេះអាចឆ្លង [...]សត្វឈឺ បសត្វស្លាប់ដោយជំងឺនេះទៅមនុស្សនៅក្នុងភូមិនិងបណ្តាលអោយអ្នកភូមិស្លាប់បាន។

## ៣.អ្នកគួរតែទំនាក់ទំនងជាមួយភ្នាក់ងារសុខភាពសត្វភូមិ និងពេទ្យសត្វខេត្តដែរឬទេ ?

តើនេះគឺជាបញ្ហាធំដែលខ្ញុំមិនបានដឹងគ្រប់គ្រាន់ និងខ្ញុំត្រូវការអោយគេជួយឬ?

តើរាជរដ្ឋាភិបាលមានច្បាប់ផ្នែកបសុព្យាបាល ដែលខ្ញុំគួរតែប្រាប់ទៅពួកគេអំពីសត្វដែលឈឺពិតប្រាកដឬ ?

អ្នកគួរតែប្រាប់ទៅភ្នាក់ងារសុខភាពសត្វភូមិ ខេត្ត បើសិនជាអ្នកបានជួបប្រទះនិងសត្វគោ ក្របីដែលមានជំងឺ [...]ឈាមខ្មៅ សារទឹក អុតក្តាម បូសខ្យល់......។

## ៤.ទៅត្រួតពិនិត្យសត្វមើលម្តងទៀតក្នុងពេល ២.៣ថ្ងៃ :

អនុវត្តន៏នូវដំណាក់កាលទាំងអស់ នៃការពិនិត្យសត្វឈឺ។

យើងនឹងបន្ថែមចំនុចទាំង៤នេះទៅក្នុងល្បែងនៃការព្យាបាលសត្វនៅពេលដែលយើងលេងវា។

❄❄❄❄❄

## តារាងស្ថិតិនៃចំនួនសត្វដែលមាននៅក្នុងភូមិនិងចំនួនសត្វដែលស្លាប់កាលពីរដូវច្រូតកាត់ឆ្នាំមុន

ភូមិ.................................ឃុំ.......................................ស្រុក...............................................

ឈ្មោះភ្នាក់ងារសុខភាពសត្វភូមិ.......................................ថ្ងៃទី..........ខែ..............ឆ្នាំ...........

| ល.រ | ឈ្មោះម្ចាស់សត្វ | ចំនួនក្របី | | ចំនួនគោ | | ចំនួនជ្រូក | | ចំនួនមាន់ | |
|---|---|---|---|---|---|---|---|---|---|
| | | រស់ | ស្លាប់ | រស់ | ស្លាប់ | រស់ | ស្លាប់ | រស់ | ស្លាប់ |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| សរុប | | | | | | | | | |

ទំព័រលេខ...........

*( តមកពីទំព័រមុន)*

## ១.សត្វដែលបានព្យាបាលតាំងពីពេលជួបលើកមុន

ថ្ងៃ.......ខែ................ឆ្នាំ២០០.......)

| ប្រភេទសត្វ | សៀវភៅពតិមានជំងឺសត្វ | | ការជ្រើសរើសថ្នាំ | | កំរិតនៃការប្រើប្រាស់ថ្នាំ | | ប្រាក់ដែលគេអោយ |
|---|---|---|---|---|---|---|---|
| | ត្រូវ | ខុស | ត្រូវ | ខុស | ត្រូវ | ខុស | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# ភ្នាក់ងារសង្ខេបសកម្មភាពរបស់ភ្នាក់ងារសុខភ

ភូមិ.......................................ឃុំ...................................................ស្រុក................................................

ឈ្មោះភ្នាក់ងារសុខភាពសត្វភូមិ..................................ឈ្មោះគ្រូ..............................ថ្ងៃចុះទៅជួប......................

## ១. សត្វដែលបានព្យាបាលតាំងពីពេលជួបលើកមុន ( ថ្ងៃទី.........ខែ...............ឆ្នាំ២០០........)

| ប្រភេទសត្វ | សៀវភៅពត៌មានជំងឺសត្វ | | ការជ្រើសរើសថ្នាំ | | កំរិតនៃការប្រើប្រាស់ថ្នាំ | | ប្រាក់ដែលគេអោយ |
|---|---|---|---|---|---|---|---|
| | ត្រូវ | ខុស | ត្រូវ | ខុស | ត្រូវ | ខុស | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## ២. សត្វដែលបានចាក់ថ្នាំការពារតាំងពីពេលជួបលើកមុន

| ប្រភេទសត្វ | ចំនួនសត្វបានចាក់ថ្នាំការពារ | ប្រភេទថ្នាំការពារ | ប្រាក់គេអោយក្នុង១ក្បាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

## ៣. ថ្នាំព្យាបាលដែលបានប្រើប្រាស់អស់គិត

| ឈ្មោះថ្នាំ | ចំណុះថ្នាំដែលបានប្រើប្រាស់អស់ |
|---|---|
| | |
| | |
| | |
| | |
| | |

## ៤. ការពិពណ៌នាអំពីបញ្ហាផ្សេងៗ : ..............................................................................................

...........................................................................................................................................

...........................................................................................................................................

# ល្បែងបង្ហាញអំពីពេលមេរោគចូលទៅក្នុងខ្លួនសត្វ



## គំណត់ហេតុរបស់គ្រូ

ពេលនេះយើងនឹងនាំគ្នាលេងល្បែងដែលបង្ហាញអំពី ថាតើមានអ្វីកើតឡើងក្នុងពេលដែលសត្វធ្វើការវាយប្រហារជាមួយនិងមេរោគ ។

សិក្ខាកាមទាំងអស់គួរតែត្រូវបានអោយដឹងដូចខាងក្រោមនេះ :

(ពួកគេអាចពាក់មួក ឬដាក់ផ្លាកសំគាល់ខ្លួនគេ)

- សិក្ខាកាមម្នាក់ដើរតួជា មាត់ ត្រូវឈរក្បែរទ្វារដែលបានសន្មត់ជាមាត់
- សិក្ខាកាមម្នាក់ដើរតួជា ក្រពះ
- សិក្ខាកាមម្នាក់ដើរតួជា ពោះវៀនតូច
- សិក្ខាកាមម្នាក់ដើរតួជា ពោះវៀនធំ ត្រូវឈរក្បែរទ្វារដែលជារន្ធគូទ
- សិក្ខាកាមម្នាក់ដើរតួជា ថ្លើម សិក្ខាកាមម្នាក់ដើរតួជាច្រមុះ ត្រូវឈរក្បែរបង្អួចដែលជាច្រមុះ
- សិក្ខាកាមម្នាក់ដើរតួជា សួត
- សិក្ខាកាមម្នាក់ដើរតួជា ឈាម
- សិក្ខាកាមម្នាក់ដើរតួជា តំរងនោម
- សិក្ខាកាមម្នាក់ដើរតួជា ប្លោកនោម ត្រូវឈរក្បែរបង្អួចដែលជា លិង្គ
- សិក្ខាកាមម្នាក់ដើរតួជា កូនកណ្តុរ

- សិក្ខាកាមម្នាក់ដើរតួជា ខួរក្បាល
- សិក្ខាកាមម្នាក់ដើរតួជា មេរោគ មានកាន់កន្ត្រៃកាត់សរីរាង្គ ហើយស៊ីសរីរាង្គទាំងនោះ

ត្រូវរៀបចំសិក្ខាកាមដែលនៅក្នុងថ្នាក់អោយដូចជាសរីរាង្គដែលត្រូវរៀបចំនៅក្នុងខ្លួនសត្វ ។

## រឿង ទី ១

នៅពេលដែលអ្នកអានរឿងនេះ សិក្ខាកាមអាចធ្វើសកម្មភាពក្នុងការសំដែងដូចតទៅនេះ :

មេរោគចូលតាមមាត់ហើយធ្វើដំណើរឆ្ពោះទៅរកពោះវៀនតូច ។ នៅទីនោះហើយដែលវាចង់ចាប់ផ្តើមស៊ី ឬធ្វើការរុករាន ។ប៉ុន្តែពេលភ្លាមៗនោះមេរោគកំពុងតែប្រឈមមុខជាមួយបញ្ហា ។ ព្រោះនៅទីនោះមានគេចង់វាយប្រហារវា !!។

អ្នកយាម ( កូនកណ្តុរ ) !!! ជានិច្ចកាលពួកគេតែងតែអង្គុយផឹកស៊ីជុំវិញកន្លែងនោះ ដោយគ្មានការងារធ្វើ ។ ប៉ុន្តែពេលនេះពួកគេហាក់ដូចជាមានការងារមួយសំខាន់ណាស់ ហើយពួកគេបានប្រកាសអាសន្នភ្លាមៗថាមានមេរោគចូលមកលុកលុយដល់កន្លែងយើងហើយ ពួកយើងចូរប្រុងប្រយ័ត្ន !!! ។

អ្នកយាមព្យាយាមធ្វើការប្រយុទ្ធតទល់ជាមួយមេរោគ តែមេរោគនេះមានកំលាំងខ្លាំងហើយអ្នកយាមមិនអាចទទួលបានជ័យជំនះពីមេរោគឡើយ ។ ដូចនេះមេរោគបន្តធ្វើការរុករានស៊ីពោះវៀនតូចនេះទៀត ។ ពេលនេះពោះវៀនហាក់ដូចជាបំផ្លិចបំផ្លាញ ហើយពេលដែលចំណីនិងទឹកចេញពីក្រពះចូលទៅក្នុងពោះវៀនតូចៗ មិនអាចផ្តល់ចំណីខ្លះៗទៅអោយឈាមឡើយ និងផ្ទុយទៅវិញចំណីនិងទឹកទាំងនេះត្រូវបានបញ្ជូនមកពោះវៀនធំហើយចេញមកក្រៅតាមរន្ធគូទ

**ដូចនេះហើយដែលបណ្តាលអោយសត្វរាគរូសអាចម៍!!! ។**

បន្ទាប់មកមេរោគធ្វើដំណើរចូលទៅក្នុងឈាម ហើយពេលនេះវាកាន់តែមានកំលាំងខ្លាំងឡើង និងបង្កើតកូនចៅរុករានស៊ីផ្នែកខ្លះៗនៃថ្លើម ហើយធ្វើដំណើរជុំវិញតាមឈាម និងចាប់យកផ្នែកខ្លះៗនៃសរីរាង្គទាំងអស់ ។ ពេលនេះសរីរាង្គទាំងអស់មានការព្រួយបារម្ភយ៉ាងខ្លាំងព្រោះគ្មានអ្នកណាម្នាក់ជួយការពារពួកគេឡើយ ។ សរីរាង្គទាំងអស់ឡើងក្តៅដោយសារសកម្មភាពនេះ ។ ប៉ុន្តែពេលគេស្រែកប្រាប់ទៅខួរក្បាល ខួរក្បាលក៏ឈឺដែរ ខួរក្បាលមិនអាចធ្វើការងារគេបានឡើយ ។

**នេះហើយដែលបណ្តាលអោយសត្វឡើងកំដៅក្នុងខ្លួន!!!**

មេរោគនៅតែធ្វើការរុករានស៊ីហើយស៊ីទៀត ធ្វើអោយសត្វកាន់តែឈឺខ្លាំងឡើងៗ ។ មេរោគខ្លះបានសំរេចចិត្តចេញពីខ្លួនសត្វ ។ ពួកវាចេញពីខ្លួនសត្វតាមរយះលាមក ហើយព្យាយាមទៅរកសត្វផ្សេងទៀត........

**និងនឹងបញ្ចប់សត្វនឹងត្រូវស្លាប់ !!!**

## រឿង ទី ២

ពេលនេះសិក្ខាកាមទាំងអស់អង្គុយចុះ ។ ចូរធ្វើការសង្ខេបនូវអ្វីដែលបានកើតឡើង ដើម្បីអោយសិក្ខាកាមកត់ត្រាបានអំពី

-តើមានអ្វីកើតឡើងនៅពេលដែលមេរោគចូលទៅក្នុងខ្លួនសត្វ.......

-មេរោគចូលតាមមាត់ហើយធ្វើការចាប់ផ្តើមស៊ីពោះវៀនតូច ។

-អ្នកយាម (កូនកណ្តុរ) បានធ្វើការប្រយុទ្ធទល់ជាមួយនិងមេរោគតែមិនអាចទទួលជ័យជំនះឡើយ ហើយមេ រោគនៅតែបន្តការរុករានដដែល ។

-ពោះវៀនតូចត្រូវបានបំផ្លាញយ៉ាងតំណំ គេមិនអាចបំពេញការងារគេបានឡើយ ហើយសត្វក៏ចាប់ផ្តើមរាគអាចម៍ ។

-ខ្លួនសត្វឡើងកំដៅខ្លាំងព្រោះខួរក្បាលមិនអាចបំពេញការងារគេបាន ។

-មានមេរោគខ្លះចេញមកក្រៅតាមលាមក ហើយព្យាយាមទៅរកសត្វផ្សេងទៀត ។

-សត្វស្លាប់ ។

**នេះគឺជារឿងមួយដែលនិយាយអំពីមេរោគ និងសត្វឈឺ !!!**

# មេរៀន ទី ៣

ពេលនេះយើងនឹងនិទានរឿងមួយផ្សេងទៀត គឺរឿង :

តើយើងត្រូវជួយសត្វដែលឈឺឱ្យមានសុខភាពល្អវិញយ៉ាងដូចម្តេច?

ជាដំបូងយើងត្រូវចាក់ថ្នាំចូលទៅក្នុងខ្លួនសត្វ ហើយថ្នាំនោះអាចចូលទៅក្នុងឈាម ពេលនោះមេរោគត្រូវតែផឹកថ្នាំនោះ និងបន្ទាប់មកវានិងត្រូវស្លាប់ ឬក៏ធ្វើអោយវាចុះខ្សោយដែលជាហេតុធ្វើអោយអ្នកយាមអាចចូលទៅសំលាប់មេរោគដែលខ្សោយនោះបានយ៉ាងងាយ ។

ពេលនេះយើងចាប់ផ្តើមសំដែងរឿង ដោយអោយសិក្ខាកាមដែលដើរតួជាមេរោគ និងជាអ្នកយាមចេញមកក្រៅថ្នាក់ ដើម្បីធ្វើការបោកចំបាប់គ្នា ។

ដោយមេរោគមានកំលាំងខ្លាំងដូចនេះគេនឹងទទួលជ័យជំនះ ។ យើងធ្វើជាចាក់ថ្នាំសំលាប់មេរោគ ឬថ្នាំបង្អង់សកម្មភាពមេរោគ ទៅក្នុងកែវមួយហើយអាចទៅមេរោគផឹក........។ បន្ទាប់មកមេរោគនោះនឹងចុះខ្សោយជាងមុនហើយអ្នកយាមការពារអាចចូលទៅសំលាប់មេរោគនោះបាន!!!
មានន័យថាសត្វឈឺត្រូវបានជួយសង្គ្រោះ !!!

រឿងដែលយើងចាក់ថ្នាំចូលទៅក្នុងខ្លួនសត្វដើម្បីសំលាប់មេរោគនេះ
គឺជារឿងមួយដែលនិយាយពីមេរោគមួយ ប្រភេទ និងសកម្មភាពអ្វីដែលវាបានធ្វើក្នុងខ្លួនសត្វតែប៉ុណ្ណោះ។ នៅមានមេរោគច្រើនប្រភេទទៀតដែលយើងអាច និទានរឿងបានយ៉ាងច្រើនរឿងផ្សេងៗគ្នា ។

យើងអាចនិទានរឿងដែលមេរោគចូលទៅកាន់កន្លែងផ្សេងៗដូចជា : មេរោគចូលទៅក្នុងខ្លួនជ្រូកហើយចូល ទៅក្នុងសួតនិងធ្វើអោយជ្រូកក្អក ។

មេរោគចូលទៅក្នុងពោះវៀនកូនក្របី ធ្វើអោយឈាមហូរចេញមកក្រៅបន្តិចម្តងៗ ដែលបណ្តាលអោយកូនក្របីចុះខ្សោយ ។ មេរោគចូលទៅក្នុងស្បែកជ្រូក ធ្វើអោយស្បែកឡើងក្រហម ។

❄❄❄❄❄

តើមេរោគគ្រប់ប្រភេទទាំងអស់អាចត្រូវបានសំលាប់ដោយថ្នាំឬ ?

មានរឿងសំខាន់ៗផ្សេងទៀតដែលយើងអាចនិទាន............................

ដូចរឿងមុនដែរ មេរោគចូលទៅក្នុងខ្លួនសត្វ វាធ្វើការរុករានសរីរាង្គធ្វើអោយសត្វភាគអាចម៍ ឬទល់លាមក ដោយសារពោះវៀនតូចមិនអាចបំពេញការងាររបស់គេបាន ។ កំដៅក្នុងខ្លួនសត្វឡើងខ្ពស់។ អ្នកយាម (កូនកណ្តុរ) ខ្សោយពេក មិនអាចធ្វើការត្រួតពិនិត្យសកម្មភាពរបស់មេរោគបាន.......។

ប៉ុន្តែពេលនេះម្ចាស់សត្វបានទៅហៅភ្នាក់ងារសុខភាពសត្វភូមិ។ ភ្នាក់ងារយើងពិនិត្យមើលឃើញថាសត្វមានកំដៅឡើងខ្លាំង ក៏ធ្វើការព្យាបាលសត្វដោយចាក់ថ្នាំសំលាប់ ឬថ្នាំបង្អង់សកម្មភាពមេរោគ។

នៅក្នុងខ្លួនសត្វមេរោគកំពុងតែធ្វើការប្រយុទ្ធជាមួយនិងអ្នកយាមការពារដែលមានកំលាំងខ្សោយ។ ពេលនោះថ្នាំចូលទៅដល់ក្នុងឈាម ហើយមេរោគផឹកថ្នាំនោះ..........បន្ទាប់មកមេរោគញញឹមញញែញ ហាក់ដូចជាគ្មានបញ្ហាអ្វីកើតឡើងចំពោះវាសោះ។

ថ្នាំនេះមិនអាចធ្វើអោយមេរោគប្រភេទនេះឈឺចាប់បានឡើយ... គួរអោយអស្ចារ្យមែន!!!! ដូច្នេះសត្វត្រូវស្លាប់!!!

មានមេរោគប្រភេទខ្លះមិនអាចសំលាប់ដោយថ្នាំឡើយ ។ មានវិធីតែមួយគត់ដែលយើងអាចសំលាប់មេរោគនេះបាន គឺដោយធ្វើអោយអ្នកយាមការពារ (កណ្តុរ) មានកំលាំងខ្លាំងមុនពេលដែលមេរោគចូលទៅក្នុងខ្លួនសត្វ។ នោះគឺជាការការពារ !!!!

យើងនិងរៀនអំពីការការពារនេះនៅក្នុងមេរៀនទី ៤ ។

# 1.4.6 សកម្មភាព



# ល្បែងអំពីការចិញ្ចឹមសត្វ

(សំរាប់ហាត់សាកល្បងអំពីវិធីចិញ្ចឹមសត្វអោយមានសុខភាពល្អ  និងការពារកុំអោយសត្វឈឺ)

វគ្គបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ
ដើម្បីលើកកំពស់វិស័យផលិតកម្មនិងបសុព្យាបាលតាម
ភូមិនៃប្រទេសកម្ពុជា



# សេចក្ដីផ្ដើម

ល្បែងនេះត្រូវបានរៀបចំឡើងដើម្បីអោយសិស្សចងចាំនូវ កត្តា ៤ យ៉ាង ដែលត្រូវការចាំបាច់ក្នុងការចិញ្ចឹមសត្វអោយមានសុខភាពល្អ និងការពារសត្វកុំអោយឈឺ ។ នៅក្នុងល្បែងនេះត្រូវមានអ្នកលេង ៣នាក់ ដែលម្នាក់ៗដើរតួជាកសិករ ( ម្ចាស់សត្វក្នុងភូមិជាមួយគ្នា) ។ កសិករម្នាក់ៗគេមានចិញ្ចឹមសត្វគោ ជ្រូក និងមាន់សំរាប់លក់ ។ កសិករម្នាក់ៗគេត្រូវធានាថាធ្វើអោយសត្វទាំងនោះបានទទួលនូវកត្តា ៤យ៉ាងដែលធ្វើអោយសត្វមានសុខភាពល្អ លូតលាស់ឆាប់រហ័ស និងបន្តពូជបានល្អដូចជា :

- ត្រូវមានកន្លែងចិញ្ចឹមស្អាត
- ត្រូវមានចំណើនិងទឹកគ្រប់គ្រាន់
- ត្រូវបានបញ្ចុះព្រូនអោយបានទៀងទាត់
- ត្រូវចាក់វ៉ាក់សាំងអោយបានទៀងទាត់

ល្បែងនេះនិងត្រូវបានលេងលើកដំបូងនៅក្នុងមេរៀនទី៤ ហើយនិងត្រូវលេងបន្តបន្ទាប់ទៅតាមកម្មវិធី នៃការរីកចំរើនរបស់សិស្សនៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ ។ នៅពេលលេងជាបន្តបន្ទាប់រហូតដល់ចប់នៃវគ្គ បណ្ដុះបណ្ដាលនេះសិក្ខាកាមនឹងអាចមានសមត្ថភាពក្នុងការរៀបរាប់អំពីកម្មវិធីបញ្ចុះព្រូន និងកម្មវិធីចាក់វ៉ាក់សាំងទៅតាមប្រភេទសត្វនីមួយៗនិងអាចដាក់ឈ្មោះនៃប្រភេទថ្នាំដែលបានប្រើ និងគណនាតំលៃថ្នាំទាំងនោះ ។

## ការបង្កើតល្បែង

សំភារៈដែលត្រូវការ :

- ក្រដាសកាតុង ( ផ្ទាំងធំ)
- ប៊ិច ប៊ិចហ្វឺត កន្ត្រៃ និងបន្ទាត់
- កៅស៊ូកង បង់ស្អិត

ការបង្កើត ១កំប្លេរនៃល្បែងនេះ

១-កាត់ក្រដាសធ្វើជាកាតអោយបានចំនួន៥៥ សន្លឹក ដែលមានទំហំ ៧ស.ម និង ៥ស.ម ។ ក្នុងចំណោមកាតទាំង ៥៥នេះ មានកាតចំនួន ៤៦ ជា*កាតសំរាប់ការចិញ្ចឹមសត្វ* និង កាតនៅសល់ចំនួន ៩ ទៀតគឺជា*កាតជំងឺសត្វ* ។

២-ដើម្បីបង្កើតកាតសំរាប់ការចិញ្ចឹមសត្វ ៤៦នេះ ត្រូវសរសេរលើផ្នែកម្ខាងនៃកាតដូចបានបង្ហាញនៅក្នុងទំព័រក្រោយនេះ( អ្នកអាចថតចំលងកាតដែលមាននៅក្នុង ទំព័រនេះហើយយកទៅបិទលើកាតក្រដាស កាតុងដែលអ្នកបាន រៀបចំដូចបានប្រាប់ខាងលើ) :

ធ្វើកាតនេះអោយបានចំនួន ១៥-២០

កាតនេះតំណាងអោយ ទឹក និងចំណើគ្រប់គ្រាន់ ហើយនិងកន្លែងចិញ្ចឹមល្អ ។ បើសិនជាសត្វអ្នកគ្មានព្រូនទេនោះ វានឹងលូតលាស់បានលឿន ។ ដូច្នេះអ្នកអាចរំកិលវាទៅមុខមួយថ្នាក់ ( ឡើងតំលៃបានមួយជី) បើសិនជាសត្វអ្នកមានព្រូននោះអ្នកមិនអាចប្រើកាតនេះឡើយ ។ ដូចនេះត្រូវដាក់កាតនេះទៅក្នុងគំនរកាតវិញ ។

ធ្វើកាតនេះអោយបានចំនួន ១៥-២០

នេះជាថ្នាំសំរាប់ទំលាក់ព្រូន ។ បើសត្វអ្នកមានព្រូន សូមប្រើថ្នាំនេះដើម្បីទំលាក់ព្រូនអោយសត្វអ្នកចេញឱ្យអស់ ។
បើសិនសត្វអ្នកគ្មានព្រូនទេ ត្រូវដាក់កាតនេះទៅក្នុងគំនរកាតវិញ ។

ធ្វើកាតនេះអោយបានចំនួន ២

កាតនេះតំណាងអោយវ៉ាក់សាំងការពារជំងឺសារទឹក គោ ក្របី ។
រក្សាកាតនេះសំរាប់ចាក់វ៉ាក់សាំងការពារជំងឺសារទឹក គោ ក្របី របស់អ្នករាល់ឆ្នាំ ។
បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះហើយ នោះត្រូវដាក់កាតនេះទៅក្នុងគំនរកាតវិញ ។

ធ្វើកាតនេះអោយបានចំនួន ២

កាតនេះតំណាងអោយវ៉ាក់សាំងការពារជំងឺបូសខ្យល់ គោ ក្របី ។
រក្សាកាតនេះសំរាប់ចាក់វ៉ាក់សាំងការពារជំងឺបូសខ្យល់ គោ ក្របី របស់អ្នករាល់ឆ្នាំ ។
បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះហើយ នោះត្រូវដាក់កាតនេះទៅក្នុងគំនរកាតវិញ ។

នៅពេលដែលអ្នកបានបញ្ចប់ដំណាក់កាលទី២នេះហើយ នោះបានន័យថាអ្នកត្រូវបានរៀបចំរួចជាស្រេចនូវកាតសំរាប់ការចិញ្ចឹមសត្វចំនួន ៤៦ក្បាលហើយ ។

៣-នៅសល់ ៩កាតទៀតនេះ គឺជាកាតជំងឺឆ្លងសត្វ ។ កាតទាំងអស់នឹងប្រាប់អ្នកអំពីប្រភេទនៃមេរោគដែលចូលមកយាយី សត្វនៅក្នុងភូមិ ។

ដើម្បីបង្កើតកាតជំងឺនេះត្រូវគូរលើផ្នែកម្ខាងនៃកាតនូវរូបមេរោគដ៏កាចមួយដូចជាបង្ហាញនៅផ្នែកខាងស្តាំនេះស្រាប់ ។



នៅលើផ្នែកម្ខាងទៀតនៃកាតទាំងនេះត្រូវសរសេរពត៌មានដូចខាងក្រោមនេះ (អ្នកអាចថតចំលងកាតដែល នៅក្នុងទំព័រនេះហើយយកទៅបិទលើកាតក្រដាសកាតុងដែលអ្នកបានរៀបចំដូចបាន ប្រាប់ខាងលើ) :

ធ្វើកាតនេះអោយបានចំនួន ២

| |
|---|
| មេរោគនៃជំងឺសារទឹកចូលមកយាយីដល់គោ ក្របីនៅក្នុងភូមិយើងហើយ ។<br>កូនគោក្របីដែល មិនបានចាក់វ៉ាក់សាំងការពារ ត្រូវឈឺហើយ ស្លាប់ ។<br>បើសិនជាគោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំង ការពាររាល់ឆ្នាំ នោះគ្មានបញ្ហាអ្វីឡើយ ។ |

ធ្វើកាតនេះអោយបានចំនួ

| |
|---|
| មេរោគនៃជំងឺឈាមខ្មៅចូលមកយាយីដល់គោ ក្របីនៅក្នុងភូមិយើងហើយ ។ គោ ក្របីដែ មិនបានចាក់វ៉ាក់សាំងការពារ ត្រូវឈឺហើ ស្លាប់ ។<br>បើសិនជាគោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំ ការពាររាល់ឆ្នាំ នោះគ្មានបញ្ហាអ្វីឡើយ ។ |

ធ្វើកាតនេះអោយបានចំនួន១

| |
|---|
| មេរោគនៃជំងឺបួសខ្យល់ចូលមកយាយីដល់គោ ក្របីនៅក្នុងភូមិយើងហើយ ។ កូនគោដែល មិនបានចាក់វ៉ាក់សាំងការពារ ត្រូវឈឺហើយ ស្លាប់ ។<br>បើសិនជាគោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំង ការពាររាល់ឆ្នាំ នោះគ្មានបញ្ហាអ្វីឡើយ ។ |

ធ្វើកាតនេះអោយបានចំនួ

| |
|---|
| មេរោគនៃជំងឺអុតក្តាមចូលមកយាយីដល់គោ ក្របីនៅក្នុងភូមិយើងហើយ ។កូនគោក្របីដែល មិនបានចាក់វ៉ាក់សាំងការពារជំងឺនេះត្រូវឈឺ ។ ដូច្នេះត្រូវរំកិលគោក្របីនោះមកក្រោយមួយ ថ្នាក់ (មួយជី) ។<br>បើសិនជាគោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំ ការពាររាល់ ៦ខែម្តង នោះគ្មានបញ្ហាអ្វីឡើយ ។ |

ធ្វើកាតនេះអោយបានចំនួន២

| |
|---|
| កាតនេះតំណាងអោយវ៉ាក់សាំងការពារជំងឺ ឈាមខ្មៅ គោ ក្របី ។<br>រក្សាកាតនេះសំរាប់ចាក់វ៉ាក់សាំងការពារជំងឺ ឈាមខ្មៅ គោ ក្របី របស់អ្នករាល់ឆ្នាំ ។<br>បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះ ហើយ នោះត្រូវដាក់កាតនេះទៅក្នុងគំនរកាត វិញ ។ |

ធ្វើកាតនេះអោយបានចំនួន២

| |
|---|
| កាតនេះតំណាងអោយវ៉ាក់សាំងការពារជំងឺ អុតក្តាម គោ ក្របី ។<br>រក្សាកាតនេះសំរាប់ចាក់វ៉ាក់សាំងការពារជំងឺ អុតក្តាមឱ្យ គោ ក្របី របស់អ្នករាល់៦ខែម្តង ។<br>បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះ ហើយ នោះត្រូវដាក់កាតនេះទៅក្នុងគំនរកាត វិញ ។ |

ធ្វើកាតនេះអោយបានចំនួន២

កាតនេះតំណាងអោយវ៉ាក់សាំងការពារជំងឺប៉េស្តជ្រូក ។

រក្សាកាតនេះសំរាប់ចាក់វ៉ាក់សាំងការពារជំងឺប៉េស្តជ្រូក របស់អ្នករាល់៦ខែម្តង ។

បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះហើយ នោះត្រូវដាក់កាតនេះទៅក្នុងគំនរកាតវិញ ។

ធ្វើកាតនេះអោយបានចំនួន២

កាតនេះតំណាងអោយវ៉ាក់សាំងការពារជំងឺញូវកាសមាន់ ។

រក្សាកាតនេះសំរាប់ចាក់វ៉ាក់សាំងការពារជំងឺញូវកាសមាន់ របស់អ្នករាល់៣ខែម្តង ។

បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះហើយ នោះត្រូវដាក់កាតនេះទៅក្នុងគំនរកាតវិញ ។

ធ្វើកាតនេះអោយបានចំនួន២

មានមេរោគបង្កគ្រោះថ្នាក់ចូលភូមិយើង ហើយដាក់កាតនេះទៅក្នុងគំនរកាតវិញ ហើយចាប់យកកាតពីគំនរកាតជំងឺមួយសន្លឹកដើម្បីឱ្យដឹងថាតើមេរោគណាចូលមក ។

ធ្វើកាតនេះអោយបានចំនួន២

មេរោគនៃជំងឺប៉េស្តជ្រូកចូលមកយាយីដល់គោក្របីនៅក្នុងភូមិយើងហើយ ។ សត្វជ្រូកដែលមិនបានចាក់វ៉ាក់សាំងការពារ ត្រូវឈឺហើយស្លាប់ ។

បើសិនជាគោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំងការពាររាល់ឆ្នាំ នោះគ្មានបញ្ហាអ្វីឡើយ ។

ធ្វើកាតនេះអោយបានចំនួន២

មេរោគនៃជំងឺញូវកាសចូលមកយាយីដល់គោក្របីនៅក្នុងភូមិយើងហើយ ។ សត្វជ្រូកដែលមិនបានចាក់វ៉ាក់សាំងការពារ ត្រូវឈឺហើយស្លាប់ ។

បើសិនជាគោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំងការពាររាល់ឆ្នាំ នោះគ្មានបញ្ហាអ្វីឡើយ ។

៤-ការធ្វើផ្ទាំងក្រដាសសម្រាប់លេងល្បែងនេះ :

នៅលើផ្ទាំងក្រដាសកាតុងធំមួយត្រូវគូរ ដូចបានគូរបង្ហាញនៅលើទំព័រខាងក្រោយ ។ រូបប្រអប់រាងបួនជ្រុងទ្រវែ នីមួយៗជាកន្លែងដាក់កាតសំរាប់ការចិញ្ចឹមសត្វ និងកាតជំងឺសត្វ ។ ដូចនេះអ្នកអាចប្រើកាតនេះមួយសំរាប់ធ្វើជាគំរូដើម្បី ជួយក្នុងការគូរប្រអប់ទាំងនោះនៅលើផ្ទាំងក្រដាសកាតុងធំ ។

៥-ការងារចុងក្រោយនេះគឺជាការបង្កើតរូបសត្វ ។ យើងត្រូវការមានរូបសត្វទាំងនេះចំនួនពាកំប្លេរ ។ ម្ចាស់ស ម្នាក់ត្រូវមានរូបសត្វ ១កំប្លេរ ដែលកំប្លេរនីមួយៗមាន :

-គោ ២ក្បាល ( មួយជាគោពេញវ័យ និងមួយជាកូនគោ)

-ជ្រូក ២ក្បាល

-មាន់មួយហ្វូង

នៅទំព័រទី.....មានរូបសត្វដែលអ្នកអាចថតចំលងយកមកធ្វើជារូបសត្វសំរាប់លេងល្បែងនេះបាន ។ បើមិនរ ដូច្នោះ ទេអ្នកគូររូបសត្វទាំងនោះដោយខ្លួនឯង ។ រូបសត្វនីមួយៗដែលបានធ្វើនេះគឺត្រូវធ្វើយ៉ាងណាអោយវាអាចឈរនៅ លើផ្ទាំងក្រដាសបាន ។

## ការលេងល្បែង

នៅក្នុងល្បែងនេះត្រូវមានអ្នកលេងជាកសិករចំនួន ៣នាក់ដែលម្នាក់ៗគឺជាអ្នកចិញ្ចឹមសត្វគោក្របី មាន់សំរាប់លក់នៅទីផ្សារ ។ កសិករម្នាក់ៗមានចិញ្ចឹមគោ២ក្បាល( គោធំ១និងកូនគោ) ជ្រូក២ក្បាល និងមាន់មួយហ្វូង ។

នៅពេលចាប់ផ្តើមលេងល្បែងនេះសត្វគោ និងជ្រូកនីមួយៗមានតំលៃ ១ជី ។ ចំណែកមាន់១ហ្វូងមានតំលៃ១ជីផង នៅពេលដែលសត្វត្រូវបានបញ្ចុះព្រូន និងមានចំណីទឹកគ្រប់គ្រាន់ ហើយនិងកន្លែងចិញ្ចឹមល្អសត្វទាំងនោះនិងមានការធាត់ល្អ តំលៃសត្វនីមួយៗនៅពេលដែលកសិករយកទៅលក់នៅទីផ្សានឹងឡើងបាន ៤ជីក្នុងមួយក្បាល ( គោ និងជ្រូក)ហ្វូង ( មាន់) ។

នៅក្នុងល្បែងនេះមានមេរោគដែលបង្កគ្រោះថ្នាក់បានចូលមកយាយីដល់សត្វនៅក្នុងភូមិ ។បើសិនជាសត្វទាំងនោះមិនបានចាក់ថ្នាំការពារទេ សត្វទាំងនោះនឹងត្រូវស្លាប់( ឬឈឺ) ពេលនោះកសិករនឹងត្រូវ បាត់បង់ប្រាក់ចំណូល ( ខាត) ។

ចុងបញ្ចប់នៃល្បែងនេះ នៅពេលដែលកសិករម្នាក់អាចចិញ្ចឹម និងនាំយកសត្វទាំងអស់របស់គាត់ទៅលក់ដល់ទីផ្សារ ទោះបីកសិករនេះមាននៅសល់តែមាន់មួយហ្វូងក៏ដោយ ( ព្រោះគោ និងជ្រូកបានស្លាប់អស់) នៅពេលកសិករអាចចិញ្ចឹម មាន់នោះ និងនាំទៅលក់ដល់ទីផ្សារ ហើយល្បែងនេះនឹងសន្មត់ថាចប់ ។ នៅទីបញ្ចប់នៃល្បែងនេះ កសិករម្នាក់ៗត្រូវគណនាតំលៃសរុបរបស់សត្វទាំងអស់ដែលមាននៅលើកន្លែងចិញ្ចឹមលើផ្ទាំងក្រដាសកាតុងនៃល្បែងនេះ និងតំលៃសត្វដែលលក់បាននៅលើទីផ្សារ ។ កសិករដែលបានមាសច្រើនជាងគេគឺជាអ្នកឈ្នះ ។

ត្រូវរៀបចំសិក្ខាកាមមួយក្រុមៗដែលមានគ្នា៣នាក់ ហើយលេងល្បែងនេះតាមការណែនាំដូចខាងក្រោមនេះ :

### ការរៀបចំផ្ទាំងក្រដាសកាតុងសំរាប់ល្បែងនេះ

- ដាក់កាតជំងឺចំនួន៩និងកាតសំរាប់ការចិញ្ចឹមសត្វចំនួន៤៦ទៅក្នុងប្រអប់ដាក់កាតនេះដែលនៅកណ្តាលផ្ទាំងក្រដាសកាតុង
- អ្នកលេងល្បែងនេះម្នាក់ៗត្រូវដាក់សត្វរបស់ខ្លួននៅលើប្រអប់ដែលមានតំលៃ( ១ជី)
- ដាក់កៅស៊ូកងវង់ទៅក្នុងរូបសត្វនីមួយៗ ដើម្បីជាតំណាងអោយព្រូនដែលកំពុងរស់នៅក្នុងខ្លួនសត្វទាំងនោះ ។
- ដាក់កៅស៊ូកងវង់នៅលើប្រអប់ដែលមានតំលៃ ២ជី និង៣ជី ទាំងអស់ដើម្បីជាតំណាងអោយស៊ុតព្រូនដែលមាននៅពាសពេញភូមិ ដែលធ្វើអោយសត្វនៅតែស៊ីចំណីដោយស៊ុតព្រូននេះជារៀងរហូត ទោះបីសត្វទាំងនោះទើបតែបានធ្វើការទំលាក់ព្រូនហើយក៏ដោយ ។

### ការចិញ្ចឹមសត្វនៅក្នុងភូមិ :

អ្នកលេង ( កសិករ) ល្បែងនេះទាំងអស់៣នាក់ ត្រូវធ្វើការសំរេចចិត្តថាតើត្រូវអោយអ្នកណាចាប់ផ្តើមមុនគេ ។ បន្ទាប់មកកសិករដែលសំរេចចិត្តអោយចាប់ផ្តើមមុននោះ ត្រូវធ្វើការចាប់ផ្តើមដោយចាប់យកកាតសំរាប់ចិញ្ចឹមសត្វមួយសន្លឹកដែលនៅខាងលើគេពីគំនរកាតនោះ ហើយអានខ្លាំងដើម្បីអោយកសិករផ្សេងទៀតបានលឺ ថាតើនឹងមានអ្វីកើត

ឡើង ។ កសិករ២នាក់ទៀតមិនត្រូវបានអនុញ្ញាតិអោយចាប់យកកាតនោះឡើយ លុះត្រាតែកសិករទី១ បានបញ្ចូលរបស់ខ្លួន។

- ## កាតសំរាប់ចំណី និងកន្លែងចិញ្ចឹម :

កាតនេះតំណាងអោយចំណី និងកន្លែងចិញ្ចឹមរបស់សត្វ។ អ្នកអាចប្រើកាតនេះបានលុះត្រាតែ គោ ជ្រូកនិងមាន់របស់អ្នកគ្មានព្រូន (គ្មានកៅស៊ូកងវង់)។ បើសិនជាសត្វរបស់អ្នកគ្មានព្រូនទេ អ្នកអាចប្រើកាតនេះបានដោយយកវាទៅដាក់ក្នុងប្រអប់ដែលជាកន្លែងត្រូវរំកិលសត្វរបស់អ្នកទៅមុខ (ប្រអប់តំលៃលើសពី ១ជី)។

កៅស៊ូកងវង់ដែលនៅក្នុងប្រអប់២ និង៣ជី គឺជាព្រូនដែលអាចឆ្លងចូលទៅក្នុងខ្លួនសត្វអ្នកម្តងទៀត ។ ដូច្នេះពេលដែលសត្វរបស់អ្នកទៅដល់កន្លែងនោះ អ្នកត្រូវចាប់យកកៅស៊ូកងដែលនៅកន្លែងនោះបញ្ចូលទៅក្នុងខ្លួនសត្វរបស់អ្នក។ ដោយសារសត្វរបស់ត្រូវមានព្រូនសារជាថ្មីម្តងទៀត ដូច្នេះត្រូវរង់ចាំរហូតដល់ពេលអ្នកធ្វើការទំលាក់ព្រូនជាថ្មីម្តងទៀត ទើបអ្នកអាចប្រើកាតចំណី និងកន្លែងចិញ្ចឹមនេះបានទៀត។

នៅពេលសត្វរបស់អ្នកមានព្រូន អ្នកមិនអាចប្រើកាតនេះបានទេដូច្នេះអ្នកត្រូវយកកាតនេះដាក់ទៅផ្នែកខាងក្រោម នៃកាតនេះវិញ។

- ## កាតសំរាប់ថ្នាំសំលាប់ព្រូន

កាតនេះតំណាងឱ្យថ្នាំសំលាប់ព្រូនដែលអ្នកអាចយកមកប្រើដើម្បីធ្វើការទំលាក់ព្រូនអោយគោ ជ្រូក មាន់របស់អ្នកបាន។ បើសិនជាសត្វរបស់អ្នកមានព្រូនអ្នកអាចប្រើកាតនេះដើម្បីទំលាក់ព្រូន ដោយយកព្រូន (កៅស៊ូកងវង់) ចេញពីខ្លួនសត្វ ហើយដាក់ទៅផ្នែកម្ខាងនៃក្រដាសកាតុងជាមួយនិងកាតថ្នាំនេះ ។ ប៉ុន្តែសត្វដែលអ្នកបានធ្វើការទំលាក់ព្រូននេះមិនអាចរំកិលទៅមុខ (ឡើងថ្លៃ ១ជី) បានឡើយ គឺនៅរងចាំរហូតដល់អ្នកចាប់កាតចំណី និងកន្លែងចិញ្ចឹមបាន។

នៅពេលដែលអ្នកគ្មានសត្វដែលមានព្រូនទេនោះ អ្នកមិនអាចប្រើកាតថ្នាំនេះបានឡើយ ។ ដូច្នេះអ្នកត្រូវយកកាតនេះដាក់ទៅផ្នែកខាងក្រោមនៃគំនរកាតនេះវិញ។

- ## កាតចាក់វ៉ាក់សាំង

បើសិនជាអ្នកចាប់បានកាតនេះ អ្នកអាចប្រើកាតនេះដើម្បីចាក់វ៉ាក់សាំងអោយសត្វរបស់អ្នកទៅតាមអ្វីដែលបានសរសេរលើកាតនោះ ។ ហើយត្រូវដាក់កាតនោះទៅក្នុងប្រអប់វ៉ាក់សាំងដែលនៅខាងក្រោយសត្វ ដូចមានបង្ហាញនៅក្នុងផ្ទាំងក្រដាសកាតុងស្រាប់ ។ បើកាតវ៉ាក់សាំងនេះបានប្រើទៅលើប្រភេទសត្វណាមួយហើយ បានន័យថាសត្វនោះត្រូវបានការពារនិងជំងឺនោះរហូតដល់ទីបញ្ចប់នៃល្បែងនេះ ព្រោះកាតនេះតំណាងអោយកម្មវិធីចាក់វ៉ាក់សាំងយ៉ាងទៀងទាត់ដល់សត្វ ។ បើសិនជាសត្វរបស់អ្នកបានចាក់វ៉ាក់សាំងនេះរួចហើយ ឬ ក៏សត្វអ្នកស្លាប់ហើយនោះ អ្នកមិនអាចប្រើកាតនេះបានឡើយ។ ដូច្នេះអ្នកត្រូវដាក់កាតនេះទៅផ្នែកខាងក្រោមនៃគំនរកាតនេះវិញ។

• **កាតមេរោគ**

នៅពេលដែលអ្នកចាប់បានកាតនេះហើយ មានន័យថាមេរោគបានចូលមកយាយីដល់សត្វរបស់កសិករទាំងអស់គ្នា នៅ ក្នុងភូមិនេះ ។ បន្ទាប់មកចូរអ្នកដាក់កាតនេះចូលទៅផ្នែកខាងក្រោមនៃគំនរកាតនេះវិញ ហើយត្រូវចាប់យកកាតមួយទៀត ពីគំនរកាតជំងឺ ដើម្បីដឹងថាតើមេរោគណាមួយដែលបានចូលមកយាយីដល់សត្វនៅក្នុងភូមិ ។

• **ជំងឺសត្វនៅក្នុងភូមិ**

-កាតជំងឺ

នៅពេលដែលកសិករចាប់បានកាតដែលសរសេរថា មានមេរោគចូលមកយាយីដល់សត្វនៅក្នុងភូមិយើងហើយនោះកសិករ នោះត្រូវដាក់កាតនោះចូលទៅផ្នែកខាងក្រោមនៃគំនរកាតនេះវិញ ហើយត្រូវចាប់យកកាតមួយទៀតពីគំនរកាតជំងឺដើម្បីដឹង ថាតើមេរោគណាមួយដែលបានចូលមកយាយីដល់សត្វនៅក្នុងភូមិ ។

អានពត៌មានដែលបានសរសេរលើកាតជំងឺ ដែលចាប់បាននេះ ដើម្បីអោយដឹងថាតើសត្វណាមួយដែលត្រូវបានឆ្លងជំងឺនេះត្រូវចង់ចាំថាមេរោគចូលមកធ្វើការយាយីដល់សត្វរបស់កសិករទាំង ៣នាក់ គឺមិនមែនចូលមកយាយីតែសត្វរបស់កសិករ ដែលជាអ្នកចាប់បានកាតនេះទេ ។

ចំពោះសត្វដែលចិញ្ចឹមបានទៅលក់ដល់ទីផ្សារហើយ មិនអាចឆ្លងជំងឺនេះបណ្តាលមកពីមេរោគដែលចូលមកយាយីដល់សត្វនៅក្នុងភូមិនោះឡើយ ។

## ការលេងល្បែងរំលឹកឡើងវិញ

ល្បែងនេះត្រូវតែលេងអោយបានច្រើនដងនៅក្នុងពេលបណ្តុះបណ្តាលនេះ ទៅតាមកាលវិភាគនៃវគ្គបណ្តុះបណ្តាលនេះមានស្រាប់ ។ ប៉ុន្តែសិក្ខាកាមអាចលេងច្រើន ឬតិចដងជាងនេះ អាស្រ័យទៅតាមល្បឿននៃការយល់ដឹងរបស់សិក្ខា កាមនូវគោលបំណងរបស់មេរៀន ។ អ្នកត្រូវផ្តល់កំប្លែរនៃល្បែងនេះ អោយបានគ្រប់គ្រាន់ដល់សិក្ខាកាមដូចនេះដើម្បី អោយសិក្ខា កាមទាំងអស់លេងល្បែងនេះក្នុងពេលតែមួយ ។

ក្រោយពីបញ្ចប់មេរៀនទី៥ ពេលដែលសិក្ខាកាមបានរៀនអំពីឈ្មោះ កំរិតនៃការប្រើប្រាស់និងតំលៃរបស់វ៉ាក់សាំង និង ថ្នាំទំលាក់ព្រូន ។ ពត៌មានទាំងនេះអាចយកមកប្រើប្រាស់នៅក្នុងល្បែងនៃការចិញ្ចឹមសត្វនេះបាន ។ ដើម្បីអោយមាន ការប្រើប្រាស់ពត៌មាននេះ គ្រូត្រូវផ្តល់នូវពត៌មានមួយចំនួនបន្ថែមទៀតអំពីទំងន់សត្វ

ឧទាហរណ៍ :

| ប្រភេទសត្វ | សត្វគោ | ជ្រូក | មាន់ |
|---|---|---|---|
| ប្រអប់ ៣ជី | គោពេញវ័យ ៣០០គក្រ<br>គោជំទង់ ១៥០គក្រ | ជ្រូក ២ក្បាល<br>១ក្បាលទំងន់១០០គក្រ | មាន់ ១០០ក្បាល<br>ទំងន់សរុប ១២០គក្រ |
| ប្រអប់ ២ជី | គោពេញវ័យ ៣០០គក្រ<br>គោជំទង់ ១០០គក្រ | ជ្រូក ២ក្បាល<br>១ក្បាលទំងន់៥០គក្រ | មាន់ ៥០ក្បាល<br>ទំងន់សរុប ៦០គក្រ |
| ប្រអប់ ១ជី | គោពេញវ័យ ៣០០គក្រ<br>គោជំទង់ ៥០គក្រ | ជ្រូក ២ក្បាល<br>១ក្បាលទំងន់២០គក្រ | មាន់ ២០ក្បាល<br>ទំងន់សរុប ៣០គក្រ |

តាមរយៈពតិមាននេះ សិក្ខាកាមអាចគណនាកំរិតនៃវ៉ាក់សាំង និងថ្នាំព្យាបាលដែលពួកគេប្រើសំរាប់សត្វ នៅចុង បញ្ចប់នៃល្បែងនេះ សិក្ខាកាមអាចគណនាប្រាក់សរុបដែលពួកគេបានចំណាយទៅលើវ៉ាក់សាំង និងថ្នាំព្យាបាល ។

នៅក្នុង ២ ទំព័របន្ទាប់មានរូបគំនូរសំរាប់ធ្វើជាគំរូក្នុងការរៀបចំផ្ទាំងក្រដាសកាតុងសំរាប់ល្បែងចិញ្ចឹមសត្វនេ និងរូបសត្វមួយចំនួនទៀតដែលអ្នកអាចថតចំលង និងកាត់មកធ្វើជារូបសត្វដែលកសិករនឹងត្រូវចិញ្ចឹមនៅក្នុងល្បែងនេះ ។

*******



# ផ្ទាំងក្រដាសកាតុងធំសំរាប់ការលេងល្បែងចិញ្ចឹមសត្វ



# ល្បែងអំពីការព្យាបាលសត្វ

## (សំរាប់ហាត់សាកល្បងនូវសកម្មភាពដែលត្រូវធ្វើនៅពេលដែលអ្នកទៅពិនិត្យសត្វឈឺ)

វគ្គបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ
ដើម្បីលើកកំពស់វិស័យផលិតកម្មនិងបសុព្យាបាលតាម
ភូមិនៃប្រទេសកម្ពុជា



# សេចក្តីផ្តើម

ល្បែងនេះត្រូវបានរៀបចំឡើងដើម្បីអោយសិស្សបានចាំនូវដំណាក់កាលទាំង៦ ដែលភ្នាក់ងារសុខភាពសត្វភូមិ ត្រូវអនុវត្តតាម នៅពេលដែលគេទៅពិនិត្យសត្វឈឺនៅក្នុងភូមិរបស់គេ ។ ក្នុងការលេងល្បែងនេះ ត្រូវមានអ្នកលេងពីរនាក់ ម្នាក់ជាម្ចាស់សត្វ និងម្នាក់ទៀតជាភ្នាក់ងារសុខភាពសត្វភូមិ ។ ម្ចាស់សត្វបានទៅហៅ ភ្នាក់ងារសុខភាពសត្វភូមិដើម្បី មកមើលសត្វឈឺ ។ សិក្ខាកាមនឹងបានហាត់រៀនអំពីការទៅសួរម្ចាស់សត្វ និងសរសេរបំពេញពតិមានដែលបានសួរទៅក្នុង សៀវភៅពតិមានជំងឺសត្វ និងរៀនធ្វើការសង្ស័យអំពីមូលហេតុដែលធ្វើអោយសត្វឈឺ និងបានហាត់ធ្វើការសំរេចចិត្តក្នុង ការព្យាបាលសត្វអោយជាសះស្បើយឡើងវិញ ។

ការលេងល្បែងនេះលើកទីមួយ គឺត្រូវលេងក្រោយពេលបញ្ចប់មេរៀនទី៣ និងបន្ទាប់មកត្រូវលេងបន្តបន្ទាប់ ទៅតាមកម្មវិធីនៃការរីកចំរើនរបស់សិស្សនៅក្នុងវគ្គបណ្តុះបណ្តាលនេះ ។

ក្នុងពេលលេងល្បែងនេះ ជាលើកដំបូងសិក្ខាកាមនឹងអាចជ្រើសរើសនូវប្រភេទនៃការព្យាបាលជាទូទៅ (ដូចជា : ការបន្ថែមចំណី និងទឹក ការប្រើថ្នាំសំលាប់មេរោគ ..ជាដើម) ។ ប៉ុន្តែនៅពេលលេងបន្តបន្ទាប់មកទៀត និងរហូតដល់ចុង បញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាចមានសមត្ថភាពធ្វើការព្យាបាលលំអិត ដូចជា : ប្រាប់ឈ្មោះថ្នាំ របៀប ប្រើប្រាស់ កំរិតនៃការប្រើប្រាស់ ការគណនាតំលៃថ្នាំ និងតំលៃយ៉ាងសមរម្យដែលម្ចាស់សត្វត្រូវបង់ជូន ។

## ការបង្កើតល្បែង

សំភារៈដែលត្រូវការ :

-ក្រដាសកាតុង ( ផ្ទាំងធំ)

-ប៊ិច ប៊ិចហ្វឺត កន្ត្រៃ និងបន្ទាត់

-ក្រដាសទំរង់បែបបទស្តីពីពតិមានជំងឺសត្វ

ការបង្កើតល្បែងមួយកំប្លេរ

១-កាត់ក្រដាសធ្វើជាកាតអោយបានចំនួន ៧២ សន្លឹក ដែលមានទំហំប្រហែល ១២ ស.ម និង ១០ស.ម

២-បង្កើតអោយបាន ១២កំប្លេរ ដែលមួយកំប្លេរមានកាតចំនួន ៦ ដោយមានសរសេរនៅលើផ្នែកម្ខាងនៃកាតនីមួយៗ ដូចខាងក្រោមនេះ

| | | | | |
|---|---|---|---|---|
| កាតទី១ (កំប្លែទី១: ក្របី) | កាតទី២ (កំប្លែទី១: ក្របី) | កាតទី៣ (កំប្លែទី១: ក្របី) | កាតទី៤ (កំប្លែទី១: ក្របី) | កាតទី៥ (កំប្លែទី១: ក្របី) |
| កាតទី១ (កំប្លែទី១: ជ្រូក) | កាតទី២ (កំប្លែទី១: ជ្រូក) | កាតទី៣ (កំប្លែទី១: ជ្រូក) | ............ | |

នៅលើផ្នែកម្ខាងទៀតនៃកាតនេះត្រូវសរសេរបំពេញនូវពត៌មានអំពីប្រវត្តិរបស់សត្វឈឺ ដូចបានបង្ហាញនូវទំព័រខាង ក្រោយ ឬក៏អ្នកអាចថតចំលងពត៌មានទាំងនេះ ហើយកាត់យកមកបិទនិងកាតទាំងនោះ ។

៣-នៅលើផ្ទាំងក្រណាត់កាតុងធំ ចូរគូររូបដៃមនុស្សដូចបានបង្ហាញជូនខាងក្រោម ។ ធ្វើដូចនេះដើម្បីអោយយើងអាចដាក់កាតតូចៗនេះទៅក្នុងប្រអប់ដែលមានចុះលេខស្រាប់ ។ ចូរគូរធ្វើផ្ទាំងក្រដាសនេះអោយបាន៣ ឬ៤ផ្ទាំង ដើម្បីអោយសិក្ខាកាមអាចលេងល្បែងនេះបានច្រើនកំប្លែរក្នុងពេលជាមួយគ្នា ។

នេះជាផ្ទាំងក្រដាសកាតុងធំ សំរាប់លេងល្បែងព្យាបាលសត្វ




## ការលេងល្បែង

នៅក្នុងការលេងល្បែងនេះត្រូវមានអ្នកលេង២នាក់ ។ ម្នាក់ជាម្ចាស់សត្វ (កសិករ) និងម្នាក់ទៀតជាភ្នាក់ងារសុខភាពសត្វភូមិ ។ ម្ចាស់សត្វបានទៅអញ្ជើញភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីឱ្យមកជួយសត្វដែលកំពុងឈឺ ។ សិក្ខាកាមពីរ បីនាក់ទៀតអាចទៅមើលការលេងល្បែងនេះ ហើយគ្រូគួរតែនៅសង្កេតមើល និងជួយក្នុងការលេងល្បែងនេះ ក្នុងករណីចាំបាច់ ។

ការលេងល្បែងនេះត្រូវចាប់ផ្តើមឡើងដោយម្ចាស់សត្វត្រូវរើសយកកាតមួយកំប្លេរ ។ បន្ទាប់មកត្រូវដាក់កាតទាំងនោះទៅលើផ្ទាំងក្រដាសកាតុងធំអោយបានត្រឹមត្រូវទៅតាមកន្លែងដែលមានលេខស្រាប់ ។ ចំពោះអ្នកលេងម្នាក់ដែលដើរតួជាភ្នាក់ងារសុខភាពសត្វភូមិ ត្រូវមានក្រដាសទំរង់បែបបទស្តីអំពីពតិមានជំងឺសត្វ ដើម្បីយកមកបំពេញ ។ គេត្រូវសរសេរបំពេញនៅក្នុងក្រដាសនេះនូវអ្វីដែលគេបានឃើញ បានឮ និងអ្វីដែលគេសង្ស័យថាជាមូលហេតុ ដែលធ្វើឱ្យសត្វឈឺ ហើយនិងវិធីនៃការព្យាបាលដែលគេបានជ្រើសរើសយកមកធ្វើការព្យាបាល ។ ក្រដាសទំរង់បែបបទនេះ គឺដូចគ្នានិងទំរង់បែបបទ ដែលភ្នាក់ងារសុខភាពសត្វភូមិត្រូវប្រើប្រាស់ នៅពេលដែលពួកគេទៅពិនិត្យសត្វឈឺនៅក្នុងភូមិរបស់គេ ។ កាតទាំងនេះតំណាងអោយទំរង់ការដែលភ្នាក់ងារសុខភាពសត្វភូមិត្រូវធ្វើតាម ដើម្បីរកឃើញនូវអ្វីដែលធ្វើអោយមានបញ្ហាដល់សត្វ និងដើម្បីធ្វើការជ្រើសរើសរកវិធីព្យាបាលអោយបានត្រឹមត្រូវ ។

ត្រូវពន្យល់ដល់សិក្ខាកាមដូចខាងក្រោមនេះ :

-កាតទី១ ( កាតដាក់លើស្មា)

កាតនេះតំណាងអោយតំណាក់កាលទីមួយ ដែលអ្នកត្រូវធ្វើនៅពេលដែលអ្នកទៅពិនិត្យសត្វឈឺ ។ ក្នុងដំណាក់កាល នេះ គឺអ្នកត្រូវពិនិត្យសត្វថាតើវារស់ប្បាយ ឬអត់ ក្នុងល័ក្ខខ័ណ្ឌនៃការចិញ្ចឹមនេះ ។

កាតទី២ ( កាតដាក់លើដើមដៃ)

កាតនេះតំណាងអោយការសួរទៅម្ចាស់សត្វ ។ តាមធម្មតាអ្នកត្រូវសួរនូវសំណួរ៣ប្រភេទ

- ប្រភេទនៃសំនួរទីមួយ គឺសួរលំអិតអំពីសត្វ ដូចជា អាយុ ភេទ ក្រៀវ ឬអត់? តើវាមានកូន ឬអត់?
- ប្រភេទនៃសំនួរទីពីរ សួរប្រវត្តិនៃសត្វឈឺ ដូចជា រយៈពេលដែលសត្វឈឺ រោគសញ្ញាដែលម្ចាស់សត្វបានឃើញ ។
- ប្រភេទនៃសំនួរទីបី គឺសួរថាតើសត្វនេះបានព្យាបាលខ្លះហើយ ឬនៅ ។

-កាតទី៣ ( កាតដាក់លើកែងដៃ)

កាតនេះតំណាងអោយកំដៅរបស់សត្វ ។ វាមានសារៈសំខាន់ណាស់ដើម្បីដឹងថាតើមានមេរោគធ្វើអោយសត្វឈឺ ឬអត់ ។

-កាតទី៤ ( កាតដាក់លើកំភួនដៃ)

កាតនេះបង្ហាញអំពីការពិនិត្យសត្វបន្ទាប់ពីវាស់កំដៅសត្វរួច ។ អ្នកត្រូវចាប់ផ្តើមដោយពិនិត្យមើលសភាពទូទៅរបស់សត្វ ( ស្គម ឬអត់) ។ បន្ទាប់មកអ្នកត្រូវពិនិត្យសត្វ ដើម្បីមើលឃើញនូវអ្វីដែលមិនធម្មតាដូចជា : ដំណើរការដកដង្ហើម សភាពនៃស្បែក រោម ភ្នែក ច្រមុះ មាត់ ។ល ។

-កាតទី៥ ( កាតដាក់លើបាតដៃ)

កាតនេះតំណាងអោយការសំរេចចិត្តរបស់អ្នកពីមូលហេតុដែលធ្វើឱ្យសត្វឈឺ :

- មេដៃ —មានន័យថាវាមិនសប្បាយចិត្ត
- ចង្អុលដៃ —មានន័យថាគ្មានចំណី និងទឹកគ្រប់គ្រាន់
- ចង្អុលខ្មោច —មានន័យថា មានព្រូន ចៃ អង្កែ ដង្កែ

- នាងដៃ — មានន័យថាមានមេរោគចូលក្នុងខ្លួនសត្វ
- កូនដៃ — មានន័យថាសត្វពុល
- កណ្តាលបាតដៃ — មានន័យថាមានរបួស

កាតទី៥ ( កាតដាក់លើម្រាមដៃ)

មេដៃ និងម្រាមដៃតំណាងអោយវិធី៥យ៉ាង ដែលអ្នកត្រូវជ្រើសរើសយកមកធ្វើការព្យាបាល

- មេដៃ — កែលំអកន្លែងចិញ្ចឹម និងការថែរក្សា
- ចង្អុលដៃ — កែលំអ និងបន្ថែមចំណី និងទឹក
- ចង្អុលខ្មោច — ព្យាបាលសត្វដោយប្រើថ្នាំសំលាប់មេរោគ
- នាងដៃ — ព្យាបាលសត្វដោយប្រើថ្នាំសំលាប់ ព្រូន ដង្កែ អង្កែ
- កូនដៃ — ព្យាបាលសត្វដោយប្រើវិធីបន្សាបជាតិពុល

ឥឡូវនេះត្រូវជ្រើសរើសយកកាតមួយកំប្លេរ ហើយដាក់កាតទាំងនោះទៅលើផ្ទាំងក្រដាសកាតុងធំ ទៅតាមលេខរបស់វា ។

ចូរអោយសិក្ខាកាមលេងល្បែងដូចខាងក្រោមនេះ

## ដំណាក់កាលទីមួយ

ភ្នាក់ងារសុខភាពសត្វភូមិត្រូវចាប់យកកាតទី១ (កាតដាក់នៅលើស្មា) មកអាន ដែលកាតនេះនឹងប្រាប់ភ្នាក់ងារសុខភាពសត្វភូមិអោយដឹងនូវប្រភេទសត្វដែលម្ចាស់សត្វបានហៅភ្នាក់ងារសុខភាពសត្វភូមិមកពិនិត្យ (គោ ក្របី ជ្រូក ឬមាន់) និងប្រាប់អោយដឹងកន្លែងចិញ្ចឹមសត្វនោះ ។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវសរសេរពត៌មានទាំងនេះ ដាក់នៅក្នុងក្រដាសទំរង់បែបបទពត៌មានជំងឺសត្វ ។

## ដំណាក់កាលទីពីរ

ម្ចាស់សត្វត្រូវចាប់យកកាតទី២ (កាតដាក់លើដើមដៃ) មកកាន់ ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវសួរទៅម្ចាស់សត្វហើយម្ចាស់សត្វឆ្លើយនិងសំណួររបស់ភ្នាក់ងារសុខភាពសត្វភូមិ ដែលអានតាមចំលើយដែលមានសរសេរនៅក្នុងកាត ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវសរសេរពត៌មានទាំងនោះ ដាក់នៅក្នុងក្រដាសទំរង់បែបបទពត៌មានជំងឺសត្វ ។

## ដំណាក់កាលទីបី

ភ្នាក់ងារសុខភាពសត្វភូមិត្រូវវាស់កំដៅសត្វដោយចាប់យកកាតទី៣ (កាតដាក់លើកែងដៃ) មកមើល ហើយសរសេរកំរិតនៃកំដៅនេះចូលទៅក្នុងក្រដាសទំរង់បែបបទពត៌មានជំងឺសត្វ ។

## ដំណាក់កាលទីបួន

ភ្នាក់ងារសុខភាពសត្វភូមិត្រូវធ្វើការពិនិត្យសត្វដោយចាប់យកកាតទី៤ ( កាតដាក់លើកំភួនដៃ) មកអានអោយដឹងអំពីរោគសញ្ញាអ្វីខ្លះដែលអាចឃើញ ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវសរសេរពតិមាននេះដាក់នៅក្នុងក្រដាសទំរង់បែបបទពតិមានជំងឺ ។

## ដំណាក់កាលទីប្រាំ

ភ្នាក់ងារសុខភាពសត្វភូមិត្រូវសំរេចចិត្តថាអ្វីដែលជាមូលហេតុធ្វើអោយសត្វឈឺ ។ បន្ទាប់មកភ្នាក់ងារសុខភាពសត្វភូមិត្រូវធ្វើការជ្រើសរើសយកមូលហេតុ១ ឬច្រើនក្នុងចំណោមមូលហេតុទាំង៦យ៉ាង ដែលអាចធ្វើឱ្យសត្វឈឺ ឬស្គម ។ ភ្នាក់ងារសុខភាពសត្វភូមិកត់មូលហេតុទាំងនេះដាក់ទៅក្នុងទំរង់បែបបទពតិមានជំងឺសត្វ ។

## ដំណាក់កាលទីប្រាំមួយ

ពេលដែលភ្នាក់ងារសុខភាពសត្វភូមិធ្វើការសំរេចចិត្តអំពីវិធីព្យាបាលសត្វ ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវជ្រើសរើស យកវិធី១ ឬច្រើនក្នុងចំណោម៦យ៉ាង ដែលអាចជួយអោយសត្វឈឺ ឬស្គមបានជាសះស្បើយឡើងវិញ ។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវកត់ត្រាអំពីវិធីព្យាបាលនេះនិងអំពីដំបូន្មានរបស់ខ្លួនឱ្យដល់ម្ចាស់សត្វ ទៅក្នុងទំរង់បែបបទពតិមានជំងឺសត្វ .។

## ដំណាក់កាលទីប្រាំពីរ

នៅពេលដែលភ្នាក់ងារសុខភាពសត្វភូមិបានបញ្ចប់នូវការកត់ត្រាទាំងនេះ ទៅក្នុងទំរង់បែបបទពតិមានជំងឺសត្វហើយ គេត្រូវចាប់យកកាតទី៥ ( កាតដាក់លើបាតដៃ) ដើម្បីមើលចំលើយត្រឹមត្រូវអំពីមូលហេតុដែលធ្វើអោយសត្វឈឺ ឬស្គម ។

## ដំណាក់កាលទីប្រាំបី

ពេលដែលភ្នាក់ងារសុខភាពសត្វភូមិចាប់យកកាតទី៩ ( កាតដាក់នៅលើម្រាមដៃ) ដើម្បីពិនិត្យផ្ទៀងផ្ទាត់មើលលើការព្យាបាលថាតើវាត្រឹមត្រូវរឺអត់ ។ បើសិនជាភ្នាក់ងារសុខភាពសត្វភូមិបានធ្វើការព្យាបាលត្រឹមត្រូវ នោះម្ចាស់សត្វត្រូវបង់ប្រាក់ខ្លះ អោយទៅភ្នាក់ងារសុខភាពសត្វភូមិ ។

## ការលេងល្បែងរំលឹកឡើងវិញ

ល្បែងនេះត្រូវតែលេងអោយបានច្រើនដងនៅក្នុងពេលបណ្តុះបណ្តាលនេះ ទៅតាមកាលវិភាគនៃវគ្គបណ្តុះបណ្តាលនេះមានស្រាប់ ។ ប៉ុន្តែសិក្ខាកាមអាចលេងច្រើន ឬតិចដងជាងនេះ អាស្រ័យទៅតាមល្បឿននៃការយល់ដឹងរបស់សិក្ខាកាម នូវគោលបំណងរបស់មេរៀន ។ សិក្ខាកាមទាំងអស់ត្រូវលេងអោយបានច្រើនដង ដោយជួនកាលដើរតួជាភ្នាក់ងារសុខភាពសត្វភូមិ និងជួនកាលដើរតួជាម្ចាស់សត្វ ។

ពតិមានដែលភ្នាក់ងារសុខភាពសត្វភូមិបានសរសេរអំពីការព្យាបាល និងកាន់តែមានការលំអិតឡើង ទៅតាមការរីកចំរើននៃការយល់ដឹងរបស់សិស្ស តាមរយៈមេរៀននៃវគ្គបណ្តុះបណ្តាលនេះ ។

ការលេងល្បែងនេះលើកដំបូងត្រូវប្រើកំប្លែរទី១ ដល់កំប្លែរទី៨ ។ នៅពេលនោះសិក្ខាកាមអាចមានសមត្ថភាពធ្វើការជ្រើសរើសវិធីសាស្ត្រនៃការព្យាបាលជាទូទៅ ( ដូចជា : ការបន្ថែមចំណី និងទឹក ការប្រើថ្នាំសំលាប់មេរោគជាដើម ។ )

បន្ទាប់ពីសិក្ខាកាមបានរៀនអំពីជំងឺសំខាន់មួយចំនួននៅក្នុងមេរៀនទី៦ រួចមក ល្បែងនេះត្រូវលេងដោយប្រើកំប្លែរ ទី១ ដល់ ទី២០ ។ ពេលនោះសិក្ខាកាមអាចមានសមត្ថភាព ធ្វើការជ្រើសរើសយកវិធីសាស្ត្រក្នុងការព្យាបាលដោយលំអិតដូចជា : ប្រាប់ឈ្មោះថ្នាំ របៀបប្រើប្រាស់ កំរិតនៃការប្រើប្រាស់ ការគណនាតំលៃថ្នាំ និងតំលៃយ៉ាងសមរម្យដែលម្ចាស់ សត្វត្រូវបង់ជូន ។

នៅក្នុងទំព័រខាងក្រោយនេះគឺជា ពត៌មានសត្វឈឺចំនួន ២០ ដែលត្រូវយកមកប្រើ ដើម្បីបង្កើតបានជាល្បែង ២០ កំប្លែរនេះ ។ អ្នកអាចបង្កើតជាកំប្លែរនៃល្បែងនេះបន្ថែមទៀត ទៅតាមករណីជាក់ស្តែង ដែលអ្នកអាចធ្វើបានដោយខ្លួនឯង ។

## កំប្លែរនៃកាតរបស់ល្បែងស្តីពីការព្យាបាលសត្វ

លក្ខណៈរួម ឬលក្ខណៈទូទៅ ( កំប្លែរទី១ ដល់ ទី៨)

| | | |
|---|---|---|
| កំប្លែរទី១ : សត្វគោ<br>អាយុ ១ឆ្នាំ<br>ស្គម ចៃ គ្រុន | កំប្លែរទី២ : សត្វជ្រូក<br>អាយុ ៣ខែ<br>ស្គម អង្កែ រមាស់ | កំប្លែរទី៣ : សត្វក្របី<br>អាយុ ៣ឆ្នាំ<br>រាគអាចម៍ គ្រុន |
| កំប្លែរទី៤ :សត្វគោ<br>អាយុ ៦ឆ្នាំ<br>មេគោស្គមណាស់ អត់គ្រុន | កំប្លែរទី១: សត្វជ្រូក<br>អាយុ ២ខែ<br>ដំបៅក្លាយ កន្លែងក្រៀវ គ្រុន | កំប្លែរទី១ : សត្វគោ<br>អាយុ ៥ឆ្នាំ<br>ដំបៅ គ្រុន |
| កំប្លែរទី៧ : សត្វគោ<br>អាយុ ១០ឆ្នាំ<br>ធ្វើការហួសកំលាំង គ្រុន | កំប្លែរទី១ : សត្វជ្រូក<br>កូនជ្រូក<br>រាគអាចម៍ អត់គ្រុន | |

ជំងឺសំខាន់ៗមួយចំនួន ( កំប្លែរទី៩ ដល់ ទី២០ )

| | | | |
|---|---|---|---|
| កំប្លែរទី៩ : សត្វក្របី<br>ជំងឺ សារទឹក | កំប្លែរទី១០ : សត្វជ្រូក<br>ប៉េស្តជ្រូក | កំប្លែរទី១១ : សត្វគោ<br>អុតក្តាម | កំប្លែរទី១២ : សត្វមាន់<br>ជំងឺញូវកាស |
| កំប្លែរទី១៣: សត្វក្របី<br>ជំងឺ ឈាមខ្មៅ | កំប្លែរទី១៤ : សត្វជ្រូក<br>កូនជ្រូក ព្រូនមូល | កំប្លែរទី១៥ : សត្វគោ<br>ជំងឺបូសខ្យល់ | កំប្លែរទី១៦ : សត្វមាន់<br>ជំងឺអាសន្នរោគ |
| កំប្លែរទី១៧: សត្វក្របី<br>កូនក្របី<br>ព្រូនមូល | កំប្លែរទី១៨ : សត្វជ្រូក<br>មេជ្រូកទើបកើតកូន<br>ជំងឺទាស់ ( អត់ទឹកដោះ ) | កំប្លែរទី១៩ : សត្វគោ<br>ព្រូនសំប៉ែត<br>( ហ្វាស្យូឡា ) | កំប្លែរទី២០ : សត្វគោ<br>ជំងឺឆ្កួត ( ឆ្កែឆ្កួតខាំ ) |

(កាតលេខ ១) កំប្លែរ ១

ប្រភេទសត្វ : សត្វគោ

កន្លែងចិញ្ចឹមសត្វ : ក្រោលស្អាតនៅពេលយប់

ពេលថ្ងៃសត្វនៅវាលស្រែ

(កាតលេខ ២)

ភេទ? ញី

អាយុ? ១ឆ្នាំ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? ស៊ីតិច។

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ចុះស្គម២.៣អាទិត្យហើយ

ប៉ុន្តែទើបតែឈប់ស៊ីចំណីថ្ងៃនេះ ។

បានឃើញសត្វយ៉ាងម៉េចខ្លះ? ពេលខ្លះឃើញរាគអាចម៍ ។

ការព្យាបាល? បានព្យាបាលថ្នាំខ្មែរ

សត្វផ្សេងទៀតឈឺឬអត់? វាស្គម តែនៅស៊ីចំណី

(កាតលេខ ៣)

កំដៅខ្លួនសត្វ? ៤០ អង្សា

(កាតលេខ៤)

ទំងន់ប៉ុន្មានគីឡូ? ប្រហែល៧០គក្រ

ធាត់ រឺស្គម? ស្គម

តិច ឬ ខ្លាំង? អន់តិច

ដំណើរ? ស៊ីតិច។

លាមក? ស្មៅ និងចំបើង

ទឹកនោម? ចុះស្គម២.៣អាទិត្យហើយ

ដង្ហើម? ពេលខ្លះឃើញរាគ អាចម៍ ។

មាត់ ច្រមុះ? បានព្យាបាលថ្នាំខ្មែរ

ភ្នែក? វាស្គម តែនៅស៊ីចំណី

ស្បែក និងរោម? ស្ងួត រោមបះ និងមានចៃច្រើន

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគរុករានក្នុងខ្លួនសត្វ

-មានចៃច្រើនកំពុងខាំសត្វ

-ប្រហែលជាមានព្រូននៅក្នុងពោះវៀនសត្វផង ។

(កាតលេខ ៦)

ការព្យាបាល? -ប្រើថ្នាំសំលាប់មេរោគ

-ប្រើថ្នាំសំលាប់ចៃ

-ប្រើថ្នាំទំលាក់ព្រូន

ដំបូន្មានដល់ម្ចាស់សត្វ :

-សូមអោយទឹកសត្វផឹក ឲ្យបានគ្រប់គ្រាន់និងបន្ថែមស្មៅឬស្លឹកឈើស្រស់អោយសត្វស៊ី ។

-សត្វផ្សេងទៀតក៏ប្រហែលជាចុះស្គមដោយសារមានព្រូន និងខ្វះចំណី ។

កំប្លែរ ២

( កាតលេខ ១ )

ប្រភេទសត្វ : *សត្វជ្រូក*

កន្លែងចិញ្ចឹមសត្វ : *ចងនៅក្រោមដើមឈើ*

( កាតលេខ ២ )

ភេទ? *ញី*

អាយុ? *៣ខែ*

ក្រៀវ ឬអត់? *ក្រៀវហើយ*

ការស៊ីចំណី? *ស៊ីតិច១*

ដាក់ចំណីអ្វីអោយស៊ី? *បបរ លាយកន្ទក់*

ឈឺប៉ុន្មានថ្ងៃហើយ? *ឈឺជិតមួយខែហើយ*

បានឃើញសត្វយ៉ាងម៉េចខ្លះ? *ជ្រូកវារមាស់ខ្លាំង ហើយស៊ីចំណីមិនបានច្រើន ។*

ការព្យាបាល? *លាបប្រេងម៉ាស៊ីនលើស្បែក*

សត្វផ្សេងទៀតឈឺឬអត់? *អត់*

( កាតលេខ ៣ )

កំដៅខ្លួនសត្វ? *៣៨.៥ អង្សា*

( កាតលេខ ៤ )

ទំងន់ប៉ុន្មានគីឡូ? *ប្រហែល១៥គក្រ*

ធាត់ រឺស្គម? *ស្គម*

តិច ឬ ខ្លាំង? *អន់តិច*

ដំណើរ? *ធម្មតា*

លាមក? *ធម្មតា*

ទឹកនោម? *ធម្មតា*

ដង្ហើម? *ធម្មតា*

មាត់ ច្រមុះ? *ច្រមុះស្ងួត*

ភ្នែក? *ធម្មតា*

ស្បែក និងរោម? *ស្បែកក្រហម ហើយជ្រួញ*

( កាតលេខ ៥ )

ការសង្ស័យលើមូលហេតុនៃជំងឺ?

*-អង្កែ ( រមាស់ )*

*-ប្រហែលជាមានព្រូននៅក្នុងពោះវៀនសត្វផង ។*

( កាតលេខ ៦ )

ការព្យាបាល? *-ប្រើថ្នាំសំលាប់អង្កែ ចៃ*

*-ប្រើថ្នាំទំលាក់ព្រូន*

ដំបូន្មានដល់ម្ចាស់សត្វ :

*-ត្រូវប្រើថ្នាំសំលាប់អង្កែ ចៃ ម្តងទៀតក្នុងរយៈពេល២អាទិត្យក្រោយ ។*

*-បង្កើនចំណីជ្រូកដោយបន្ថែមបន្លែស្រស់ លាយជាមួយ សណ្តែកសៀង ឬក៏ត្រី*

*-ត្រូវដាក់ទឹកអោយជ្រូកផឹកអោយបានគ្រប់គ្រាន់ ។*

កំប្លែរ ៣

(កាតលេខ ១)

ប្រភេទសត្វ : សត្វក្របី

កន្លែងចិញ្ចឹមសត្វ : ក្រោលតូចចង្អៀត និងមានភក់ លាយអាចម៍ក្របីច្រើន

(កាតលេខ ២)

ភេទ? ញី

អាយុ? ៣ឆ្នាំ

គ្រៀវ ឬអត់? អត់

ការស៊ីចំណី? ស៊ីតិចៗ

ដាក់ចំណីអ្វីអោយស៊ី? ស្មៅទឹក និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ២ថ្ងៃ

បានឃើញសត្វយ៉ាងម៉េចខ្លះ? រាគអាចម៍ ៣ថ្ងៃ ហើយ

ការព្យាបាល? ព្យាបាលថ្នាំខ្មែរ

សត្វផ្សេងទៀតឈឺឬអត់? អត់

កំប្លែរ ៤

(កាតលេខ ១)

ប្រភេទសត្វ : សត្វគោ

កន្លែងចិញ្ចឹមសត្វ : ក្រោលនៅពេលយប់និងទៅស៊ីស្មៅនៅវាលស្រែនៅពេលថ្ងៃ

(កាតលេខ ២)

ភេទ? ញី

អាយុ? ៦ឆ្នាំ

គ្រៀវ ឬអត់? អត់ (មានកូនអាយុ៦ខែនៅបៅដោះ)

ការស៊ីចំណី? ធម្មតា

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ប្រហែល ៣ថ្ងៃហើយ

បានឃើញសត្វយ៉ាងម៉េចខ្លះ? ចុះស្គមរាល់អាទិត្យ ហើយកូនវាក៏ចាប់ផ្តើមស្គមដែរ ។

ការព្យាបាល? អត់

សត្វផ្សេងទៀតឈឺឬអត់? អត់

(កាតលេខ ៣)

កំដៅខ្លួនសត្វ? ៣៨.៥ អង្សា

(កាតលេខ៤)

ទំងន់ប៉ុន្មានគីឡូ? ប្រហែល២៥០គក្រ

ធាត់ រឺស្គម? ស្គមខ្លាំងណាស់

តិច ឬ ខ្លាំង? អន់តិច

ដំណើរ? ធម្មតាតែរាងខ្សោយ

លាមក? ធម្មតា

ទឹកនោម? ធម្មតា

ដង្ហើម? ធម្មតា

មាត់ ច្រមុះ? ធម្មតា

ភ្នែក? ធម្មតា

ស្បែក និងរោម? ស្បែកស្ងួត បះរោម

( កាតលេខ ៥ )

ការសង្ស័យលើមូលហេតុនៃជំងឺ?

-ចំណីទឹកមិនគ្រប់គ្រាន់

-មានព្រូននៅក្នុងពោះវៀនផង

ការព្យាបាល? ( កាតលេខ ៦

-ប្រើថ្នាំសំលាប់ព្រូន

ដំបូន្មានដល់ម្ចាស់សត្វ :

-ត្រូវទំលាក់ព្រូនកូនគោផងដែរ

-ត្រូវបង្កើនគុណភាពចំណីដល់មេគោ និងកូនគោដោយយក វាទៅឃ្វាលនៅកន្លែងដែលមានស្មៅល្អ ។ ច្រូតស្មៅ ឬរកស្លឹកឈើមក បន្ថែមអោយវា ។ ផ្ងាប់ចំបើងជាមួយជីអ៊ុយរេអោយវាស៊ីផង ។

( កាតលេខ ១ )

កំប្លែរ ៥

ប្រភេទសត្វ : សត្វជ្រូក

កន្លែងចិញ្ចឹមសត្វ : នៅក្នុងទ្រុងក្រោលឈើស្អាតហើយ នៅក្រោមម្លប់ឈើ

ភេទ? ឈ្មោល ( កាតលេខ ២ )

អាយុ? ២ខែ

ក្រៀវ ឬអត់? ក្រៀវ២ថ្ងៃមកហើយ

ការស៊ីចំណី? អត់ស៊ីចំណីអាហារសោះ

ដាក់ចំណីអ្វីអោយស៊ី? បបរ លាយកន្ទក់

ឈឺប៉ុន្មានថ្ងៃហើយ? ឈឺចាប់ពីព្រឹកមិញ

បានឃើញសត្វយ៉ាងម៉េចខ្លះ? វាមិនចង់ស៊ីបាយ និងមិនចង់ដើរ ។

ការព្យាបាល? អត់

សត្វផ្សេងទៀតឈឺឬអត់? អត់

( កាតលេខ ៣ )

កំដៅខ្លួនសត្វ? ៤០.៥ អង្សា

ទំងន់ប៉ុន្មានគីឡូ? ប្រហែល១៥គក្រ ( កាតលេខ៤ )

ធាត់ រឺស្គម? ធាត់

តិច ឬ ខ្លាំង? អន់ខ្លាំង

ដំណើរ? រឹងជើងក្រោយ

លាមក? ទល់លាមក

ទឹកនោម? មិនបានឃើញ

ដង្ហើម? ញាប់ខ្លាំង

មាត់ ច្រមុះ? ធម្មតា

ភ្នែក? ធម្មតា

ស្បែក និងរោម? មុខរបួសក្រៀវហើមមានពណ៌ក្រហម

( កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគ ( មេរោគចូលក្នុងខ្លួនជ្រូកតាមមុខរបួស កន្លែងក្រៀវ )

ការព្យាបាល? -ប្រើថ្នាំសំលាប់មេរោគ ( កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

-ពេលក្រោយអ្នកគួរតែហៅភ្នាក់ងារសុខភាពសត្វភូមិមកក្រៀវជ្រូកអ្នក

-បង្កើនចំណីជ្រូកដោយបន្ថែមបន្លែស្រស់ លាយជាមួយ សណ្តែកសៀង ស្ពោរ ឬកំប្លោកត្រី ។

-ត្រូវដាក់ទឹកអោយជ្រូកផឹកអោយបានគ្រប់គ្រាន់

( កាតលេខ ១)

ប្រភេទសត្វ : សត្វក្របី

កន្លែងចិញ្ចឹមសត្វ : នៅក្រោមដើមឈើពេលយប់ នៅវាលស្រែពេលថ្ងៃ

កំប្លែរ ៦

ភេទ? ឈ្មោល ( កាតលេខ ២)

អាយុ? ៥ខែ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? ស៊ីតិចៗ

ដាក់ចំណីអ្វីអោយស៊ី? ស្មៅទឹក និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ឈប់ស៊ីចំណីពីម្សិលមិញ

បានឃើញសត្វយ៉ាងម៉េចខ្លះ? មុតបន្ទាលូសកាលពីអាទិត្យមុន ។ ឥឡូវវាឈឺជើងដើរលែងចង់រួច ។

ការព្យាបាល? គ្រូខ្មែរមកព្យាបាលពីម្សិលមិញ

សត្វផ្សេងទៀតឈឺឬអត់? អត់

( កាតលេខ ៣)

កំដៅខ្លួនសត្វ? ៤០ អង្សា

ទំងន់ប៉ុន្មានគីឡូ? ប្រហែល៣៥០គក្រ ( កាតលេខ៤)

ធាត់ ស្គម? ធម្មតា

តិច ឬ ខ្លាំង? អន់តិច

ដំណើរ? ដើរខ្ញើចៗ

លាមក? ធម្មតា

ទឹកនោម? ធម្មតា

ដង្ហើម? ធម្មតា

មាត់ ច្រមុះ? ច្រមុះស្ងួត

ភ្នែក? ធម្មតា

ស្បែក និងរោម? ដំបៅជើង ហើមក្តៅ ឈឺខ្លាំង និងមានដង្កូវ

( កាតលេខ ៥ )

<u>ការសង្ស័យលើមូលហេតុនៃជំងឺ?</u>

*-មានរបួសដោយមុតបន្លាលួស*

*-មានមេរោគ ( មេរោគចូលតាមផ្លូវដង្ហូវរុក )*

<u>ការព្យាបាល?</u> *-ប្រើថ្នាំសំលាប់មេរោគ* ( កាតលេខ ៦)

*-ប្រើថ្នាំសំលាប់ដង្កូវ និងការពាររុយកុំអោយមកពង ដាក់ទៀត ។*

<u>ដំបូន្មានដល់ម្ចាស់សត្វ :</u>

*-លាងដំបៅជាមួយទឹកក្តៅ ឫទឹកអំបិលរៀងរាល់ថ្ងៃ ។ ប្រើថ្នាំសំលាប់ដង្កូវ និងការពារកុំអោយរុយពងដាក់ ។*

*-សូមអោយទឹកសត្វផឹកអោយបានគ្រប់គ្រាន់*

កំប្លេរ ៧

( កាតលេខ ១ )

<u>ប្រភេទសត្វ :</u> *សត្វគោ*

<u>កន្លែងចិញ្ចឹមសត្វ :</u> *ចងអោយដេកនៅលើដីស្ងួតស្អាត ក្រោមម្លប់ឈើ*

<u>ភេទ?</u> *ឈ្មោល* ( កាតលេខ ២

<u>អាយុ?</u> *១២ឆ្នាំ*

<u>ក្រៀវ ឬអត់?</u> *ក្រៀវហើយ*

<u>ការស៊ីចំណី?</u> *អត់ស៊ីចំណី*

<u>ដាក់ចំណីអ្វីអោយស៊ី?</u> *ចំបើងចាស់ៗ*

<u>ឈឺប៉ុន្មានថ្ងៃហើយ?</u> *ឈឺចាប់ពីម្សិលមិញ*

<u>បានឃើញសត្វយ៉ាងម៉េចខ្លះ?</u> *ក្រោយពីភ្ជួររស្រែបានប្រហែលជាង១ហិចតា ស្រាប់តែឈឺ*

<u>ការព្យាបាល?</u> *អត់*

<u>សត្វផ្សេងទៀតឈឺឬអត់?</u> *អត់*

( កាតលេខ ៣ )

<u>កំដៅខ្លួនសត្វ?</u> *៤០អង្សា*

<u>ទំងន់ប៉ុន្មានគីឡូ?</u> *ប្រហែល៣០០គក្រ* ( កាតលេខ៤

<u>ធាត់ រឺស្គម?</u> *ស្គម*

<u>តិច ឬ ខ្លាំង?</u> *អន់តិច*

<u>ដំណើរ?</u> *ធម្មតាតែហាក់ដូចជាអស់កំលាំង*

<u>លាមក?</u> *ធម្មតា*

<u>ទឹកនោម?</u> *ពណ៌ក្រម៉ៅ*

<u>ដង្ហើម?</u> *ដកដង្ហើមរាងញាប់*

<u>មាត់ ច្រមុះ?</u> *ច្រមុះស្ងួត*

<u>ភ្នែក?</u> *ធម្មតា*

<u>ស្បែក និងរោម?</u> *ធម្មតា*

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

*-សត្វមិនសប្បាយចិត្ត ព្រោះវាចាស់ ហើយប្រើវាច្រើនពេក និងអោយវាស៊ីតែចំបើង ។*

*-ចំណីមិនគ្រប់គ្រាន់*

*-មានមេរោគចូលក្នុងខ្លួនសត្វ*

ការព្យាបាល? *-ប្រើថ្នាំសំលាប់មេរោគ* (កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

*-បើចង់អោយវារស់បានយូរ សូមកុំប្រើវាខ្លាំងពេក*

*-ត្រូវបង្កើនគុណភាពចំណីដល់គោ ដោយយកវាទៅឃ្វាលនៅកន្លែងដែលមានស្មៅល្អៗ ។ ច្រូតស្មៅឬរកស្លឹកឈើបន្ថែមអោយវាស៊ី ។ ផ្លាប់ចំបើងជាមួយជីអ៊ុយរេអោយវាស៊ីផង ។ ដោយដាក់ទឹកអោយវាផឹកគ្រប់គ្រាន់*

(កាតលេខ ១)

កំប្លែ ៨

ប្រភេទសត្វ : *សត្វជ្រូក*

កន្លែងចិញ្ចឹមសត្វ : *ទ្រុងចង្អៀត មានភក់ និងអាចម៍ជ្រូកច្រើន ។*

ភេទ? *ញី* (កាតលេខ ២)

អាយុ? *២ខែ*

ក្រៀវ ឬអត់? *អត់*

ការស៊ីចំណី? *ស៊ីចំណីតិចៗ*

ដាក់ចំណីអ្វីអោយស៊ី? *បបរ លាយកន្ទក់*

ឈឺប៉ុន្មានថ្ងៃហើយ? *ឈឺចាប់ពីម្សិលមិញ*

បានឃើញសត្វយ៉ាងម៉េចខ្លះ? *វារាគអាចម៍ខ្លាំងណាស់*

ការព្យាបាល? *អត់*

សត្វផ្សេងទៀតឈឺឬអត់? *អត់*

(កាតលេខ ៣)

កំដៅខ្លួនសត្វ? *៣៩ អង្សា*

ទំងន់ប៉ុន្មានគីឡូ? *ប្រហែល១០គក្រ* (កាតលេខ៤)

ធាត់ រឺស្គម? *ធម្មតា*

តិច ឬ ខ្លាំង? *រស់តិច*

ដំណើរ? *ធម្មតា*

លាមក? *រាគ*

ទឹកនោម? *នោមតិច*

ដង្ហើម? *ធម្មតា*

មាត់ ច្រមុះ? *ធម្មតា*

ភ្នែក? *ធម្មតា*

ស្បែក និងរោម? *ប្រឡាក់ភក់ កខ្វក់*

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-សត្វមិនសប្បាយចិត្តដោយសារ ទ្រុងចង្អៀតហើយមិនស្អាត ។

-ខ្វះជាតិទឹក (ព្រោះវារាគខ្លាំង)

-មានមេរោគក្នុងពោះវៀន

-ប្រហែលមានព្រូននៅក្នុងពោះវៀន

ការព្យាបាល? (កាតលេខ ៦)

-ប្រើថ្នាំជួយឱ្យពោះវៀនស្រូបជាតិទឹកអោយបានច្រើន

-ប្រើថ្នាំសំលាប់មេរោគ

-ប្រើថ្នាំសំលាប់ព្រូន

ដំបូន្មានដល់ម្ចាស់សត្វ :

-ផ្លាស់កន្លែងកូនជ្រូកអោយទៅនៅកន្លែងស្អាត

-ត្រូវដាក់ទឹកអោយជ្រូកផឹកអោយបានគ្រប់គ្រាន់ និងលាយទឹកអូរ៉ាលីតផង ។

-បង្កើនចំណីជ្រូកដោយបន្ថែមបន្លែស្រស់ លាយជាមួយសណ្តែកសៀង ឬកន្ត្រក ។

(កាតលេខ ១) កំប្លែរ ៩

ប្រភេទសត្វ : សត្វក្របី

កន្លែងចិញ្ចឹមសត្វ : ក្រោលស្អាតនៅពេលយប់

វាទៅស៊ីចំណីនៅឯព្រៃនៅពេលថ្ងៃ

ភេទ? ឈ្មោល (កាតលេខ ២)

អាយុ? ២ឆ្នាំ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? មិនស៊ីចំណី

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ១ថ្ងៃ

បានឃើញសត្វយ៉ាងម៉េចខ្លះ? វាចាប់ឈឺភ្លាមៗតែម្តង

ការព្យាបាល? ថ្នាំខ្មែរ

សត្វផ្សេងទៀតឈឺឬអត់? ក្របីជិតខាង២ខ្លះទៀតនៅក្នុងភូមិនេះក៏ឈឺដែរ

(កាតលេខ ៣)

កំដៅខ្លួនសត្វ? ៤១ អង្សា

ទំងន់ប៉ុន្មានគីឡូ? ប្រហែល២០០គក្រ (កាតលេខ៤)

ធាត់ រឺស្គម? ធម្មតា

តិច ឬ ខ្លាំង? អន់ខ្លាំងហោស់

ដំណើរ? នៅឈរមួយកន្លែង មិនចង់ដើរ

លាមក? មិនជុះ

ទឹកនោម? មិននោម

ដង្ហើម? ដកដង្ហើមញាប់ហើយឮសូរក្រកៗ

មាត់ ច្រមុះ? ហៀរទឹកមាត់ និងមានហៀរសំបោរផង

ភ្នែក? ធម្មតា

ស្បែក និងរោម? ហើមក និងហើមពោះ

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

*-មានមេរោគចូលរុករានក្នុងខ្លួនសត្វ (ប្រហែលជាមេរោគនេះនៅក្នុងក និងនៅក្នុងសួត) ។*

ការព្យាបាល? *-ប្រើថ្នាំសំលាប់មេរោគ* (កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

*-ជំងឺនេះប្រហែលជាជំងឺសារទឹក*

*-ក្របីនេះឈឺធ្ងន់ណាស់ វាអាចស្លាប់ ។*

*តើមានបានចាក់ថ្នាំការពារជំងឺនេះអោយវាទេក្នុងឆ្នាំនេះ?*

*ការចាក់*

*ថ្នាំការពាររាល់ឆ្នាំអាចការពារក្របីមិនអោយឈឺដោយសារជំងឺនេះបាន ។*

*-សូមកុំភ្លេចអោយទឹកវាផឹកអោយបានគ្រប់គ្រាន់ ។*

កំប្លែរ១()

(កាតលេខ ១)

ប្រភេទសត្វ : *សត្វជ្រូក*

កន្លែងចិញ្ចឹមសត្វ : *ចងខ្សែនៅដីស្អាតក្រោមផ្ទះ*

ភេទ? *ឈ្មោល* (កាតលេខ ២)

អាយុ? *៥ខែ*

ក្រៀវ ឬអត់? *ក្រៀវហើយ*

ការស៊ីចំណី? *មិនស៊ីចំណី*

ដាក់ចំណីអ្វីអោយស៊ី? *កន្ទក់ និងបបរលាយត្រកួន*

ឈឺប៉ុន្មានថ្ងៃហើយ? *៣ថ្ងៃ*

បានឃើញសត្វយ៉ាងម៉េចខ្លះ? *ដំបូលទល់និងក្រោយមករាគ*

ការព្យាបាល? *អត់បានព្យាបាលទេ*

សត្វផ្សេងទៀតឈឺឬអត់? *ជ្រូកអ្នកជិតខាងក៏ឈឺដែរ*

(កាតលេខ ៣)

កំដៅខ្លួនសត្វ? *៤០ អង្សា*

ទំងន់ប៉ុន្មានគីឡូ? *ប្រហែល៧០គក្រ* (កាតលេខ៤)

ធាត់ រឺស្គម? *ធម្មតា*

តិច ឬ ខ្លាំង? *រវន់ខ្លាំងណាស់*

ដំណើរ? *មិនចង់ដើរ*

លាមក? *រាគ*

ទឹកនោម? *មិនបានឃើញ*

ដង្ហើម? *ដកដង្ហើមញាប់*

ហាត់ ច្រមុះ? *ច្រមុះឡើងពណ៌ក្រម៉ៅ*

ភ្នែក? *ភ្នែកពណ៌ក្រហម និងមានពពឹកភ្នែកផង*

ស្បែក និងរោម? *ត្រចៀកនិងជើងមានពណ៌ខៀវ និងមានស្នាមក្រហមអុច១ខាងក្រោមពោះ*

( កាតលេខ ៥ )

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគចូលរុករានក្នុងខ្លួនសត្វ ( ប្រហែលជាមេរោគនេះនៅក្នុងផ្ទៃកស្បែក និងពោះវៀន )

( កាតលេខ ៦ )

ការព្យាបាល?

-ប្រើថ្នាំសំលាប់មេរោគ

និងថ្នាំជួយឱ្យពោះវៀនស្រូបជាតិទឹកទៅ ក្នុងខ្លួន ។

ដំបូន្មានដល់ម្ចាស់សត្វ :

-ជំងឺនេះប្រហែលជាជំងឺប៉េស្តជ្រូក ។ ជ្រូកនេះវាឈឺធ្ងន់ណាស់ ប្រហែលជាអាចស្លាប់ ។ ពេលវាស្លាប់សូមយកទៅកប់កុំអោយមេរោគឆ្លងទៅជ្រូកផ្សេងទៀត ។

-ពេលចិញ្ចឹមជ្រូកលើកក្រោយកុំភ្លេចចាក់ថ្នាំការពារ

( កាតលេខ ១ )

ប្រភេទសត្វ : សត្វគោ

កន្លែងចិញ្ចឹមសត្វ : កន្លែងស្អាតនៅក្រោមដើមឈើនៅពេលយប់ និងពេលថ្ងៃដើរស៊ីស្មៅនៅតាមវាលស្រែ

កំប្លែ១១

( កាតលេខ២ )

ភេទ? ញី

អាយុ? ៤ឆ្នាំ

គ្រៀវ ឬអត់? អត់

ការស៊ីចំណី? អត់ស៊ីចំណី

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ១អាទិត្យ

បានឃើញសត្វយ៉ាងម៉េចខ្លះ? ដំបូងកូនវាស្លាប់ប្រហែលជា១អាទិត្យ បន្ទាប់មកស្រាប់តែឃើញវាមានដំបៅមាត់និងក្រចក ។

ការព្យាបាល? បានព្យាបាលថ្នាំខ្មែរ

សត្វផ្សេងទៀតឈឺឬអត់? គោ ក្របីអ្នកជិតខាងក៏ឈឺដែរ ។

( កាតលេខ ៣ )

កំដៅខ្លួនសត្វ? ៣៩អង្សា

( កាតលេខ៤ )

ទំងន់ប៉ុន្មានគីឡូ? ប្រហែល៣០០គក្រ

ធាត់ រឺស្គម? ធម្មតា

តិច ឬ ខ្លាំង? អន់តិចៗ

ដំណើរ? មិនចង់ដើរ

លាមក? ធម្មតា

ទឹកនោម? ធម្មតា

ដង្ហើម? ធម្មតា

មាត់ ច្រមុះ? ហៀរទឹកមាត់ ដំបៅអណ្តាត និងអញ្ចាញ

ភ្នែក? ធម្មតា

ស្បែក និងរោម? ដំបៅស្បែកគល់ក្រចក

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគចូលរុករានក្នុងខ្លួនសត្វ (ប្រហែលជាមេរោគនេះនៅក្នុងមាត់ និងនៅក្នុងជើង) ។

ការព្យាបាល? -ប្រើថ្នាំសំលាប់មេរោគ (កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

-ជំងឺនេះប្រហែលជាជំងឺអុតក្តាម ។ មេរោគនេះហើយដែលធ្វើអោយកូនគោស្លាប់ ។ ចូរលាងដំបៅនិងទឹកឆ្អិន លាយអំបិល និងដាក់ថ្នាំការពាររុយរាល់ថ្ងៃ ។

-យើងអាចការពារជំងឺនេះបានបើសិនជាយើងចាក់ថ្នាំការពារ ៦ខែម្តង ។

(កាតលេខ ១)

ប្រភេទសត្វ : មាន់មួយហ្វូង

កន្លែងចិញ្ចឹមសត្វ : ទីធ្លាជុំវិញផ្ទះ និងនៅក្នុងផ្ទះ

កំប្លែរ១៤

ភេទ? មានញី មានឈ្មោល (កាតលេខ២)

អាយុ? គ្រប់វ័យ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? មាន់ខ្លះស៊ី និងមាន់ខ្លះមិនស៊ី

ដាក់ចំណីអ្វីអោយស៊ី? អង្ករ

ឈឺប៉ុន្មានថ្ងៃហើយ? ២ថ្ងៃ

បានឃើញសត្វយ៉ាងម៉េចខ្លះ? មាន់ខ្លះវិលៗដូចឆ្កួត និងខ្លះទៀតរបស់ងាប់ណាស់

ការព្យាបាល? ដាក់ជីអ៊ុយរេក្នុងទឹកអោយផឹក

សត្វផ្សេងទៀតឈឺឬអត់? មាន់ទាំងអស់ក្នុងភូមិឈឺ

(កាតលេខ ៣)

កំដៅខ្លួនសត្វ? (មិនចាំបាច់វាស់កំដៅសត្វមាន់ឡើយ ព្រោះមាន់ឈឺនិងមាន់ជាទាំងអស់មានកំដៅក្តៅស្រាប់ហើយ)

ទំងន់ប៉ុន្មានគីឡូ? ប្រហែលតិចជាងពាគក្រ (កាតលេខ៤)

ធាត់ រឺស្គម? ធម្មតា

តិច ឬ ខ្លាំង? សំកុកខ្លាំងណាស់

ដំណើរ? មិនអាចដើរបាន

លាមក? ធម្មតា

ដង្ហើម? មាន់ខ្លះក្អក

មាត់ ច្រមុះ? ហៀរទឹកមាត់ ទឹកសំបោរ

ភ្នែក? ក្រហម

ស្បែក និងរោម? ពណ៌ខ្មៅស្រអាប់

( កាតលេខ ៥ )

<u>ការសង្ស័យលើមូលហេតុនៃជំងឺ?</u>

*-មានមេរោគចូលរុករានក្នុងខ្លួនមាន់*

<u>ការព្យាបាល?</u> *-ប្រើថ្នាំសំលាប់មេរោគ* ( កាតលេខ ៦ )

*-ប្រើថ្នាំជំនួយពោះវៀនស្រូបជាតិទឹក*

<u>ដំបូន្មានដល់ម្ចាស់សត្វ :</u>

*-ជំងឺនេះប្រហែលជាជំងឺញូវកាស ។ មាន់ជាច្រើនត្រូវស្លាប់ ព្រោះមិនបានចាក់ថ្នាំការពារជំងឺនេះ ។ ចូរដាក់ទឹក លាយជាមួយអូរ៉ាលិត អោយមាន់ផឹក ( កុំដាក់ជីអុយរ៉េ ) ។*

*-កុំភ្លេចហៅខ្ញុំមកចាក់ថ្នាំការពារអោយមាន់របស់អ្នកនៅពេល មាន់មិនទាន់ឈឺ ។*

( កាតលេខ ១ ) កំប្លែរ១៧

<u>ប្រភេទសត្វ :</u> *សត្វក្របី*

<u>កន្លែងចិញ្ចឹមសត្វ :</u> *ក្រោលស្អាតនៅពេលយប់*

<u>ភេទ?</u> *ញី* ( កាតលេខ ២ )

<u>អាយុ?</u> *៦ឆ្នាំ*

<u>ក្រៀវ ឬអត់?</u> *អត់*

<u>ការស៊ីចំណី?</u> *មិនស៊ីចំណី*

<u>ដាក់ចំណីអ្វីអោយស៊ី?</u> *ស្មៅ និងចំបើង*

<u>ឈឺប៉ុន្មានថ្ងៃហើយ?</u> *១ម៉ោងមុនទេ*

<u>បានឃើញសត្វយ៉ាងម៉េចខ្លះ?</u> *វាមិនក្រោកឈរសោះ*

<u>ការព្យាបាល?</u> *អត់*

<u>សត្វផ្សេងទៀតឈឺឬអត់?</u> *ក្របី២ក្បាលស្លាប់យប់មិញ និងមានឃើញហៀរ ឈាមតាមច្រមុះ និងតាមគូទ ។*

( កាតលេខ ៣ )

<u>កំដៅខ្លួនសត្វ?</u> *៤១ អង្សា*

<u>ទំងន់ប៉ុន្មានគីឡូ?</u> *ប្រហែល៣០០គក្រ* ( កាតលេខ ៤ )

<u>ធាត់ រឺស្គម?</u> *ធម្មតា*

<u>តិច ឬ ខ្លាំង?</u> *អន់ខ្លាំងណាស់*

<u>ដំណើរ?</u> *មិនក្រោកឈរសោះ*

<u>លាមក?</u> *អត់*

<u>ទឹកនោម?</u> *អត់*

<u>ដង្ហើម?</u> *ដកដង្ហើមញាប់*

<u>មាត់ ច្រមុះ?</u> *ច្រមុះស្ងួត*

<u>ភ្នែក?</u> *ភ្នែកក្រហម*

<u>ស្បែក និងរោម?</u> *ធម្មតា*

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគចូលរុករានក្នុងខ្លួនក្របីហើយ

ការព្យាបាល? -ប្រើថ្នាំសំលាប់មេរោគ (កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

-ក្របី២ក្បាលដែលស្លាប់យប់មិញប្រហែលជាមានជំងឺឈាមខ្មៅ ដូចនេះក្របីនេះប្រហែលជាកើតជំងឺនេះដែរ ហើយអាចស្លាប់ផង ។ ជំងឺនេះគ្រោះថ្នាក់ណាស់ចំពោះសត្វ និងមនុស្ស ។ ត្រូវកប់ខ្មោចក្របីនិងហាមវះកាត់វា ។ ត្រូវទៅហៅភ្នាក់ងារសុខភាពសត្វភូមិអោយមកចាក់ថ្នាំការពារគោ ក្របីក្នុងភូមិជាប្រញាប់ ដើម្បីបញ្ឈប់ការចំលងជំងឺនេះទៀត ។

(កាតលេខ ១)

ប្រភេទសត្វ : សត្វជ្រូក

កន្លែងចិញ្ចឹមសត្វ : លែងអោយវាដើរដោយសេរី

កំប្លេរ១៤

ភេទ? ឈ្មោល (កាតលេខ ២)

អាយុ? ២ខែ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? ស៊ីចំណីធម្មតា

ដាក់ចំណីអ្វីអោយស៊ី? បបរ លាយកន្ទក់

ឈឺប៉ុន្មានថ្ងៃហើយ? វាក្អក២អាទិត្យមកហើយ

បានឃើញសត្វយ៉ាងម៉េចខ្លះ? វាក្អកខ្លាំងណាស់

ការព្យាបាល? អត់

សត្វផ្សេងទៀតឈឺឬអត់? អត់

(កាតលេខ ៣)

កំដៅខ្លួនសត្វ? ៣៨ អង្សា

ទំងន់ប៉ុន្មានគីឡូ? ប្រហែល១០គក្រ (កាតលេខ៤)

ធាត់ រឺស្គម? ស្គមតិចៗ

តិច ឬ ខ្លាំង? ធម្មតា

ដំណើរ? ធម្មតា

លាមក? ធម្មតា

ទឹកនោម? ធម្មតា

ដង្ហើម? ក្អក

មាត់ ច្រមុះ? ធម្មតា

ភ្នែក? ធម្មតា

ស្បែក និងរោម? ស្បែកស្ងួតខ្លាំង និងរោមបះ

( កាតលេខ ៥ )

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានព្រូនក្នុងសួត

( កាតលេខ ៦ )

ការព្យាបាល?

-ប្រើថ្នាំសំលាប់ព្រូន

ដំបូន្មានដល់ម្ចាស់សត្វ :

-ជ្រូកដែលចិញ្ចឹមអោយដើរសេរីអញ្ចឹង ងាយវានិងមានព្រូនណាស់ ជ្រូកមានព្រូនវាស៊ីច្រើនណាស់ តែវាមិនធំធាត់ទេ ។ បើសិនជាអ្នកចង់ឱ្យ ជ្រូកធំធាត់លឿនត្រូវចិញ្ចឹមវានៅក្នុងទ្រុងស្អាត ហើយដាក់ចំណីល្អៗអោយ វាស៊ីដោយបន្ថែមបន្លែស្រស់ និងសណ្តែកសៀងលាយត្រីឱ្យវាស៊ីផង ។

ចូរដាក់ទឹកអោយវាផឹកបានគ្រប់គ្រាន់ ។

( កាតលេខ ១ )

ប្រភេទសត្វ : សត្វគោ

កន្លែងចិញ្ចឹមសត្វ : កន្លែងស្អាតនៅក្រោមដើមឈើ នៅពេលយប់ និងពេលថ្ងៃដើរស៊ីស្មៅនៅតាមវាលស្រែ

កំប្លែរ១៥

( កាតលេខ ២ )

ភេទ? ញី

អាយុ? ១ឆ្នាំ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? អត់ស៊ីចំណី

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? តាំងពីម្សិលមិញ

បានឃើញសត្វយ៉ាងម៉េចខ្លះ? ឈឺជើងក្រោយខាងឆ្វេង

ការព្យាបាល? បានព្យាបាលថ្នាំខ្មែរ

សត្វផ្សេងទៀតឈឺឬអត់? អត់

( កាតលេខ ៣ )

កំដៅខ្លួនសត្វ? ៤០ អង្សា

( កាតលេខ៤ )

ទំងន់ប៉ុន្មានគីឡូ? ប្រហែល១៤០គក្រ

ធាត់ រឺស្គម? ធាត់

តិច ឬ ខ្លាំង? អន់ខ្លាំងណាស់

ដំណើរ? ឈរ ពិការជើងឆ្វេងក្រោយ

លាមក? ធម្មតា

ទឹកនោម? មិនបានឃើញ

ដង្ហើម? ញាប់

មាត់ ច្រមុះ? ច្រមុះស្ងួត

ភ្នែក? ធម្មតា

ស្បែក និងរោម? ហើមប៉ោងយ៉ាងធំនៅលើត្រគាតឆ្វេង និងមានសំលេង ក្រិបៗពេលស្ទាបកន្លែងហើមនោះ ។

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគចូលរុករានក្នុងខ្លួនសត្វ (ប្រហែលជាមេរោគនេះនៅក្នុងជើងផ្ទេង) ។

ការព្យាបាល? -ប្រើថ្នាំសំលាប់មេរោគ (កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

-ជំងឺនេះប្រហែលជាជំងឺបូសខ្យល់ ។ គោនេះឈឺខ្លាំងណាស់ ហើយអាចស្លាប់ផង បើវាមិនស្លាប់ទេ វានឹងមានដំបៅលើជើងនេះក្នុងរយៈពេលយូរ ។ ត្រូវចាក់ថ្នាំការពារជំងឺនេះអោយគោជំទង់ៗទាំងអស់ដែលនៅក្នុងភូមិរបស់អ្នក ។

-ចូរដាក់ទឹក និងចំណីឱ្យបានគ្រប់គ្រាន់ ។

(កាតលេខ ១)

ប្រភេទសត្វ : មាន់មួយហ្វូង

កន្លែងចិញ្ចឹមសត្វ : ទីធ្លាជុំវិញផ្ទះ និងនៅក្នុងផ្ទះ

កំប្លេរ១៦

ភេទ? មានញី មានឈ្មោល (កាតលេខ២)

អាយុ? មាន់មានអាយុប្រហែលពី ៥ទៅ១០ខែ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? មាន់ខ្លះស៊ី និងមាន់ខ្លះមិនស៊ី

ដាក់ចំណីអ្វីអោយស៊ី? អង្ករ

ឈឺប៉ុន្មានថ្ងៃហើយ? មាន់ខ្លះបានចាប់ផ្តើមឈឺពីអាទិត្យមុន និងឥឡូវមាន់ផ្សេងទៀតកំពុងឈឺ

បានឃើញសត្វយ៉ាងម៉េចខ្លះ? ក្អក និងរាគ

ការព្យាបាល? អត់

សត្វផ្សេងទៀតឈឺឬអត់? មាន់អ្នកជិតខាងឈឺខ្លះៗដែរ

(កាតលេខ ៣)

កំដៅខ្លួនសត្វ? (មិនចាំបាច់វាស់កំដៅសត្វមាន់ឡើយ ព្រោះមាន់ឈឺនិងមាន់ជាទាំងអស់មានកំដៅក្តៅស្រាប់ហើយ)

ទំងន់ប៉ុន្មានគីឡូ? ០.៥ ទៅ១គក្រ (កាតលេខ៤)

ធាត់ រឺស្គម? ធម្មតា

តិច ឬ ខ្លាំង? សំកុកខ្លាំងណាស់

ដំណើរ? មិនចង់ដើរ

លាមក? រាគធំក្លិនអាក្រក់

ដង្ហើម? មាន់ខ្លះក្អក

មាត់ ច្រមុះ? ហៀរ ទឹកសំបោរ

ភ្នែក? ក្រហម

ស្បែក និងរោម? ពណ៌ខ្មៅស្រអាប់

មានអ្វីផ្សេងទៀត? មាន់ដែលឈឺក្នុងរយៈពេលយូរហើយឃើញមានហើមកែ

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានមេរោគចូលរុករានក្នុងខ្លួនមាន់

(កាតលេខ ៦)

ការព្យាបាល? -ប្រើថ្នាំសំលាប់មេរោគ

-ប្រើថ្នាំជំនួយពោះវៀនស្រូបជាតិទឹក

ដំបូន្មានដល់ម្ចាស់សត្វ :

-ជំងឺនេះប្រហែលជាជំងឺអាសន្នរោគ ។ មាន់ជាច្រើនត្រូវស្លាប់ដោយសារជំងឺនេះ ។ ចូរដាក់ទឹកលាយជាមួយថ្នាំអូរ៉ាលីត ឱ្យមាន់ផឹក។ ត្រូវកប់ខ្មោចមាន់អោយបានល្អដើម្បីកុំអោយឆ្លងទៅមាន់ផ្សេងទៀត។

(កាតលេខ ១) កំប្លែរ១៧

ប្រភេទសត្វ : សត្វក្របី

កន្លែងចិញ្ចឹមសត្វ : ក្រោលស្អាតនៅពេលយប់ . វាទៅស៊ីចំណីឯវាលស្រែនៅពេលថ្ងៃ

(កាតលេខ ២)

ភេទ? ឈ្មោល

អាយុ? ៣ខែ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? វាស៊ីតិចតួច មិនទាន់លែងដោះទេ

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងទឹកដោះមេវា

ឈឺប៉ុន្មានថ្ងៃហើយ? ២ ឬ៣អាទិត្យមកហើយ

បានឃើញសត្វយ៉ាងម៉េចខ្លះ? វាចេះតែចុះខ្សោយៗ ទោះបីមេវាមានទឹកដោះក៏ដោយ

ការព្យាបាល? អត់

សត្វផ្សេងទៀតឈឺឬអត់? កូនក្របីខ្លះទៀតនៅក្នុងភូមិនេះក៏ឈឺនិងស្លាប់ដែរ ។

(កាតលេខ ៣)

កំដៅខ្លួនសត្វ? ៣៨.៥ អង្សា

(កាតលេខ៤)

ទំងន់ប៉ុន្មានគីឡូ? ប្រហែល៥០គក្រ

ធាត់ រឺស្គម? ស្គម

តិច ឬ ខ្លាំង? អន់តិចៗ

ដំណើរ? ធម្មតា

លាមក? មិនបានឃើញ

ទឹកនោម? ធម្មតា

ដង្ហើម? ធម្មតា

មាត់ ច្រមុះ? ធម្មតា

ភ្នែក? ធម្មតា

ស្បែក និងរោម? ស្ងួត បះរោម

មានអ្វីផ្សេងទៀត? ហើមពោះ

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានព្រូននៅក្នុងពោះក្របី

ការព្យាបាល? -ប្រើថ្នាំសំលាប់ព្រូន (កាតលេខ ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

-កូនក្របីនេះមានព្រូនច្រើនណាស់ ។ ព្រូននេះអាចធ្វើអោយក្របី ស្លាប់បាន ។ ដូចនេះការទំលាក់ព្រូនជាការចាំបាច់ណាស់ មុនពេលវាធ្វើអោយកូនក្របីឈឺ ។

-សូមកុំភ្លេចអោយទឹកវា និងមេវាផឹកអោយបានគ្រប់គ្រាន់

(កាតលេខ ១) កំប្លែរ១៨

ប្រភេទសត្វ : សត្វជ្រូក

កន្លែងចិញ្ចឹមសត្វ : កន្លែងស្អាតនៅក្រោមផ្ទះ

(កាតលេខ ២)

ភេទ? ឈ្មោល

អាយុ? ២ឆ្នាំ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? មិនស៊ីចំណី

ដាក់ចំណីអ្វីអោយស៊ី? បបរ លាយកន្ទក់

ឈឺប៉ុន្មានថ្ងៃហើយ? តាំងពីម្សិលមិញ

បានឃើញសត្វយ៉ាងម៉េចខ្លះ? មេជ្រូកហាក់ដូចជាគ្មានទឹកដោះ ។ ដូច្នេះកូនវាហាក់ដូចជាឃ្លានខ្លាំង ។

ការព្យាបាល? អត់បានព្យាបាល

រោមនិងស្បែក? ធម្មតា

សត្វផ្សេងទៀតឈឺឬអត់? អត់

(កាតលេខ ៣)

កំដៅខ្លួនសត្វ? ៣៨.៥ អង្សា

(កាតលេខ៤)

ទំងន់ប៉ុន្មានគីឡូ? ប្រហែល១២០គក្រ

ធាត់ រឺស្គម? ធម្មតា

តិច ឬ ខ្លាំង? អន់បន្តិចបន្តួច

ដំណើរ? មិនចង់ដើរ

លាមក? ទល់លាមក

ទឹកនោម? ពណ៌លឿងក្រមៅ

ដង្ហើម? ធម្មតា

មាត់ ច្រមុះ? ធម្មតា

ភ្នែក? ធម្មតា

ស្បែក និងរោម? ធម្មតា

មានអ្វីផ្សេងទៀត? មានខ្ទុះហៀរចេញតាមផ្លូវបន្តពូជ

( កាតលេខ ៦)

<u>ការព្យាបាល?</u>

-ប្រើថ្នាំសំលាប់មេរោគ និងថ្នាំជួយអោយពោះវៀនស្រូបជាតិទឹក ទៅក្នុងខ្លួន

<u>ដំបូន្មានដល់ម្ចាស់សត្វ :</u>

-ត្រូវដាក់ទឹកលាយជាមួយថ្នាំអូរ៉ាលិតអោយជ្រូកផឹកអោយបានគ្រប់គ្រាន់ ។

-បង្កើនគុណភាពចំណីជ្រូកដោយបន្ថែមបន្លែស្រស់ និងសណ្តែកសៀងលាយជាមួយត្រីផង ។

( កាតលេខ ១)

កំប្លេរ១៩

<u>ប្រភេទសត្វ :</u> *សត្វគោ*

<u>កន្លែងចិញ្ចឹមសត្វ :</u> *កន្លែងស្អាតនៅក្រោមដើមឈើ នៅពេលយប់ និងពេលថ្ងៃដើរស៊ីស្មៅនៅតាមវាលស្រែ*

( កាតលេខ ២)

<u>ភេទ?</u> *ឈ្មោល*

<u>អាយុ?</u> *៣ឆ្នាំ*

<u>ក្រៀវ ឬអត់?</u> *ក្រៀវ*

<u>ការស៊ីចំណី?</u> *ស៊ីចំណីតិចៗ*

<u>ដាក់ចំណីអ្វីអោយស៊ី?</u> *ស្មៅ និងចំបើង*

<u>ឈឺប៉ុន្មានថ្ងៃហើយ?</u> *១ខែហើយ*

<u>បានឃើញសត្វយ៉ាងម៉េចខ្លះ?</u> *ពេលខ្លះទល់ពេលខ្លះរាគ*

<u>ការព្យាបាល?</u> *បានព្យាបាលថ្នាំខ្មែរ*

<u>សត្វផ្សេងទៀតឈឺឬអត់?</u> *គោខ្លះនៅក្នុងភូមិឈឺដែរ ។*

( កាតលេខ ៣)

<u>កំដៅខ្លួនសត្វ?</u> *៣៨.៥ អង្សា*

( កាតលេខ៤)

<u>ទំងន់ប៉ុន្មានគីឡូ?</u> *ប្រហែល២០០គក្រ*

<u>ធាត់ រឺស្គម?</u> *ស្គម*

<u>តិច ឬ ខ្លាំង?</u> *អន់តិចៗ*

<u>ដំណើរ?</u> *ធម្មតា*

<u>លាមក?</u> *ធម្មតា*

<u>ទឹកនោម?</u> *មិនបានឃើញ*

<u>ដង្ហើម?</u> *ធម្មតា*

<u>មាត់ ច្រមុះ?</u> *ហៀរសំបោរតិចៗ*

<u>ភ្នែក?</u> *ធម្មតា*

<u>ស្បែក និងរោម?</u> *ស្បែកស្ងួត រោមបះ*

(កាតលេខ ៥)

ការសង្ស័យលើមូលហេតុនៃជំងឺ?

-មានព្រូននៅក្នុងថ្លើម និងនៅក្នុងពោះវៀន

ការព្យាបាល? -ប្រើថ្នាំសំលាប់ព្រូន (កាតលេខ៦)

ដំបូន្មានដល់ម្ចាស់សត្វ :

-គោដែលចូលចិត្តស៊ីស្មៅទឹក វាតែងតែស៊ីដោយកូនព្រូនដែលវាចូលចិត្តរស់នៅក្នុងថ្លើមគោ បើសិនជាធ្វើការទំលាក់ព្រូននេះអោយគោទាំងអស់នៅក្នុងភូមិនេះនៅដើមរដូវវស្សាម្តង និងចុងខែវស្សាម្តង នោះសង្ឃឹមអាចការពារជំងឺនេះបាន ។

(កាតលេខ ១)

ប្រភេទសត្វ : សត្វគោ

កន្លែងចិញ្ចឹមសត្វ : កន្លែងស្អាតនៅក្រោមដើមឈើនៅពេលយប់ និងពេលថ្ងៃដើរស៊ីស្មៅនៅតាមវាលស្រែ

កំប្លែរ២០

ភេទ? ញី (កាតលេខ២)

អាយុ? ៦ឆ្នាំ

ក្រៀវ ឬអត់? អត់

ការស៊ីចំណី? មិនស៊ីចំណី

ដាក់ចំណីអ្វីអោយស៊ី? ស្មៅ និងចំបើង

ឈឺប៉ុន្មានថ្ងៃហើយ? ២ថ្ងៃហើយ

បានឃើញសត្វយ៉ាងម៉េចខ្លះ? គោនេះហាក់ដូចជាមិនសប្បាយចិត្ត វាចេះតែស្រែករោទ៏ ហើយមានហៀរទឹកមាត់ច្រើន

ការព្យាបាល? អត់

សត្វផ្សេងទៀតឈឺឬអត់? អត់

(កាតលេខ ៣)

កំដៅខ្លួនសត្វ? គោកញ្ជ្រោលខ្លាំង និងមិនអាចវាស់កំដៅបានឡើយ

ទំងន់ប៉ុន្មានគីឡូ? ប្រហែល៣០០គក្រ (កាតលេខ៤)

ធាត់ រឺស្គម? ធម្មតា

តិច ឬ ខ្លាំង? អន់

ដំណើរ? ធម្មតា

លាមក? ធម្មតា

ទឹកនោម? មិនបានឃើញ

ដង្ហើម? ដកដង្ហើមញាប់

មាត់ ច្រមុះ? ហៀរទឹកមាត់

ភ្នែក? បើកភ្នែកធំៗ

មានឃើញអ្វីទៀត ជ្រួលច្រាល ឆ្លេឆ្លា ស្រែករោទ៏ច្រើន

( កាតលេខ ៥)

<u>ការសង្ស័យលើមូលហេតុនៃជំងឺ?</u>

*-មានមេរោគចូលរុករានក្នុងខ្លួនសត្វ ( ប្រហែលជាមេរោគនេះឆ្លងពីឆ្កែឆ្កួត)*

<u>ការព្យាបាល?</u> ( កាតលេខ ៦)

*-ហួសពេលក្នុងការព្យាបាលហើយ*

<u>ដំបូន្មានដល់ម្ចាស់សត្វ :</u>

*-ជំងឺនេះប្រហែល ជាជំងឺឆ្កួតដោយសារឆ្កែឆ្កួតខាំកាលពីប៉ុន្មានអាទិត្យមុន ។ បើអញ្ចឹងគោនេះត្រូវស្លាប់ ។ ទឹកមាត់គោនេះវាធ្វើអោយមានគ្រោះថ្នាក់ណាស់ បើអ្នកបានប្រឡាក់ទឹកមាត់វាត្រូវទៅមន្ទីរពិសោធន៍មើល បើវានៅរស់បាន ១០ថ្ងៃ នោះវាគ្មានគ្រោះថ្នាក់ទៀតទេ តែបើស្លាប់ក្នុង រយៈពេលនេះ ហាមវះកាត់នឹងត្រូវកប់វាអោយជ្រៅ។*

**ត៌មានស្តីពីជំងឺសត្វៈ** ភូមិ.......................... ឃុំ........................... ស្រុក.......................... ខេត្ត...................

គោ ☐ ក្របី ☐ ជ្រូក ☐ មាន់ ☐ សត្វផ្សេងៗ.....................

ឈ្មោះម្ចាស់សត្វ..............................

កន្លែងចិញ្ចឹមល្អ ☐ កន្លែងចិញ្ចឹមមិនល្អ ☐

ឈ្មោះបសុពេទ្យ............... ថ្ងៃ........ខែ........ឆ្នាំ...........

ឈ្មោល/ញី............. អាយុ.......... ក្រៀវ/អត់ក្រៀវ............... ជើម/អត់ជើម/មានកូនបៅដោះ.................................

សត្វស៊ីចំណីមានសភាពយ៉ាងម៉េច?.............................................................................................

ដាក់ចំណីអ្វីអោយសត្វស៊ី?......................................................................................................

សត្វឈឺប៉ុន្មានថ្ងៃហើយ?........................................................................................................

សត្វឈឺអ្វីខ្លះ?.....................................................................................................................

ព្យាបាលថ្នាំអ្វី?...................................................................................................................

មានសត្វផ្សេងទៀតឈឺទេ?.......................................................................................................

កំដៅប៉ុន្មាន?.................................

៤ ទំងន់ប៉ុន្មាន គក្រ?............. សត្វធាត់ ☐ ធម្មតា ☐ សត្វស្គម ☐

សត្វអន់តិច ☐ សត្វអន់ខ្លាំង ☐

សត្វដើរធម្មតា ☐ ដើរមិនធម្មតា ☐ ដំណើរយ៉ាងម៉េច?..............................................

លាមកធម្មតា ☐ លាមករាគលាមកក្អៀន ☐ មានសភាពយ៉ាងម៉េច?..........................................

ទឹកនោមធម្មតា ☐ ទឹកនោមមិនធម្មតា ☐ មានសភាពដូចម្តេច?..........................................

សត្វដកដង្ហើមធម្មតា ☐ សត្វដកដង្ហើមញាប់ ☐ សត្វក្អកមានសភាពដូចម្តេច?..............................

មាត់ច្រមុះធម្មតា ☐ មាត់ច្រមុះមិនធម្មតា ☐ មានសភាពយ៉ាងម៉េច?..........................................

ភ្នែកធម្មតា ☐ ភ្នែកមិនធម្មតា ☐ មានសភាពយ៉ាងម៉េច?..........................................

ស្បែកនិងរោមធម្មតា ☐ ស្បែកនិងរោមមិនធម្មតា ☐ មានសភាពយ៉ាងម៉េច?..........................................

មានបញ្ហាអ្វីផ្សេងទៀត?........................................................................................................

៥

សត្វឈឺបណ្តាលមកពី :



៦

ការព្យាបាលដោយប្រើថ្នាំអ្វី?

ឈ្មោះថ្នាំ ប៉ុន្មានCC (គ្រាប់) ម្តង

១.......................................... ..........................................

២.......................................... ..........................................

ការណែនាំដល់ម្ចាស់សត្វ ..........................................................................................

បានព្យាបាលប៉ុន្មានថ្ងៃ :..................សត្វជា ☐ សត្វមិនជា ☐ សត្វស្លាប់ ☐

# កម្មវិធីបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ

៚៚៚

| អាទិត្យ | ថ្ងៃ ខែ ឆ្នាំ | មុខវិជ្ជា |
|---|---|---|
| ទី១ | ទី១ | -ពិធីបើកវគ្គបណ្តុះបណ្តាល<br>-ការណែនាំឱ្យស្គាល់គ្នាទៅវិញទៅមក<br>-ការបង្ហាញជូននូវកម្មវិធីបណ្តុះបណ្តាល |
| | | -ដំណើរការរបស់សត្វពេលមានសុខភាពល្អ<br>-អ្វីដែលសត្វត្រូវការឱ្យមានសុខភាពល្អ<br>-សកម្មភាពសិក្សាលើជ្រូករស់មួយក្បាល |
| | ទី២ | -ការបង្ហាញសរីរាង្គក្នុងរបស់សត្វ និង ទីតាំងរបស់សរីរាង្គទាំងនោះ<br>-តួនាទីរបស់សរីរាង្គក្នុងនីមួយៗ |
| | | -ការលេងល្បែងបញ្ជាក់ពីដំណើរការរបស់សត្វមានសុខភាពល្អ<br>-ដាក់ឈ្មោះសរីរាង្គខាងក្នុងទាំងនោះ និងការលេងល្បែង |
| | ទី៣ | -គូសបំព្រួញនូវចលនារបស់ទឹក ចំណី ខ្យល់ នៅពេលដែលវាចូលទៅក្នុងខ្លួនសត្វ<br>-បង្កើតផ្ទាំងរូបភាពសំរាប់ល្បែងខាងលើ |
| | | -ធ្វើលំហាត់តាមក្រុមនិងតំណាងសមាជិកនៃក្រុមនីមួយៗ និងឡើងធ្វើការពន្យល់ដល់សិក្ខាកាម ។<br>-ការពន្យល់សង្ខេបឡើងវិញ និងធ្វើសំនួរត្រួតពិនិត្យ |
| | ទី៤ | -តើអ្វីដែលធ្វើឱ្យសត្វឈឺឬស្គម?និងអ្វីដែលអាចជួយឱ្យសត្វមានសុខភាពល្អឡើងវិញ?<br>-កត្តា ៦យ៉ាងដែលធ្វើឱ្យសត្វឈឺ ឬស្គម<br>-វិធី ៥យ៉ាងដែលអាចឱ្យសត្វមានសុខភាពល្អឡើងវិញ |
| | ទី៥ | -បន្តមេរៀនពីម្សិលមិញ |
| | | -ការលេងល្បែងស្តីអំពីសត្វឈឺ<br>-ការធ្វើលំហាត់តាមក្រុមនិងអ្នកតំណាងក្រុមឡើងធ្វើការបកស្រាយជូនសិក្ខាកាម |
| | ទី៦ | -សង្ខេបមេរៀនដែលបានរៀន៣ថ្ងៃកន្លងមក<br>-សកម្មភាពភ្នាក់ងារសុខភាពសត្វភូមិពេលទៅពិនិត្យសត្វឈឺ និងដំណាក់កាលដែលត្រូវអនុវត្តន៍នៅពេលអ្នកទៅពិនិត្យសត្វឈឺ ។ |
| | | -រំលឹកមេរៀនក្នុងមួយអាទិត្យកន្លងមក<br>-សំណួរត្រួតពិនិត្យ |

| | | | |
|---|---|---|---|
| ទី២ | ទី១ | -ការចិញ្ចឹមសត្វឱ្យមានសុខភាពកាន់តែល្អ និងការការពារសត្វកុំឱ្យឈឺ<br>-ការថែរក្សាឱ្យសត្វសប្បាយចិត្ត<br>-ការផ្តល់ចំណីអាហារឱ្យសត្វបានគ្រប់គ្រាន់<br>-ការការពារជំងឺដែលបង្កឡើងដោយព្រូន<br>- ការការពារជំងឺដែលបង្កឡើងដោយមេរោគ | |
| | ទី២ | -ការចិញ្ចឹមជ្រូក | |
| | | -ការចិញ្ចឹមបក្សី | |
| | ទី៣ | -ការបង្កើតល្បែងលេង ស្តីពីការចិញ្ចឹមសត្វ | |
| | | -ថ្នាំព្យាបាល ថ្នាំការពារ និងរបៀបប្រើប្រាស់<br>-របៀបថែរក្សា និងប្រើប្រាស់វ៉ាក់សាំង និងថ្នាំព្រូន | |
| | ទី៤ | -កំរិតនៃការប្រើប្រាស់ និងការគណនានូវតំលៃដែលម្ចាស់សត្វត្រូវបង់ | |
| | | -ពពួកអង់ទីប៊ីយ៉ូទិក | |
| | ទី៥ | -អុកស៊ីតុកស៊ីន<br>-ថ្នាំវីតាមីន | |
| | | -ពពួកថ្នាំដង្កូវបរាសិត | |
| | ទី៦ | -ការលេងល្បែងអំពីការចិញ្ចឹមសត្វដោយមាន :<br>+ការចាក់វ៉ាក់សាំង និងគណនាតំលៃ<br>+ការទំលាក់ព្រូន និងគណនាតំលៃ | |
| | | -ការលេងល្បែងអំពីការព្យាបាលសត្វ ដោយមានបញ្ចូលទាំងការព្យាបាល និងគណនា តំលៃ<br>-សង្ខេបមេរៀនមួយអាទិត្យកន្លងមក និងសំណួរត្រួតពិនិត្យ | |

| | | |
|---|---|---|
| ទី៣ | ទី១ | -ជំងឺសំខាន់របស់គោក្របីនៅកម្ពុជា<br>-ជំងឺសារទឹកគោ ក្របី |
| | | -ជំងឺបូសខ្យល់ |
| | ទី២ | -រំលឹកមេរៀនពីម្សិល<br>-ជំងឺឈាមខ្មៅ |
| | | -ជំងឺអុតក្តាមគោ ក្របី |
| | ទី៣ | -រំលឹកមេរៀនពីម្សិល<br>-ជំងឺបង្កដោយបរាសិត<br>-ព្រូនមូលគោ ក្របី |
| | | -ជំងឺបង្កដោយហ្វាស្យូឡា |
| | ទី៤ | -រំលឹកមេរៀនពីម្សិល<br>-ជំងឺបង្កដោយបរាសិតខាងក្រៅ |
| | | -សង្ខេបមេរៀនជំងឺគោ ក្របី ដោយធ្វើតារាងប្រៀបធៀប |
| | ទី៥ | -ជំងឺសំខាន់ៗរបស់ជ្រូក<br>-ជំងឺប៉េស្តជ្រូក |
| | | - ជំងឺកញ្ជ្រិលជ្រូក<br>- ជំងឺរាគនៃសត្វជ្រូក |
| | ទី៦ | - ជំងឺហើមស្វត |

| | | | |
|---|---|---|---|
| ទី៤ | ទី១ | - ជំងឺចុងអង្គរ | |
| | | -សង្ខេបមេរៀនជំងឺជ្រូក ដោយធ្វើតារាងប្រៀបធៀប<br>-សំណួរត្រួតពិនិត្យ | |
| | ទី២ | - ជំងឺសំខាន់ៗរបស់បក្សី<br>- ជំងឺបណ្តាលមកពីព្រូន<br>- ជំងឺញូវកាស | |
| | | - ជំងឺអាសន្នរោគបក្សី និង ជំងឺផ្តាសាយបក្សី<br>- ជំងឺរាគស និងសាល់ម៉ូណែលឡូស | |
| | ទី៣ | - ជំងឺអុត<br>- ជំងឺកុកស៊ីឌីយ៉ូស៊ីសបក្សី | |
| | | -សង្ខេបមេរៀន ជំងឺបក្សីដោយធ្វើតារាងប្រៀបធៀប<br>-សំណួរត្រួតពិនិត្យ | |
| | ទី៤ | -ការក្រៀវសត្វគោ ក្របី ជ្រូក មាន់ | |
| | | -បន្តមេរៀនពីព្រឹក | |
| | ទី៥ | -ជំងឺមួយចំនួននៃសត្វញីបន្តពូជ | |
| | | - ជំងឺឆ្កែឆ្កួត និង ជំងឺដែលបណ្តាលមកពីឆ្កែឆ្កួតខាំ | |
| | ទី៦ | -ជំងឺកើតកូនមិនរួច<br>- សំណួរត្រួតពិនិត្យ | |
| | | -ការកត់ត្រារបស់ភ្នាក់ងារសុខភាពសត្វភូមិ<br>-ការគ្រប់គ្រងមុខនាទី<br>-ការពន្យល់ណែនាំស្តីអំពីតួនាទី និងសកម្មភាពភ្នាក់ងារសុខភាពសត្វភូមិ | |
| ទី៥ | ទី១ | -ប្រឡងបញ្ចប់ផ្នែកទ្រឹស្តី | |
| | | -ពិធីបិទវគ្គបណ្តុះបណ្តាលផ្នែកទ្រឹស្តី | |

# ជំងឺផ្តាសាយបក្សី

## គំរោងបង្កើនផលិតភាពកសិកម្ម APIP

# ការចិញ្ចឹមបក្សី



# ប្រព័ន្ធផលិតកម្មបក្សី

## លក្ខណៈគ្រួសារ៨០ -៩០%

- មាន់ ទា ក្ងាន ( ពូជស្រុក
- សំរាប់ផ្គត់ផ្គង់គ្រួសារ
- មានជាមធ្យម ១២-១៣ ក្បាល
- ក្នុងមួយគ្រួសារ

## ពាក់កណ្ដាលឧស្សាហកម្មឯកជន

- មាន់សាច់ ១៣៥ កន្លែង ( ៦៨៧.១៨៣ក្បាល
- មាន់ពង ៦៧ កន្លែង ( ៣៦៧.៨៧០ក្បាល
- ទា ៩៧៦ កន្លែង ( ៨៧៨.៧៤២ក្បាល

# ជំងឺបក្សីដែលមាននៅកម្ពុជា

**ជំងឺជាប្រចាំ**

- ញ្ញីវកាស
- សាល់ម៉ូណែឡា
- អាសន្នរោគបក្សី
- អុជមាន់
- ប៉េស្តទា
- ជំងឺប៉ារ៉ាសិត

**ជំងឺកើតមានជាអន្លើ**

- រលាកសួត និងបំពង់ខ្យល់
- ហ្គូមបូរ៉ូ

**ផ្តាសាយបក្សី**
(Avian Influenza)
**(H5N1) !**

?

# តើជំងឺផ្តាសាយបក្សីជាអ្វី?

- ជាប៉េស្តបក្សី
- អាចបណ្តាលអោយមានអាត្រាសាប់ខ្ពស់
- បង្កដោយ Orthomyxovirus ប្រភេទ A, RNA
- មានពក់ព័ន្ធទៅនឹងវីរុសផ្តាសាយមនុស្ស ប្រភេទ A
- ចែកចេញជា សណ្ឋានជំងឺសាហាវ និងមិនសូវសាហាវ

# អំពីរោគសញ្ញាជំងឺផ្កាសាយបក្សី

- អត្រាស្លាប់ខ្ពស់ភ្លាមៗ
- ធ្លាក់ចុះនៃផលិតផលស៊ុត
- មានរោគសញ្ញាប្រព័ន្ធដកដង្ហើម
- ហើមក្បាល
- មានជាំមឈាមក្រោមស្បែក និង ស្បែកពណ៌ស្វាយ
- មានរាគរូស

# ក្បាលពណ៌ស្វាយ



ហើមក្បាល សេនិងណង់ហើមប៉ោង



សេ និង ណង់ពណិស្វាយ



# ដាមដាំឈាម



មានស្លាកស្នាមជាំឈាមលើស្រោមបេះដូង ពេលធ្វើការវះកាត់



# អំពីការចំលងនៃវីរុសផ្តាសាយបក្សី

- លូតលាស់និងបង្កកំណើតនៅក្នុងប្រព័ន្ធដង្ហើម និងរំលាយអាហារ
- ចំលងតាមរយៈសត្វស្លាបទឹក
- មានការចំលងតាមផ្លូវនៃចលនាបក្សីព្រៃ
- ចំលងតាមរយៈការប៉ះផ្ទាល់ សំបោរបក្សីឈឺតាមផ្លូវដង្ហើម
- ចំលងតាមរយៈបក្សីទឹក មនុស្ស ។ល។
- ចំលងតាមរយៈ រថយន្ត ទូក ឧបករណ៍ប្រើប្រាស់

# របៀបចំលងជំងឺ

- ពីបក្សីទៅបក្សីតាមរយៈលាមកឬដំណក់ដង្ហើមផ្ទាល់
- ចំណី និង ទឹកដែលមានវីរុស
- ការចេញ-ចូលនៃបក្សី មនុស្ស ។ល។ ក្នុងកសិដ្ឋាន
- មនុស្ស-សត្វ មានការប៉ះពាល់ជាមួយបក្សីឈឺៈ
  - ជាអ្នកដឹកនាំវីរុសពីកន្លែងមួយទៅកន្លែងផ្សេងទៀត
  - ជាភ្នាក់ងារផ្ទុក និងចំលងវីរុស
- រយៈពេលសំងំនៃជំងឺ ពី ៣ ទៅ ២១ថ្ងៃ

# ភាពធន់នៃវីរុស

- អាចរស់បាន ៤ ថ្ងៃនៅក្នុងទឹកដែលមានសីតុណ្ហភាព ២២អង្សារ
- លើសពី ៣០ថ្ងៃ នៅសីតុណ្ហភាព ០ អង្សារ
- បាត់សកម្មភាពបង្ករោគនៅសីតុណ្ហភាព ៥៦អង្សាររយះពេល៣ម៉ោង
- នៅភាពអាស៊ីត និង នៅធាតុអុកស៊ីតកម្ម
- ងាប់ដោយហ្វ័រម៉ុល និង សារធាតុអ៊ីយ៉ូត

# ចលនានៃបក្សីទឹក-ព្រៃលើពិភពលោក
# ពាក់ព័ន្ធទៅនឹងវីរុសបង្កជំងឺផ្តាសាយបក្សី



# ប្រភពនៃការរាតត្បាតជំងឺផ្តាសាយបក្សី

- ជាទូទៅគេរកឃើញវីរុសបង្កជំងឺផ្តាសាយបក្សី
  - នៅលើបក្សីសមុទ្រ និង
  - បក្សីទឹកពនេចរ
- ការចំលងកើតឡើងតាមរយៈលាមកបក្សីឈើនៅក្នុងទឹកបឹងបួរ -ទន្លេ

# ការព្យាបាលចំពោះបក្សីឈឺ

- គ្មានថ្នាំសំរាបព្យាបាលទេ
- ✓ ការគ្រប់គ្រងការចិញ្ចឹមល្អ ចំណីលាយជាមួយអង់ទិប៊ីយ៉ូទិច
- ✓ អាចកាត់បន្ថយការបាត់បង់
- ✓ បក្សីឈឺជាធម្មតាគឺអនុត្តវិធានបសុពេទ្យ បំផ្លាញចោល និងធ្វើការរំងាប់មេរោគ
- ✓ ការការពារ និងការអនុវត្តសុវត្ថភាពជីសាស្ត្រ ជាការចំបាច់

# តំបន់រាតត្បាតជំងឺផ្តាសាយបក្សីនៅកម្ពុជា (គ



# វិធានការណ៍ ត្រួតពិនិត្យ និង ការពារ

# នៃជំងឺផ្តាសាយបក្សី

ការផ្ទុះជំងឺនៅអាស៊ី និង ប្រទេសជិតខាង

↓

ក្រុមតាមដាន ត្រួតពិនិត្យ និងប្រតិកម្មរហ័ស

↑

ក្រុមបសុពេទ្យខេត្ត-ក្រុង និងភ្នាក់ងារសុខភាពសត្វភូមិ

វិធានការណ៍ច្បាប់

វិធានបសុពេទ្យ

← កសិដ្ឋានផ្ទុះជំងឺ-យកសំណាកធ្វើរោគវិនិច្ឆ័យ

# វិធានបសុពេទ្យ



# វិធានការណ៍ច្បាប់

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (កសក

- ថ្ងៃទី ១២ មករា ២០០៤ សេចក្ដីជូនដំណឹងស្ដីពីការទប់ស្កាត់នូវការឆ្លង រាលដាលជំងឺ ផ្ដាសាយបក្សី
- ថ្ងៃទី ១៦ មករា ២០០៤ ប្រកាសស្ដីពីការបង្កើតស្នាក់ការត្រួតពិនិត្យ អានាម័យសត្វ-ផលិតផលមានដើមកំណើតពីសត្វ ជាបណ្ដោះអាសន្ន
- ថ្ងៃទី ១៦ មករា ២០០៤ ប្រកាសស្ដីពីការទប់ស្កាត់ នូវការឆ្លងរាលដាល ជំងឺផ្ដាសាយបក្សី
- ថ្ងៃទី ២២ មករា ២០០៤ បង្កើតគណៈកម្មការអន្តរក្រសួង
- ថ្ងៃទី ២៣ មករា ២០០៤ សេក្ដីជូនដំណឹងស្ដីពីជំងឺផ្ដាសាយបក្សី
- ថ្ងៃទី ២៣ មករា ២០០៤ ប្រកាសស្ដីពីការកំណត់តំបន់ជំងឺផ្ដាសាយបក្សី
- ថ្ងៃទី ២៦ មករា ២០០៤ សារាចរណែនាំស្ដីពីវិធានការកំចាត់ ការឆ្លងរាលដាល ជំងឺផ្ដាសាយបក្សី

# វិធានការណ៏ច្បាប់

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (កសក

04th Feb. 2004, Prokas on ban of visiting Tamao Zoo

11th Feb. 2004, Prokas on HPAI outbreak area

05th Mar. 2004, Prokas on HPAI outbreak area

12th Mar. 2004, Prokas on HPAI outbreak area

09th Apr. 2004, Prokas on HPAI outbreak area

22nd Jun. 2004, Prokas on HPAI free area

13th Jul. 2004, declaration on HPAI situation

13th Jul. 2004, strengthening HPAI control Measures

22nd Jul. 2004, Prokas on HPAI outbreak area

21st Sep. 2004, Prokas on HPAI outbreak area

31st Dec. 2004, declaration on HPAI control measures

# វិធានបសុពេទ្យ

## នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល (នផប

- ប្រព្រឹត្តិកម្មរហ័សនៅតាមបណ្តាខេត្ត-ក្រុង ដើម្បីផ្សព្វផ្សាយ និង តាមដានការសង្ស័យផ្ទុះជំងឺ
- ហាមឃាត់ចលនាសត្វ និងការនាំចូលតាមច្រកព្រំដែន
- កសិដ្ឋានដែលសង្ស័យថាមានជំងឺផ្តាសាយបក្សី
    - ✓ បញ្ជូនសំណាកទៅមន្ទីរពិសោធន៍
    - ✓ អនុវត្តវិធានអានាម័យ និង ការសំលាប់មេរោគ
    - ✓ បញ្ឈប់ការធ្វើចលនាសត្វ
    - ✓ ធ្វើការតាមដានជុំវិញកន្លែងផ្ទុះជំងឺ

# វិធានការរំងាប់មេរោគនៅកសិដ្ឋានផ្ទុះជីវី










# សេចក្ដីណែនាំ
# ការទប់ស្កាត់ការរាតត្បាតជំងឺផ្ដាសាយបក្សី

- កសិដ្ឋានត្រូវអនុវត្តវិធានការសុវត្ថិភាពជីវសាស្ត្រ
- ធ្វើការតាមដានជាប្រចាំ រកវត្តមាន វីរុស $H_5$, $H_7$, $H_9$
- ចាក់វ៉ាក់សាំងការពារទល់នឹង វីរុស $H_5$, $H_7$, $H_9$
- ចៀសវាងការប៉ះពាល់ជាមួយបក្សីទឹកព្រៃ
- មិនត្រូវចេញចូលកសិដ្ឋានដែលមានផ្ទុះជំងឺផ្ដាសាយបក្សី
- មិនត្រូវទំលាក់សាកសពបក្សីងាប់ទៅក្នុងទឹក
- ធ្វើការសំលាប់មេរោគក្នុងទឹក

# សេចក្តីណែនាំ
# ការអនុវត្តសុវត្ថិភាពជីវសាស្ត្រ

- អនុវត្តវិធានការ ចេញទាំងអស់ និង ចូលទាំងអស់
- ការពារកុំឱ្យមានការប៉ះពាល់នៃបក្សីព្រៃជាមួយបក្សីចិញ្ចឹម
- អនាម័យទឹកដោយកុំឱ្យមានការឆ្លងមេរោគពីបក្សីព្រៃ
- អនុញ្ញាតតែមនុស្សនិងមធ្យោបាយចាំបាច់ឱ្យចូលកសិដ្ឋាន
- អនាម័យសំលៀកបំពាក់ចំពោះអ្នកធ្វើការនៅកសិដ្ឋាន
- ធ្វើការរំងាប់មេរោគនូវរាល់ឧបករណ៍ និងមធ្យោបាយចេញ-ចូល
- ចៀសវាងការប្រើសប្រាស់ឧបករណ៍រួមគ្នានៃបក្សីនៅទ្រុងផ្សេងគ្នា និងនាំចូលបក្សីចូលកសិដ្ឋាន

# សេចក្តីណែនាំនៃអង្គការសុខភាពពិភពលោក WHO សុវត្ថិភាពសុខភាពនិងម្ហូបអាហារ

- មិនត្រូវលក់ ឬបរិភោគ បក្សីឈឺ
- ធ្វើការចំអិនអាហារឱ្យបានល្អ ដើម្បីសំលាប់មេរោគផ្សេងៗ
- សាច់ត្រូវចំអិនឱ្យបានល្អគ្រប់ពេល
- ត្រូវលាងសំអាតដៃជាមួយទឹកស្អាតជានិច្ច មុន និងក្រោយ ការរៀបចំអាហារ
- ត្រូវពាក់ស្រោមដៃ និងសំអាតឧបករណ៍-សំភារៈប្រើប្រាស់ជាមួយសាច់
- សាច់ និងអាហារដែលចំអិនរួចត្រូវរក្សាទុកនៅទីត្រជាក់ ( ៥អង្សា

# សុវត្ថិភាពនៃការចំអិនម្ហូបអាហារ

| | | |
|---|---|---|
| -សាច់ប្រហិតមាន់ចំអិនម្តងរួច: | ៧៥អង្សារ | ១នាទី |
| -សាច់ប្រហិតមាន់ឆៅ: | ៨៥អង្សារ | ១០ទៅ១៥នាទី |
| -មាន់អាំង: | ៨៥ -៩០អង្សារ | ៦០នាទី |
| -សាច់ -ស៊ុត : | ៧០អង្សារ | ៣០នាទី |
| | ៧៥អង្សារ | ៥នាទី |
| | ៨០អង្សារ | ១នាទី |

# សេចក្ដីណែនាំ
# ចំពោះ អ្នកចិញ្ចឹម អាជីវករ ប្រជាជន

- ចៀសវាងការប៉ះពាល់ជាមួយបក្សីឈឺ
- អនុវត្តវិធានការសុវត្ថិភាពផ្ទាល់ខ្លួន (PPE) ចំពោះអ្នកធ្វើការជាមួយសត្វស្លាបដែលងាយទទួលជំងឺ តាមគោលការណ៍ណែនាំរបស់ WHO/FAO
- អ្នកដែលសង្ស័យថាមានជំងឺផ្ដាសាយបក្សី ត្រូវទៅមន្ទីរពេទ្យធ្វើការវិភាគរោគទាន់ពេលវេលា តាមសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាល
- អនុវត្តគោលការណ៍ អនាម័យ និង សុវត្ថិភាពជីវសាស្ត្រជាប្រចាំ

# សន្និដ្ឋានៈ ស្ថានភាពទូទៅនៃការផ្ទុះជំងឺផ្តាសាយបក្សី

- ហាមឃាត់នូវការនាំចូលតាមច្រកអន្តរជាតិ និង ទ្វេរភាគី
- ការធ្វើវិធានបសុពេទ្យមុននិងក្រោយការផ្ទុះជំងឺ
- បក្សីប្រើប្រាស់សំរាប់តែតំរូវការក្នុងស្រុក
- ប៉ះពាល់កសិដ្ឋានពាក់កណ្តាលឧស្សាហកម្ម មួយចំនួន

⬇

## បន្តអនុវត្តការតាមដាន និង ស្រាវជ្រាវជាប្រចាំ

## សំណូមពរ

**ដើម្បីទប់ស្កាត់ការរាលដាល និងលុបបំបាត់ជំងឺឱ្យមានប្រសិទ្ធភាព ប្រទេសកម្ពុជាសូមធ្វើការអំពាវនាវដូចខាងក្រោម៖**

- បង្កើនកិច្ចសហការនៅក្នុងតំបន់ ជាពិសេសជាមួយប្រទេសជិតខាងដើម្បីបង្កើតប្រព័ន្ធផ្លាស់ប្តូរពត៌មាន នៃជំងឺផ្តាសាយបក្សី ដើម្បី ទប់ស្កាត់ការរាលដាល និងលប់បំបាត់នៃជំងឺនេះ មានប្រសិទ្ធភាពខ្ពស់
- លើកទឹកចិត្តដល់ការស្រាវជ្រាវ និងផ្គត់ផ្គង់វ៉ាក់សាំងការពារជំងឺផ្តាសាយបក្សី
- លើកទឹកចិត្តដល់ការអនុវត្តប្រព័ន្ធសុវត្ថិភាពជីវសាស្ត្រ
- បង្កើនការចូលរួម និងយកចិត្តទុកដាក់ពីសាធារណៈជន
- ផ្តល់ជំនួយសំរាប់ការអនុវត្តវិធានការទប់ស្កាត់និងលប់បំបាត់ជំងឺផ្តាសាយបក្សី
- ផ្សព្វផ្សាយឱ្យបានទូលាយនូវការយល់ដឹងអំពីជំងឺផ្តាសាយបក្សី
- បង្កើនប្រសិទ្ធភាពការពារ និងទប់ស្កាត់ការរាតត្បាតជំងឺផ្តាសាយបក្សី

# សំណូមពរ

**សូមអំពាវនាវដល់ម្ចាស់ជំនួយ និងអង្គការជាតិ-អន្តរជាតិ ដូចជា** FAO, OIE, WHO, JICA **ដើម្បីៈ**

- ផ្តល់ជំនាញការបច្ចេកទេស
- អនុវត្តការងារ ផ្សព្វផ្សាយ
- អនុវត្តការស្រាវជ្រាវជំងឺ
- បណ្តុះបណ្តាល
- បំពាក់សំភារៈ-បរិក្ខារមន្ទីរពិសោធន៍
- ប្រព័ន្ធពតិមាន
- សិក្សាផលប៉ះពាល់សេដ្ឋកិច្ច-សង្គម
- ស្តារ និងលើកស្ទួយផលិតកម្មបក្សី

# ការធ្វើរោគវិនិច្ឆ័យប្រៀបធៀប

| ឈ្មោះ ជំងឺ | ស ុតមិន ធម្មតា (Abnormal eggs) | ការឆ្លងរា លដាល (Spead of infection) | អត្រាស្លាប់ (Mortality) | ស្លាកស្នាម នៅថង់ខ្យល (Lesson in air sac) | ស្លាកស្នាមនៅពំ នាសជាលិកា នៅលើកញ្ចក់ | ចាក់មេរោគចូល ទៅអំប្រ៊ីយ៉ុងកូន មាន់ | សរីរាង្គបានទទួល ប៉ះពាល់ Organs affected |
|---|---|---|---|---|---|---|---|
| ជំងឺ ញូវកើស | វិជ្ជមាន (+Ve) | ប្រ៉ាស (Rapid) | ខ្ពស់ (High) | វិជ្ជមាន (+Ve) | អវិជ្ជមាន (-Ve) | Embryonic mortality haemorrhage and oedema | Proventiculus |
| ជំងឺរលាក បំពង់ខល់ | វិជ្ជមាន (+Ve) | រហ័ស (Rapid) | ខ្ពស់ (High) | វិជ្ជមាន (+Ve) | អវិជ្ជមាន (-Ve) | Dwarfing and curling of embryo death in 5-7days | Respiratory and reproductive tract |
| ជំងឺរលា I.B ផ្លូវដង្ហើម | វិជ្ជមាន (-Ve) | យឺត (Slow) | អាចប្រែប្រួល (Variable) | វិជ្ជមាន (-Ve) | Intranuclear inclusion bodies | Pock lession | Respiratory tract |
| ជំងឺ ផ្កាសាយ បក្សី | វិជ្ជមាន (-Ve) | រហ័ស (Rapid) | ខ្ពស់ លឿន (High) | វិជ្ជមាន (+Ve) | វិជ្ជមាន (+Ve) | ស្នាមហូរឈាម | ថង់ខ្យល់ (Air sac) ស្រោមបេះដូង |

# ជំងឺញូវកាស (Newcastle Disease)

## (Ranikhet Disease; Avian Pest; Avian Distemper; Doyle's Disease; Pneumoencephalitis)

អាត្រាមាន់ងាប់បង្គួរ
មានសញ្ញាសសៃប្រសាទ



មានហូរឈាមនៅទងកោះ



# ជំងឺបង្កដោយពពួកបាក់តេរី (Bacterial Disease)

## អាចព្យាបាលដោយប្រើអង់ទីប៊ីយ៉ូទិច



ជំងឺរាគសបក្សី (Pullorum disease)
(Bacillary white diarrhoea)

ជំងឺគ្រុនពោះវៀនបក្សី (Fowl typhoid)

(Salmonella gallinarum infection ី Infectious leukaemia)



ជំងឺអាសន្នរោគបក្សី (Fowl Cholera)
(Avian pasterellosis)

ជំងឺកូរីសាបក្សី (Infectious coryza )

# ជំងឺហ្គូមបូរូ (Gumboro disease)

# (Infectious bursal disease or Infectious bursitis)

អាត្រាមាន់ងាប់បង្គួរ



ស៊ុតខុសធម្មតា និងភាគពង



ហើមរលាក ក្រពេញទឹករងៃ



# ជំងឺម៉ារិក (Marek's disease)
# (Range paralysis; Skin leukosis; Neural leukossis)



អាត្រាមាន់ងាប់បង្គួរ
បក្សិស្លេកស្លាំង
មានសពាខ្វិនជើង

ឈឺភាគច្រើនលើ
មាន់អាយុ
១៦សប្តាហ៍

មានរលាកសសៃជើង

# ជំងឺអុតបក្សី (Fowl pox)
## (Avian pox; Contagious epithelioma; Variola)



អាត្រាមាន់ងាប់ទាប
មានស្នាមអុតខ្មៅ
នៅលើសេ និង
ត្របកភ្នែក

# ជំងឺរលាកទងសួត
# (Infection bronchitis)







អាត្រាងាប់ខ្ពស់
ហៀរសំបោ
សំលេងពិបាក
ដកដង្ហើម
ស៊ុតមិនប្រក្រតី
សំបកស៊ុតទន់
រាគពង



# ជំងឺរលាកបំពង់សំលេង និង បំពង់ខ្យល់

# (Infectious laryngotracheitis or Avian diptheria)



អាត្រាឈឺខ្ពស់
អាត្រាងាប់បង្គួរ
ឬ ប្រែប្រួល
ហៀរទឹកភ្នែក
ពិបាកដកដង្ហើម
ក្អកមានស្លេស
ឬឈាម
បក្សីដកក
និងជង្ហក់
រលាកតំបកភ្នែក
អាត្រាស៊ីតថយ

# ជំងឺផ្តាសាយបក្សី (Avian influenza)






មានស្នាមជាំឈាមនៅស្មងជើង





មានស្នាមហូរឈាមនៅកន្សោមពង



មានហូរសំបោ និង ក្បាលជាំឈាមពណ៌ ស្វាយ



មានស្នាមហូរឈាមនៅផ្កាសស្តើង ណពិងថង់ខ្យល់ ជុំវិញបេះដូង



មានស្នាមបែកសសៃឈាមនៅក្នុងពងលឿង



មានស្នាមហូរឈាមនៅបំពង់ក



មានស្នាមជាំឈាមក្រម៉ៅនៅបំពង់ខ្យល់





មានស្នាមគ្រាប់ឈាមនៅលើ
ខ្លាញ់ស្រោមបេះដូង



មានស្នាមហូរឈាមនៅកន្សោមពង



មានស្នាមជាំឈាមក្រម៉ៅនៅលើ
ភ្នាសស្តើងនៃសរីរាង្គក្នុង

# គ្រូបង្ហាត់សិក្សាការចិញ្ចឹមសត្វគោ ក្របី



គ្រូបង្វឹក៤ខេត្ត គោលដៅ ព្រៃវែង
ស្វាយរៀង កំពង់ចាម និង ក្រចេះ
ពេលបញ្ចប់វគ្គបណ្តុះបណ្តាល
នៅសាលាកសិកម្មខេត្តកំពង់ចាម

## សិក្ខាកាមទទួលបណ្ដុះបណ្ដាលពេទ្យសត្វភូមិជំនាន់ទី ១ ក្នុងស្រុកជើងព្រៃខេត្តកំពង់ចាម


ម៉ៅ ឃឿន


ហាន ចាន


ចាំង ស៊ីណាត


នាង គាប


ទិម ពន្លី


ឃុំ នី


ឯម សារ៉ី


សាត ស៊ីម


ជុំ ខន


ចិន ចាន់ធុ


សុក រី


សេង រ៉ែង


ពេញ ខុន


ស៊ុំ ថន


សែ ហុកស៊ីម


ជី សុន


សៅ អុន


កៅ ពុំ


តង់ ហឿន


ហ៊ាង ឆាន

## សិក្ខាកាមវគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិជំនាន់ទី២ ក្នុងស្រុកជើងព្រៃខេត្តកំពង់ចាម

( 20/11/2000 - 18/12/2000 )



## សិក្ខាកាមទទួលបណ្ដុះបណ្ដាលភ្នាក់ងារសុខភាពសត្វភូមិជំនាន់ទី៣ ក្នុងស្រុកជើងព្រៃខេត្តកំពង់ចាម
## ( 21/6/2001 - 19/7/2001 )


យ៉ន យ៉ាន់


ដោក ណាត


យួន ហ៊ុច


យួន ហ៊ុល


យ៉េង ល្បើ


ម៉ង់ រិត


ហៀង ហៀប


សុន សល់


អ៊ុំ ខេម


ជើង ផល


ឆុច គីមលី


គាវ ផា


ថោង ស្រី


យ៉ែម វឿន


លី ហ៊ោង


យួន ច័ន្ទតារ៉ា


យួន យ៉េង


ជួន សុភា


ណាល សុខណៅ


យ៉ិន សុគន្ធ

សិក្ខាកាមបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិជំនាន់ទី៤ ក្នុងស្រុកបារាយខេត្តកំពង់ចាម

( 25/9/2001 - 24/10/2001 )



សន សាន, ឈន ហត, ហ៊ុំ ណារីឡុង, លឹម គន្ធា, ស៊ី ផន, ម៉ុង សាឡន

មិន មង, ប៉ក់ ប៊ុក្ក, ហៀន រ៉ែត្ត, រ៉ុម សុខធី, ឈិម ចេវហង, ផ្លេក ចាន់លី, អែម ពិន

ឈន ប៊ិន, យូ ប៊ីរ៉ន, មន មន, ហ៊ន ម៉េង, ភឹម គារ៉ុង, កៅ ឃឹម, ហៀង ហាស



ការប្រមូលគោ ក្របី មុនពេលចាក់ថ្នាំសាំង



ចាក់ថ្នាំការពារ ក្របី នៅស្រុកព្រៃឈរ



ការប្រមូលគោក្របី នៅស្រុកជើងព្រៃ



ចាក់ថ្នាំការពារជម្ងឺសារទឹក នៅស្រុកជើងព្រៃ



លោកជា_សុជាតិ  អ្នកគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ
នែនាំដល់សិក្ខាកាម



បង្រៀនពីរបៀបបូមថ្នាំដល់ភ្នាក់ងារសុខភាពសត្វភូមិ



ការណែនាំដល់ភ្នាក់ងារសុខភាពសត្វភូមិ



ការចាក់ថ្នាំការពារជម្ងឺសារទឹក គោ ក្របីនៅស្រុកជើងព្រៃ